វិទ្យាស្ថានជាតិអប់រំ

NATIONAL INSTITUTE OF EDUCATION

មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី

NEW GENERATION PEDAGOGICAL RESEARCH CENTER


# ទស្សនៈរបស់សិស្ស គ្រូ និងអាណាព្យាបាលចំពោះ សមត្ថភាពអំណានភាសាខ្មែររបស់សិស្សថ្នាក់ទី៧នៅ អនុវិទ្យាល័យស្វាយរលំ

## Perspectives of students teachers and parents on the ability to read Khmer language of 7th grade students at Svay Rolum Secondary School

សារណាខ្លី

សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ


ឡៀប ច័ន្ទវត្តី


ឆ្នាំ ២០២១

# វិទ្យាស្ថានជាតិអប់រំ

NATIONAL INSTITUTE OF EDUCATION

## មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី

NEW GENERATION PEDAGOGICAL RESEARCH CENTER


# ទស្សនៈរបស់សិស្ស គ្រូ និងអាណាព្យាបាលចំពោះសមត្ថភាពអំណានភាសាខ្មែររបស់សិស្សថ្នាក់ទី៧នៅ អនុវិទ្យាល័យស្វាយរលំ

**Perspectives of students, teachers and parents on the ability to read Khmer language of 7th grade students at Svay Rolum Secondary School**


បេក្ខជន ៖ ទៀប ច័ន្ទវត្តី

គ្រូណែនាំ ៖ គង់ ម៉ាណែត

គណៈកម្មការការពារសារណា៖ ១. បណ្ឌិត ឈាង សទ្ធាត(ប្រធាន)

២.បណ្ឌិត ស៊ុន សុម៉ារ៉ា(អនុប្រធាន)

៣.បណ្ឌិត ម៉ម ចាន់សៀន(សមាជិក)


ឆ្ន ២០២១

# មូលន័យសង្ខេប

ការសិក្សានេះត្រូវបានធ្វើឡើង ដើម្បីសិក្សាអំពីទស្សនៈរបស់គ្រូ សិស្ស អាណាព្យាបាលសិស្ស និងអ្នកជំនាញទៅលើសមត្ថភាពអំណានភាសាខ្មែរ និងនីតិវិធីក្នុងការលើកម្ពស់សមត្ថភាពអំណានភាសាខ្មែរនៅថ្នាក់ទី៧នៃសាលារៀនអនុវិទ្យាល័យស្វាយរលំ។ ហើយការសិក្សានេះត្រូវធ្វើឡើងជាមួយសិស្ស អាណាព្យាបាលសិស្ស គ្រូបង្រៀន មកពីសាលាអនុវិទ្យាល័យស្វាយរលំ និងអ្នកជំនាញអក្សរសាស្ត្រខ្មែរ ដែលសរុបទាំងអស់១៦។ ទន្ទឹមនឹងនេះដែរ វាបានធ្វើឡើងតាមវិធីសាស្ត្រគុណវិស័យ ដោយប្រើនូវកិច្ចសម្ភាសបែបសំណួរពាក់កណ្តាលគ្រោង( semi-structured interview) ដែលមានសំណួរទាំងអស់ជាទម្រង់សំណួរបើក។ តាមរយៈការវិភាគទិន្នន័យដែលប្រមូលបានយើងឃើញថា សមត្ថភាពអំណានរបស់សិស្សនៅថ្នាក់ទី៧នៃសាលារៀនអនុវិទ្យាល័យស្វាយរលំមានលក្ខណៈនិង កម្រិតមិនដូចគ្នាទេ។ សិស្សដែលមានសមត្ថភាពអានបានល្អមានចំនួនប្រហែល២០ភាគរយប៉ុណ្ណោះ ក្នុងចំណោមសិស្សទាំងអស់ ហើយសិស្សដែលមានសមត្ថភាពអាននកម្រិតមធ្យមនិងល្អបង្គួរមានប្រមាណ៥០ភាគរយនៃចំនួនសិស្សសរុប។ រីឯសិស្សខ្សោយការអានមានទៅដល់៣០ភាគរយនៃចំនួនសិស្សសរុប។ ហើយចំពោះផ្នែកដែលពួកគេមានកម្សោយខ្លាំងទៅលើការយល់នៃពាក្យ ការយល់ន័យរបស់អត្ថបទ និងការឆ្លើយសំណួរលើអត្ថបទដែលត្រូវការឱ្យមានការវិភាគស៊ីជម្រៅ។ បន្ទាប់មកទៀត ចំពោះមូលហេតុដែលនាំឱ្យសិស្សមានសមត្ថភាពអាននៅមានកម្រិត វាបណ្តាលមកពីបញ្ហា៧ចំណុច ដែលការសិក្សានេះបានរកឃើញ (១). កត្តាបញ្ហារបស់សិស្សផ្ទាល់ដែលមិនយកចិត្តទុកដាក់ខិតខំរៀនអាន ខ្ជិលអាន មិនទម្លាប់ក្នុងការអាន (២). កត្តាបញ្ហាសាលារៀនដែលសំដៅលើគុណភាពនៃការដឹកនាំ និងការជំរុញពីគណៈគ្រប់គ្រងសាលា ការប្រើវិធីសាស្ត្របង្រៀនតាមបែបប្រពៃណីដែលមិនជំរុញដល់ការអាន និងបញ្ហាចំនួនសិស្សច្រើនក្នុងមួយថ្នាក់ៗ (៣). បញ្ហាគ្រួសារដែលខ្វះការយកចិត្តទុកដាក់លើការសិក្សារបស់កូន (៤). សិស្សខ្វះមូលដ្ឋានគ្រឹះពីថ្នាក់បឋមសិក្សាមក (៥). កត្តាបញ្ហាបណ្ណាល័យដែលមិនបានរៀបចំទីកន្លែងអានឱ្យបានសមរម្យ ពុំមានសៀវភៅដែលទាក់ទាញដល់អ្នកអាន (៦). កត្តាសង្គមដែលខ្វះការឱ្យតម្លៃលើការអាន និង(៧). កត្តាសៀវភៅសិក្សាគោលដែលគួរតែធ្វើបច្ចុប្បន្នភាពឱ្យមានលក្ខណៈទាក់ទាញបន្ថែមទៀត។ ទន្ទឹមនឹងនេះ យើងគ្រប់គ្នាដឹងហើយថា សមត្ថភាពនៃអំណានមិនអាចកាត់ផ្តាច់ចេញពីទម្លាប់អានបានទេ។ ដូចនេះ ប្រសិនបើសិស្សមានទម្លាប់អាន នោះសមត្ថភាពអានរបស់ពួកគេក៏បានល្អប្រសើរទៅតាមនោះដែរ។ ប៉ុន្តែតាមរយៈការស្រាវជ្រាវនេះ បានរកឃើញថា សិស្សនៅកម្រិតថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំមិនចូលចិត្តការ

អាន និងមិនមានទម្លាប់អានជាប្រចាំនោះទេ។ ពួកគេចំណាយពេលក្នុងការអានមួយថ្ងៃមិនលើសពី ៣០នាទីផង ហើយសៀវភៅដែលពួកគេអានពុំមានអ្វីក្រៅពីសៀវភៅពុម្ពនោះទេ។ បន្ថែមពីនេះ នៅកំឡុងពេលអាននោះ គេប្រឹងអានឱ្យតែដាច់ពាក្យ ឬអានឱ្យទៅរលូន ប៉ុន្តែមិនបានសង្កេតពិចារណាលើអត្ថន័យនៃពាក្យឬអត្ថបទនោះទេ។ ជាមួយគ្នានេះ សិស្សម្នាក់បានបង្ហាញថានៅពេលគេចូលអានសៀវភៅក្នុងបណ្ណាល័យ គេមានអារម្មណ៍ថាដូចជាមនុស្សចម្លែកនិងខុសគេ ហេតុនេះយូរៗទៅ គេក៏លែងចូលបណ្ណាល័យតែម្តង។ លើសពីនេះទៀត សិស្សភាគច្រើនបានចំណាយពេលជាមួយការលេងទូរសព្ទច្រើនជាការអានសៀវភៅ។ អ្វីទាំងនេះហើយដែលបានបង្ហាញពីឥរិយាបថអវិជ្ជមានទៅលើទម្លាប់នៃការអានសៀវភៅរបស់សិស្សនៅអនុវិទ្យាល័យស្វាយរលំ។ នៅចុងបញ្ចប់នៃលទ្ធផលស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានរកឃើញផងដែរ អំពីនីតិវិធីនៃការលើកកម្ពស់អំណានភាសាខ្មែរ។ នៅក្នុងនោះ នីតិវិធីដែលអ្នកគ្រូបានអនុវត្តកន្លងមកមានដូចជា ការខិតខំបង្រៀនមូលដ្ឋានគ្រឹះនៃការអាននៅដើមម៉ោងសិក្សា ការបន្ថែមម៉ោងដោយឱ្យសិស្សធ្វើការហាត់អានជាក្រុមតូច និងការជួយអ្នកខ្សោយអានឱ្យរៀនអាននៅម៉ោងចេញលេងឱ្យគ្រូស្តាប់។ ហើយបន្ថែមពីនេះ ពួកគេក៏បានបញ្ជ្រាបតម្លៃនៃការអានឱ្យអាណាព្យាបាលបានដឹង និងជួយកូនគាត់អានបន្ថែមនៅផ្ទះរាល់ពេលដែលសាលារៀនមានការប្រជុំជាមួយពួកគាត់។ មួយវិញទៀត តាមរយៈការសម្ភាសអ្នកជំនាញ អ្នកគ្រូ និងអាណាព្យាបាល អ្នកស្រាវជ្រាវក៏បានទទួលទិន្នន័យបន្ថែមពីនីតិវិធីជួយសិស្សឱ្យរីកចម្រើនលើសមត្ថភាពអានតាមមធ្យោបាយផ្សេងទៀតដែរ។ មធ្យោបាយទាំងនោះរួមមាន (១).ការបណ្តុះទម្លាប់អានរបស់សិស្សតាមរយៈការជួយជ្រោមជ្រែងពីអាណាព្យាបាល គ្រូ និងភាគីពាក់ព័ន្ធផ្សេងទៀត (២). ការបង្រៀនរបស់គ្រូត្រូវប្រើវិធីសាស្ត្របង្រៀនថ្មី បែបចម្រុះបន្ថែម ដែលជំរុញឱ្យការអានរបស់សិស្សអនុវត្តបានច្រើន (៣). ក្រសួងអប់រំ យុវជននិងកីឡាក៏ដូចជាស្ថាប័នពាក់ព័ន្ធនានាត្រូវប្រើបណ្តាញសង្គមក្នុងការគាំទ្រ ផ្សព្វផ្សាយពីការអាន ហើយបើអានក្រសួងក៏ត្រូវគិតពិចារណាបន្ថែមទៅលើសៀវភៅសិក្សាគោលអំណាន ឬមួយផលិតសៀវភៅជំនួយបន្ថែមដល់ការអាន។ ហើយនីតិវិធីបន្ថែមទៀតគឺផ្តោតទៅលើគុណភាពនៃបណ្ណាល័យ ដោយត្រូវបណ្តុះបណ្តាលគ្រូបណ្ណាល័យឱ្យយល់ច្បាស់ពីរបៀបអាន ការរៀបចំបណ្ណាល័យ និងចេះកំណត់ប្រធានបទសៀវភៅដែលសិស្សចូលចិត្តអាននិងមានប្រយោជន៍សម្រាប់អ្នកអាន។ ហើយពិសេសជាងនេះទៀត នីតិវិធីចុងក្រោយ គឺធ្វើយ៉ាងណាឱ្យសិស្សមានការភ្ញាក់រឭកចង់អាន ស្រឡាញ់ការអាន និងបណ្តុះទម្លាប់អានឱ្យកាន់តែកើនឡើង។

# Abstract

This study was conducted to study the views of teachers, students, guardians, students and experts on Khmer reading ability and procedures for improving Khmer reading ability in grade 7 of Svay Rolum Secondary School. This study was conducted with 16 students, parents, teachers from Svay Rolum Secondary School and Khmer literature experts. At the same time, it is done in a qualitative way, using semi-structured interviews with all questions in the form of open-ended questions. By analyzing the collected data, we see that the reading ability of the students in the 7th grade of Svay Rolum Secondary School is different and the level is not the same. Only about 20 percent of all students are able to read well, and about 50 percent of all students are able to read well. Students with reading disabilities make up 30 percent of the total number of students. And for the part where they are very weak in understanding the words, understanding the meaning of the text and answering questions on the text that requires in-depth analysis. Then, for the reason that students have limited reading ability, it is caused by 7 problems that this study found (1). Problems of students who do not pay attention to study hard, lazy to read, not in the habit of reading (2). School problem factors that refer to the quality of leadership and encouragement from the school management, the use of traditional teaching methods that do not promote reading and the problem of large numbers of students in each class (3). Family problems that lack attention to their children's education (4). Students lack the basics from primary school (5). The problem is that the library does not have a proper place to read, there are no books that attract readers (6). Social factors that lack the value of reading and (7). Basic textbook factors that should be updated to be more attractive. At the same time, we all know that the ability to read is inseparable from reading. As a result, students' reading habits improve. However, this research found that students in the seventh grade of Svay Rolum Secondary School do not like reading and do not have a habit of reading regularly. They spend no more than 30 minutes a day reading, and the books they read are nothing more than textbooks. In addition, during the reading, they try to read only words or read smoothly, but do not observe the meaning of the word or text. And (7). Basic textbook factors that should be updated to be more attractive. At the same time, a student reported that when he read books in the library, he felt like a stranger and different, so he eventually stopped going to the library. In addition, most students spend more time on the phone than reading books. These are the things that show the negative attitude towards the reading habits of students at Svay Rolum Secondary School. The procedures that teachers have implemented in the past include efforts to teach the basics of reading at the beginning of the class, overtime by having students practice reading in small groups, and helping the weak to learn to read at play time. Let the teacher listen. In addition, they also instill the value of reading to parents and help their children read more at home every time the school has a meeting with them. In addition, through interviews with experts, teachers and parents, researchers also received additional data on procedures to help students develop their reading skills in other ways. These include: (1) cultivating students' reading habits through the assistance of parents, teachers and other stakeholders (2). Teachers 'teaching must use new teaching methods that diversify students' reading practice (3). The Ministry of

Education, Youth and Sports, as well as relevant institutions, must use social media to support the promotion of reading, and if reading, the Ministry must also consider additional textbooks or produce reading aids in addition to reading. And further procedures are focused on the quality of the library by training library teachers to understand how to read, organize the library and determine the topic of books that students like to read and useful for readers. And in addition, the final procedure is to make students wake up, want to read, love to read and cultivate more reading habits.

# **ទិចាររបស់គ្រូណែនាំ**

ឈ្មោះកម្មវិធី៖ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ

ឈ្មោះបេក្ខជន៖ **ទៀប ច័ន្ទវត្តី**

ចំណងជើងនិក្ខេបបទ៖" **ទស្សនៈរបស់សិស្ស គ្រូ និងអាណាព្យាបាលចំពោះសមត្ថភាពអំណាននភាសាខ្មែររបស់សិស្សថ្នាក់ទី៧នៅអនុវិទ្យាល័យស្វាយរលំ** "

សូមបញ្ជាក់ថាកិច្ចការស្រាវជ្រាវខាងលើសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យគឺត្រូវបានធ្វើដោយបេក្ខជនខាងលើពិតប្រាកដមែន ដោយស្ថិតនៅក្រោមការណែនាំរបស់ខ្ញុំ។ ខ្ញុំបានណែនាំលើចំណុចមួយចំនួនដូចជាការមើលទៅលើបញ្ហាសម្រាប់ស្រាវជ្រាវ ការសំយោគឯកសារពាក់ព័ន្ធ វិធីសាស្ត្រនៃការស្រាវជ្រាវ ការវិភាគទិន្នន័យ និងការពិភាក្សានៅក្នុងសារណាខ្លីនេះ។

ឈ្មោះគ្រូណែនាំ៖ ..........................................

ហត្ថលេខា៖ ...............................................

កាលបរិច្ឆេទ៖ ..............................................

# វិចាររបស់អ្នកស្រាវជ្រាវ

សូមបញ្ជាក់ថា ខ្ញុំជាអ្នកស្រាវជ្រាវ «**ទៀប ច័ន្ទវត្តី**» បានធ្វើការស្រាវជ្រាវលើប្រធានបទ «**ទស្សនៈរបស់សិស្ស គ្រូ និងអាណាព្យាបាលចំពោះសមត្ថភាពអំណានភាសាខ្មែររបស់សិស្សថ្នាក់ទី៧នៅអនុវិទ្យាល័យស្វាយរលំ**» សម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យរបស់មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីនៃវិទ្យាស្ថានជាតិអប់រំ។ បន្ថែមពីលើនេះ ខ្ញុំក៏សូមបញ្ជាក់ផងដែរថា សារណាខ្លីនេះទាំងមូល ឬផ្នែកខ្លះនៃសារណាខ្លីគឺមិនបានប្រើប្រាស់សម្រាប់បំពេញតម្រូវការ ឬការសិក្សាផ្សេងទៀតនៅសាកលវិទ្យាល័យផ្សេងទៀតឡើយ។

ហត្ថលេខាបេក្ខជនៈ ............................................

កាលបរិច្ឆេទៈ ...................................................

ហត្ថលេខាគ្រូណែនាំៈ ..........................................

កាលបរិច្ឆេទៈ ...................................................

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំសូមថ្លែងអំណរគុណជាអនេកអប្បការចំពោះ៖

បិតានាម កងសារឿន និងមាតានាម សុខ ទូច ព្រមទាំងបងប្អូនទាំងអស់ដែលបាន បីបាច់ ថែរក្សានិងផ្តល់លទ្ធភាពក៏ដូចជាកម្លាំងចិត្តដ៏ធំធេងចំពោះខ្ញុំក្នុងការរៀនសូត្រតាំងពីតូច រហូតមកដល់បច្ចុប្បន្ននេះ។

លោកគ្រូ គង់ ម៉ាណែត ជាសាស្ត្រាចារ្យដឹកនាំផ្ទាល់ដែលបានលះបង់កម្លាំងកាយចិត្ត ពេលវេលាដ៏មានតម្លៃរបស់លោកគ្រូដើម្បីជួយបង្ហាត់បង្រៀនណែនាំ កែលំអ ផ្តល់ជាគំនិតដ៏មាន គុណតម្លៃបន្ថែមរហូតបានទទួលនូវលទ្ធផលសម្រេចជានិក្ខេបបទនេះឡើង។

លោកគ្រូ ជី គីមអ៊ី លោកគ្រូ ភេ សៅរិទ្ធិ លោកគ្រូ ស្រ៊ូល លីហ៊ុល និងលោកគ្រូ បាញ ហានម៉ាន ដែលបានបង្រៀនមុខវិជ្ជាផ្សេងៗនៃជំនាញឯកទេសប្រឹក្សាគរុកោសល្យ ព្រមទាំង បង្ហាត់បង្ហាញ ផ្តល់ជាដំបូន្មានល្អនៅក្នុងការសិក្សាស្រាវជ្រាវ។

លោកគ្រូ អ្នកគ្រូទាំងអស់ដែលបានបង្ហាត់បង្រៀនខ្ញុំឱ្យមានចំណេះដឹងតាំងពីបឋម សិក្សារហូតមកដល់មហាវិទ្យាល័យ។

លោកបណ្ឌិត ស៊ុន សុម៉ារ៉ាដែលជាអ្នកសម្របសម្រួលកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ឯកទេស ប្រឹក្សាគរុកោសល្យនេះ ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ ថ្មីដែលបានបង្កើតកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ប្រឹក្សាគរុកោសល្យនេះឡើង។

លោកនាយកសាលាអនុវិទ្យាល័យស្វាយរលំ សម្រាប់ការអនុញ្ញាត និងគាំទ្រការប្រមូល ទិន្នន័យពីសាលារៀនរបស់គាត់។ ហើយ ខ្ញុំនឹងមិនភ្លេចនូវគុណបំណាច់របស់អ្នកចូលរួម ដែល មានដូចជាគ្រូបង្រៀនពីររូបនៅថ្នាក់ទី៧ សិស្សខ្សោយការអានទាំង៦រូប អាណាព្យាបាល និងអ្នក ជំនាញអក្សរសាស្ត្រ ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការផ្តល់ធាតុចូលដល់ការសិក្សា មួយនេះ។

មិត្តរួមថ្នាក់និងមិត្តភ័ក្តិទាំងអស់ដែលបានជួយសម្រួលដល់ការស្រាវជ្រាវក៏ដូចជាជួយ ផ្តល់ជាគំនិតយោបល់ល្អដើម្បីឱ្យការស្រាវជ្រាវនេះទទួលបានលទ្ធផលជាផ្លែផ្កា។

# មាតិកា


មូលន័យសង្ខេប i

Abstract iii

វិចាររបស់គ្រូដឹកនាំ v

វិចាររបស់អ្នកស្រាវជ្រាវ vi

សេចក្តីថ្លែងអំណរគុណ vii

បញ្ជីអក្សរកាត់ x

ជំពូក ១៖ សេចក្តីផ្តើម 1

1.1 សាវតានៃការស្រាវជ្រាវ 1

1.2 ចំណោទបញ្ហា 2

1.3 គោលបំណងនៃការស្រាវជ្រាវ 7

1.4 គោលដៅនៃការស្រាវជ្រាវ 7

1.5 សំណួរស្រាវជ្រាវ 8

1.6 សារៈសំខាន់នៃការស្រាវជ្រាវ 8

1.7 និយមន័យប្រតិបត្តិនៃពាក្យគន្លឹះ 9

ជំពូក ២៖ ការសំយោគឯកសារពាក់ព័ន្ធ 11

2.1 ការពន្យល់បញ្ញត្តិ 11

2.1.1 សមត្ថភាពអំណាន 11

2.1.1.1 តាមន័យជាតិសព្ទ 11

2.1.1.2 តាមន័យបច្ចេកសព្ទ 12

2.1.1.3 តាមទស្សនៈផ្សេងៗ 12

2.2 បំណិនអំណាងទាំង៥ 14

2.3 របាយម៉ោងសិក្សា សមាសភាគនិងភាគរយម៉ោងសិក្សាមុខវិជ្ជាភាសាខ្មែរថ្នាក់ទី៧ 14

2.4 បញ្ហាប្រឈមនៃការអានតាមប្រទេសមួយចំនួន 15

2.5 វិធីសាស្ត្របង្រៀនដែលជំរុញការអានប្រកបដោយប្រសិទ្ធភាព 18

2.6 វត្ថុបំណងនៃសមត្ថភាពអំណាននៅកម្រិតមធ្យមសិក្សាបឋមភូមិ 20

2.7 ទម្លាប់នៃការអាននៅកម្ពុជា 21

ជំពូក ៣៖ វិធីសាស្ត្រនៃការស្រាវជ្រាវ 24

3.1 គម្រោងការស្រាវជ្រាវ 24

3.2 ទំហំសំណាក និងការជ្រើសំណាក 25

3.3 ឧបករណ៍សម្រាប់ការស្រាវជ្រាវ 27

3.4 នីតិវិធីនៃការប្រមូលទិន្នន័យ 28

3.5 ការវិភាគទិន្នន័យ 29

3.6 ក្រមសីលធម៌នៃការស្រាវជ្រាវ 30

3.7 វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ 31

ជំពូក ៤៖ លទ្ធផលនៃការស្រាវជ្រាវ 32

4.1 ទស្សនទានចំពោះសមត្ថភាពអំណានភាសាខ្មែរ 34

4.1.1 សមត្ថភាពអំណានភាសាខ្មែរ 34

4.1.2 ផ្នែកដែលសិស្សមានកម្សោយអំណាន 37

4.1.3 មូលហេតុនៃកម្សោយអំណាន 39

4.1.4 ទម្លាប់នៃអំណាន 42

4.1.4.1 ឥរិយាបថនៃទម្លាប់អាន 42

4.1.4.2 បញ្ហាប្រឈមនៃទម្លាប់អាន 45

4.1.4.3 វិធីសាស្ត្របណ្តុះទម្លាប់អាន 45

4.1.5 វត្ថុបំណងនៃសមត្ថភាពអំណាន 46

4.1.6 ដំណើរការនៃការបង្រៀនអំណាន 47

4.1.6.1 លំនាំនៃការបង្រៀនអំណានភាសាខ្មែរ 47

4.1.6.2 របៀបនៃការអនុវត្តអំណាន 48

4.2 នីតិវិធីដែលជួយលើកកម្ពស់អំណានភាសាខ្មែរ 49
4.2.1 នីតិវិធីដែលធ្លាប់អនុវត្តកន្លងមកក្នុងការលើកកម្ពស់អំណានភាសាខ្មែរ 49
4.2.2 នីតិវិធីដែលនឹងអនុវត្តបន្តដើម្បីលើកកម្ពស់អំណានភាសាខ្មែរ 52
ជំពូក ៥៖ ការពិភាក្សា 55
5.1 បញ្ហាប្រឈមនៃការអាន 55
5.2 លំនាំនៃការបង្រៀនដែលជំរុញការអានប្រកបដោយប្រសិទ្ធភាព 57
5.3 វត្ថុបំណងនៃការបង្រៀនសមត្ថភាពអំណាន 57
5.4 ឥរិយាបថនៃការអានរបស់សិស្ស 58
5.5 មូលហេតុចម្បងៗដែលសិស្សមិនមានទម្លាប់អាន 59
ជំពូក ៦៖ សន្និដ្ឋាន ដែនកំណត់នៃការស្រាវជ្រាវ និងសំណូមពរ 61
6.1 សេចក្តីសន្និដ្ឋាន 61
6.2 ដែនកំណត់នៃការស្រាវជ្រាវ 63
6.3 សំណូមពរ 63
6.4 សំណើសុំសម្រាប់ការសិក្សាបន្ត 63
ឯកសារយោង 70
ឧបសម្ព័ន្ធ កៈ កម្រងសំណួរ 73
ឧបសម្ព័ន្ធ ខៈ លិខិតស្នើសុំការស្រាវជ្រាវ 81

# បញ្ជីអក្សរកាត់

- អ.ក.ស: អ្នកចូលរួមក្រុមសិស្ស
- អ.ក.អា: អ្នកចូលរួមក្រុមអាណាព្យាបាល
- អ.ក.គ : អ្នកចូលរួមក្រុមគ្រូបង្រៀន
- អ.ក.ជំ : អ្នកចូលរួមក្រុមអ្នកជំនាញអក្សរសាស្ត្រខ្មែរ
- អ.ក.ស១: អ្នកចូលរួមជាសិស្សលំដាប់ទី១
- អ.ក.ស២: អ្នកចូលរួមជាសិស្សលំដាប់ទី២
- អ.ក.ស៣: អ្នកចូលរួមជាសិស្សលំដាប់ទី៣
- អ.ក.ស៤: អ្នកចូលរួមជាសិស្សលំដាប់ទី៤
- អ.ក.ស៥: អ្នកចូលរួមជាសិស្សលំដាប់ទី៥
- អ.ក.ស៦: អ្នកចូលរួមជាសិស្សលំដាប់ទី៦
- អ.ក.អា១: អ្នកចូលរួមជាអាណាព្យាបាលលំដាប់ទី១
- អ.ក.អា២: អ្នកចូលរួមជាអាណាព្យាបាលលំដាប់ទី២
- អ.ក.អា៣: អ្នកចូលរួមជាអាណាព្យាបាលលំដាប់ទី៣
- អ.ក.អា៤: អ្នកចូលរួមជាអាណាព្យាបាលលំដាប់ទី៤
- អ.ក.អា៥: អ្នកចូលរួមជាអាណាព្យាបាលលំដាប់ទី៥
- អ.ក.អា៦: អ្នកចូលរួមជាអាណាព្យាបាលលំដាប់ទី៦
- អ.ក.គ១: អ្នកចូលរួមជាគ្រូបង្រៀនលំដាប់ទី១
- អ.ក.គ២: អ្នកចូលរួមជាគ្រូបង្រៀនលំដាប់ទី២
- អ.ក.ជំ១: អ្នកចូលរួមជាអ្នកជំនាញអក្សរសាស្ត្រខ្មែរលំដាប់ទី១
- អ.ក.ជំ២: អ្នកចូលរួមជាអ្នកជំនាញអក្សរសាស្ត្រខ្មែរលំដាប់ទី២

# ជំពូក ១៖ សេចក្ដីផ្ដើម

## ១.១ សាវតានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលកំពុងអភិវឌ្ឍ។ ដូចនេះដើម្បីឈានដល់ប្រទេសដែលអភិវឌ្ឍនាពេលអនាគត រដ្ឋាភិបាលបានផ្ដល់ភាពសំខាន់ដល់វិស័យអប់រំដើម្បីបណ្ដុះបណ្ដាលធនធានមនុស្ស។ ក្នុងនោះដែរ ដើម្បីបណ្ដុះបាននូវធនធានមនុស្សត្រូវតែផ្ដល់តួនាទីសំខាន់នេះដល់គ្រូបង្រៀន។ ហេតុនេះ គ្រូបង្រៀនគឺជាជនគំរូដែលត្រូវចាប់ផ្ដើមធ្វើអ្វីៗដែលល្អមុនអ្នកណាៗទាំងអស់ ពោលគឺគ្រូបង្រៀនមានតួនាទីជាអ្នកអានសៀវភៅមុនសិស្ស។ ពេលណាគ្រូបានអានសៀវភៅមុនសិស្ស គឺនឹងមានគំនិតល្អៗបណ្ដុះស្មារតីដល់សិស្សបានផងដែរ។ ហើយទន្ទឹមនឹងនេះសិស្សរបស់គាត់នឹងទទួលបានឥទ្ធិពលល្អអំពីការអានសៀវភៅនេះ។ លើសពីនេះទៅទៀត អាណាព្យាបាលសិស្សក៏ជាចំណែកជំរុញឱ្យសិស្សចូលចិត្តការអាននិងមានសមត្ថភាពក្នុងការអានបានល្អផងដែរ។ ប៉ុន្តែជាអកុសល ប្រជាជនខ្មែរខ្លះក៏ដូចជាអ្នកសិក្សាមួយចំនួនធំមិនសូវចូលចិត្តអានសៀវភៅទេ វាបានក្លាយជាទម្លាប់ ហើយទម្លាប់នេះបានក្លាយទៅជាវប្បធម៌ទៅហើយ (លីម, ២០២០)។ ជាក់ស្ដែង ជាលទ្ធផលនៃការធ្វើតេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៨ រវាងឆ្នាំ២០១៥និង២០១៧បានបង្ហាញថា លទ្ធផលតេស្តនៃការសរសេរមានការប្រែប្រួលខ្លាំងកើនឡើង៩% នៅកម្រិតមូលដ្ឋាន ក៏ប៉ុន្តែ ៧១%នៃសិស្សដែលបានធ្វើតេស្តការសរសេរស្ថិតនៅក្រោមកម្រិតក្រោមមូលដ្ឋាន និងមិនមាន

ការប្រែប្រួលខ្លាំងក្នុងកម្រិតស្ទាត់ជំនាញនិងកម្រិតខ្ពស់ទេ។ ចំណែកតេស្តអំណានវិញ លទ្ធផលសិស្សមានការថយចុះ១០%នៅកម្រិតខ្ពស់និងកើនឡើង៧%នៅកម្រិតក្រោមមូលដ្ឋាន (MoEYS, 2019)។ មួយវិញទៀត យោងទៅតាមប្រសាសន៍របស់លោករដ្ឋមន្ត្រីអប់រំយុវជននិងកីឡា លោកបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុនបានលើកឡើងក្នុងឱកាសបើកកម្មវិធី"កុមាររៀន កុមារចេះ" ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ថាកុមារថ្នាក់ទី៣ប្រមាណ៥០%មិនអាចអានបានត្រឹមត្រូវ ហើយចំពោះសិស្សថ្នាក់ទី៧ប្រមាណពី៣០%ទៅ៤០% ខ្សោយក្នុងការអាននិងសរសេរដែលជាមូលហេតុនាំឱ្យពួកគេបោះបង់ចោលការសិក្សា ("Voacambodia", 2020)។

## ១.២ ចំណោទបញ្ហា

កត្តាចម្បងមួយក្នុងចំណោមកត្តាចម្បងជាច្រើនដែលនាំឱ្យលទ្ធផលសិក្សារបស់សិស្សធ្លាក់ចុះទាបគឺការខ្សោយការអានរបស់សិស្ស។ ការកត់សម្គាល់គឺត្រូវបានរកឃើញដោយគ្រូៗមួយចំនួននៅកម្រិតថ្នាក់មធ្យមសិក្សាបឋមភូមិនិងថ្នាក់មធ្យមសិក្សាទុតិយភូមិ។ ពួកគាត់ឃើញថាសិស្សរៀនកាន់តែខ្ពស់ហើយការអាននៅតែមានលក្ខណៈរដាក់រដុបមិនសូវស្គាល់ពាក្យពិបាកៗ។ ស្ថានភាពបែបនេះ ទោះបីជាចង់មិនចង់ ក៏គេត្រូវបន្ទោសលើមូលដ្ឋានគ្រឹះរបស់សិស្សនៅបឋមសិក្សាដែលសិស្សមានគ្រឹះមិនរឹងមាំ ហើយជាការព្រួយបារម្ភមួយដែលកូនខ្មែរខ្សោយភាសាជាតិ។ ហេតុផលដ៏គួរឱ្យចាប់អារម្មណ៍នេះគឺបញ្ហាមកពីកត្តាមួយចំនួនដែលជាការរួមចំណែកទទួលខុសត្រូវពីលោកគ្រូ អ្នកគ្រូ សង្គមបរិយាកាស និងសិស្សខ្លួនឯងផ្ទាល់ ("Rfi.fr.Cambodia", 2015)។

មួយវិញទៀត បើយោងតាមរបាយការណ៍ឆ្នាំ២០១៣របស់អង្គការសហប្រជាជាតិ(UNDP)ដែលបានឱ្យដឹងអំពីចំនួនមនុស្សដែលចេះអានអក្សរខ្ពស់បំផុតដល់ទៅ៩៩%នៃការប៉ាន់ស្មានក្នុងប្រទេសលើពិភពលោកបាន បង្ហាញថាប្រទេសកម្ពុជានៅលំដាប់ថ្នាក់ទី១៣៣ក្នុងចំណោម១៨២ប្រទេសដែលកម្រិតជាភាគរយអ្នកចេះអាននៅកម្ពុជា៧៦.៣០%។ ហើយ បើគិតក្នុងចំណោមប្រទេសដែលជាសមាជិកអាស៊ានទាំង១០វិញ ប្រទេសកម្ពុជាមានប្រជាជនចេះអានអក្សរច្រើនជាងប្រទេសឡាវតែមួយទេ ពោលគឺក្នុងចំណោម១០ប្រទេស កម្ពុជាជាប់លេខ៩ បើរាប់ពីលើចុះក្រោម (ប្រទេសដែលមានអ្នកចេះអានអក្សរច្រើនរាប់ដេញចុះមកកម្រិតទាបទៅប្រទេសដែលប្រជាជនចេះអានអក្សរថយចុះជាបន្តបន្ទាប់)។ ទិន្នន័យនេះសបញ្ជាក់ឱ្យដឹងថាសមត្ថភាពអំណានរបស់ប្រជាជនកម្ពុជានៅមានកម្រិតនៅឡើយបើធៀបនឹងប្រទេសទាំង១០ដែលជាសមាជិកអាស៊ាន។ ជាមួយគ្នានេះដែរ ប្រទេសកម្ពុជាបានចូលរួមក្នុងកម្មវិធីអន្តរជាតិស្ដីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលហៅកាត់ថាPISA-Dក្នុងឆ្នាំ២០១៦ជាមួយប្រទេសជាសមាជិកចំនួន៨ផ្សេងទៀត។ ជាលទ្ធផល PISA-Dបង្ហាញថាសមត្ថភាពលើផ្នែកអំណានសិស្សអាយុ១៥ឆ្នាំនៅកម្ពុជាគឺគិតជាមធ្យមមានសមត្ថភាពទាបជាងសិស្សនៅបណ្ដាលប្រទេសជាសមាជិតPISA-Dនិងប្រទេសជាសមាជិតអាស៊ាន ជាពិសេសទាបជាងប្រទេសដែលជាសមាជិកអង្គការOECD ពោលគឺពិន្ទុសរុបប្រហែល៧០០ពិន្ទុ លើផ្នែកអំណាន ប៉ុន្តែសិស្សនៅកម្ពុជាទទួលបាន៣២១ពិន្ទុដែលជាកម្រិតពិន្ទុទាបជាងសិស្សនៅក្នុងបណ្ដាលប្រទេសអាស៊ាន(៤៣០ពិន្ទុ)។ សរុបលទ្

ផលមកវិញជាភាគរយលើសមត្ថភាពអំណានរបស់សិស្សអាយុ១៥ឆ្នាំនៅកម្ពុជាប្រមាណ៨% មានសមត្ថភាពកម្រិតមូលដ្ឋាន(ម្រិតទី២)ឬលើកម្រិតមូលដ្ឋាន និង៣៨%មានសមត្ថភាពនៅកម្រិត១ក(PISA-D, 2018)។ អាស្រ័យហេតុនេះ ការអប់រំនៅកម្ពុជាទាមទារឱ្យមានកិច្ចខិតខំបន្ថែមទៀត។ រីឯតាមរយៈរបាយការណ៍តេស្តសមត្ថភាពសិស្ស ដែលឡើងពីថ្នាក់ទី៦ទៅថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំនៅដើមឆ្នាំសិក្សា២០១៩-២០២០ ទៅសមត្ថភាពអំណានបានបង្ហាញថា ក្នុងចំណោមសិស្សឡើងពីបឋមសិក្សាមករៀននៅអនុវិទ្យាល័យនេះមានចំនួនសរុបទាំងអស់១៣៩នាក់ ក្នុងនោះមានសិស្សអាចអានបានល្អចំនួន៤៩នាក់ បើគិតជាភាគរយគឺស្មើនឹង៣៥.២១% ហើយសិស្សអាចអានបានពីកម្រិតមធ្យមទៅល្អបង្គួរមានចំនួន៧១នាក់ដែលស្មើនឹង៥១.០៧% ហើយចំពោះសិស្សដែលខ្សោយការអានឬអត់ចេះអានតែម្តងនោះមានចំនួន១៩នាក់ បើគិតជាភាគរយគឺស្មើនឹង១១.៥០%។ បើយើងធ្វើការប្រៀបធៀបទិន្នន័យ ដែលបានមកពីសាលាអនុវិទ្យាល័យស្វាយរលំទៅនឹងរបាយការណ៍របស់PISA-D នោះយើងនឹងឃើញថាភាគរយនៃសិស្សដែលខ្សោយការអានមានកម្រិតប្រហាក់ប្រហែលគ្នា ពោលគឺស្ថិតនៅក្នុងរង្វង់ពី៨%ទៅ១០%។ ក្រោយពីបានពិនិត្យមើលលើភាគរយដែលសិស្សខ្សោយការអាននេះរួមមក យើងអាចនិយាយបានថាចំនួននោះវាតិចតួចទេ ប៉ុន្តែបើយើងបណ្តោយវាឱ្យបន្តកើតឡើង ដោយមិនចាត់ទុកវាថាជាបញ្ហាទេ នោះនៅពេលអនាគត សិស្សខ្មែរប្រាដកជាប្រឈមនឹងបញ្ហាមិនចេះអានឬសរសេរភាសាជាតិខ្លួនជាក់ជាមិនខាន។ អាស្រ័យហេតុនេះ យើងជាអ្នកអប់រំក៏ដូចជាអ្នកស្នេហាអក្សរសាស្ត្រជាតិត្រូវតែធ្វើការពិនិត្យរកដើមចមណាខ្លះដែល

បណ្តាលឱ្យសិស្សខ្សោយការអាន ព្រមទាំងរកយុទ្ធសាស្ត្របែបណាដើម្បីជួយដល់ការអភិវឌ្ឍការអាន របស់ឱ្យមានលក្ខណៈកាន់តែប្រសើរឡើងជាលំដាប់។

បន្ថែមពីនេះទៅទៀត យោងតាមអនុក្រឹត្យលេខ១២០ អនក្រ.បក របស់រាជរដ្ឋាភិបាលធ្វើនៅ រាជធានីភ្នំពេញ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥បានកំណត់យកថ្ងៃទី១១ ខែមីនាជារៀងរាល់ឆ្នាំគឺជា ទិវាអំណាននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាព អាន និងការតែងនិពន្ធ រួមចំណែកការពារនិងពង្រឹងវប្បធម៌ខ្មែរ ដោយអ្នកស្រាវជ្រាវឃើញការយកចិត្ត ទុកដាក់លើអំណានបែបនេះ ទើបអ្នកស្រាវជ្រាវសម្រេចចិត្តសិក្សាអំពីបញ្ហានៃការអាននេះ។ ហើយ ចំពោះទិវាអំណាននេះទៀតសោត ក្រសួងអប់រំយុវជន និងកីឡាមានភារកិច្ចក្នុងការរៀបចំជាទៀង ទាត់រាល់មួយឆ្នាំម្តង បើសរុបមកដល់ពេលនេះ ខាងក្រសួងបានប្រារព្ធឡើងចំនួនប្រាំមួយលើករួចមក ហើយ និងស្ថិតក្រោមប្រធានបទដែលប្រកបដោយអត្ថន័យខ្លឹមសារបង្កប់នូវការអប់រំទាក់ទងនឹង អំណានដូចជា (១) បណ្តុះទម្លាប់អានជំរុញវប្បធម៌អាន (២) អានដើម្បីភាពសុខដុមនៃជីវិត (៣) អំណានជា កំណាប់វិជ្ជាមហាសាល (៤) ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត (៥) ការអានបណ្តុះបញ្ញា ការ ស្រាវជ្រាវ និងនវានុវត្តន៍ និង(៦) អំណានក្នុងបរិបទកូវីដ ។ ពិសេសជាងនេះទៅទៀត តាមទិន្នន័យនៃ សិស្សបោះបង់ការសិក្សានៅកម្ពុជា ឆ្នាំ២០១១ បានបង្ហាញថាចំនួនសិស្សបោះបង់ច្រើននៅពេលពួក គេប្តូរភូមិសិក្សា ពោលគឺនៅថ្នាក់ទី៧ ទី៩ និងទី១២ ។ អាស្រ័យហេតុនេះ ការស្រាវជ្រាវពីប្រធានបទ សមត្ថភាពអំណាននៅថ្នាក់ទី៧នេះ វាជួយឱ្យយើងឃើញកាន់តែច្បាស់ពីឥទ្ធិពលនៃអំណានភាសា

ខ្មែរនៅមធ្យមសិក្សាបឋមភូមិ ដែលវាស្របនឹងរដ្ឋធម្មនុញ្ញនៅកម្ពុជា មាត្រា៦៨បានបង្ហាញថាប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ(ការវាស់ស្ទង់អនក្ខរកម្មនៅកម្ពុជាបញ្ចប់ត្រឹមថ្នាក់ទី៩)។

ទោះបីជាមានការសិក្សាស្រាវជ្រាវមួយចំនួនស្តីពីសមត្ថភាពនៃការអានភាសាខ្មែរក្តី ប៉ុន្តែមូលហេតុនៃកម្សោយការអានភាសាខ្មែរនៅកម្រិតអនុវិទ្យាល័យនៅមិនធ្លាប់មាននរណាបានសិក្សាកន្លងមកទេ។ នេះហើយជាចន្លោះប្រហោងដែលគេមិនបានយកចិត្តទុកដាក់។ ដូច្នេះវាជាភាពចាំបាច់ត្រូវធ្វើការសិក្សាលើប្រធានបទនេះ ដើម្បីស្វែងរកកត្តាដែលនាំឱ្យសិស្សខ្សោយការអានភាសាកំណើតខ្លួន ទោះបីពួកគេរៀនដល់កម្រិតអនុវិទ្យាល័យទៅហើយក្តី។ នៅឆ្នាំ២០១៥ អង្គការ UNESCOបានធ្វើការសិក្សាមួយស្តីពីអំណាននិងសំណេរដំបូងនៅកម្រិតបឋមសិក្សាក្នុងប្រទេសកម្ពុជា។ វត្ថុបំណងក្នុងការសិក្សានេះគឺពិនិត្យមើលជំហានដែលបានអនុវត្តក្នុងការអាននិងការសរសេរនៅកម្រិតដំបូង ដើម្បីឈានដល់ការអភិវឌ្ឍសៀវភៅសិក្សាគោល និងសៀវភៅគ្រូដែលពាក់ព័ន្ធនិងវិធីសាស្ត្រ និងទស្សនៈរបស់អ្នកប្រើប្រាស់សៀវភៅនេះ។ មួយវិញទៀត លោក Chhourn Bun Hoeun (2010) គាត់បានធ្វើការសិក្សាលើប្រធានបទមួយដែលមានចំណងជើងថាសមត្ថភាពនៃការអានរបស់សិស្សថ្នាក់ទី៦នៅសាលាបឋមសិក្សាជនបទបីក្នុងខេត្តកំពង់ធំ។ ហើយការស្រាវជ្រាវនេះចង់ដឹងពីកត្តាមួយចំនួនដែលបណ្តាលឱ្យសិស្សថ្នាក់ទី៦នៅសាលាបឋមសិក្សាជនបទទាំងបីទទួលបានលទ្ធផលនៃការអានបានល្អឬមិនល្អ។ ទន្ទឹមនឹងនេះ ការសិក្សាលើទស្សនៈរបស់សិស្សនិងគ្រូចំពោះកត្តាដែលជះឥទ្ធិពលលើទម្លាប់ក្នុងការអានរបស់សិស្សកម្ពុជានៅថ្នាក់វិទ្យាល័យ ដែលករណីសិក្សានៅវិទ្យាល័យ

ហ៊ុនសែន កោះចិន។ អ្នកស្រាវជ្រាវលើប្រធានបទនេះមកសិក្សាក្នុងគោលបំណងរកឱ្យឃើញនូវកត្តាទាំងឡាញដែលបានជះឥទ្ធិពលលើទម្លាប់ក្នុងការអានរបស់សិស្សនៅវិទ្យាល័យហ៊ុនសែន កោះចិន(Phang,2018)។ លើសពីនេះមានការសិក្សាមួយទៀតបានសិក្សាពីកត្តាជួយជំរុញការអាន និងសរសេររបស់សិស្សថ្នាក់ទី៧ ហើយគោលបំណងនៃការសិក្សាគឺព្យាយាមសិក្សាស្រាវជ្រាវស្វែងរកកត្តាទាំងឡាយដែលស្តែងចេញតាមរយៈអាណាព្យាបាលសិស្ស គ្រូបង្រៀនថ្នាក់ទី៧ និងសិស្សថ្នាក់ទី៧ក្នុងការរកឱ្យឃើញពីកត្តានានាដែលជួយជំរុញដល់ការអាននិងការសរសេររបស់សិស្សនៅថ្នាក់ទី៧ (Savuth, 2011)។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះគឺ រកឱ្យឃើញពីមូលហេតុទាំងឡាយដែលនាំឱ្យសិស្សខ្សោយការអានភាសាខ្មែរនៅថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំ ព្រមទាំងចង់លើកកម្ពស់សមត្ថភាពអានភាសាខ្មែរដល់សិស្សឱ្យបានប្រសើរឡើង។

## ១.៤ គោលដៅនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះផ្តោតលើពីរចំណុច គឺ ការស្រាវជ្រាវទៅលើទស្សនៈរបស់គ្រូនិងសិស្សអំពីមូលហេតុដែលធ្វើឱ្យមានកម្សោយនៃការអាន និងការស្រាវជ្រាវទៅលើទស្សនៈរបស់អាណាព្យាបាល

សិស្សអំពីមូលហេតុដែលធ្វើឱ្យកូនគាត់ខ្សោយការអាន។ មួយវិញទៀត គោលដៅនៃការស្រាវជ្រាវនេះនឹងកំណត់ពីវិធីសាស្ត្រនានាដែលជួយលើកកម្ពស់ដល់ការអានរបស់សិស្សផងដែរ។

## ១.៥ សំណួរស្រាវជ្រាវ

ដើម្បីសម្រេចបាននូវគោលបំណងរបស់ប្រធានបទស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់នូវសំណួរស្រាវជ្រាវពីរសំខាន់ៗដូចខាងក្រោមៈ

១) តើភាគីពាក់ព័ន្ធមានទស្សនៈយល់ឃើញដូចម្តេចចំពោះអំណានរបស់សិស្សថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំលើមុខវិជ្ជាភាសាខ្មែរ?

២) តើគ្រូ អាណាព្យាបាលរបស់សិស្ស និងអ្នកជំនាញត្រូវធ្វើដូចម្តេចដើម្បីឱ្យសិស្សទទួលបានលទ្ធផលល្អក្នុងការអានភាសាខ្មែរ?

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សានេះបានផ្តល់ការសំខាន់ណាស់ដល់គ្រូបង្រៀនភាសាខ្មែរគ្រប់រូបឱ្យបានយល់ច្បាស់ពីមូលហេតុនៃកម្សោយការអានភាសាខ្មែររបស់សិស្ស ហើយពួកគាត់អាចពិចារណាលើវិធីសាស្ត្របង្រៀនថ្មីៗបន្ថែមទៀត ដើម្បីអនុវត្តយ៉ាងណាឱ្យការអានរបស់សិស្សទទួលលទ្ធផលល្អក្នុងការសិក្សាអំណាន។ ហើយវាក៏មានសារៈសំខាន់ផងដែរ ចំពោះនាយកសាលា ពីព្រោះនៅពេលដែលគាត់បានជ្រាបពីបញ្ហានៃកម្សោយការអានភាសាខ្មែររបស់សិស្ស គាត់អាចយកវា

ទៅពិចារណាឬរៀបចំកម្មវិធីសិក្សាផ្សេងៗទៀតបន្ថែមលើកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំដែលបានកំណត់មក ដើម្បីជួយជំរុញឱ្យការអានរបស់សិស្សល្អប្រសើរ។ ជាមួយគ្នានេះដែរ អាណាព្យាបាលសិស្សក៏ជាអ្នកទទួលប្រយោជន៍ពីការសិក្សានេះផងដែរ ពោលគឺបន្ទាប់ពីរកឃើញអំពីមូលហេតុនៃការខ្សោយការអានកូនរបស់ពួកគាត់ ពួកគាត់ត្រូវតែពិចារណាកំណត់ពេលវេលាខ្លះ ដើម្បីជួយកូនរបស់ពួកគាត់ទៅលើការអាននៅផ្ទះផងដែរ ពីព្រោះការសិក្សារបស់សិស្សមិនអាចពឹងផ្អែកតែលើការបង្រៀនរបស់គ្រូតែម្យ៉ាងនោះទេ គឺត្រូវការចាំបាច់មានការចូលរួមសហការពីសំណាក់អាណាព្យាបាលរបស់សិស្ស។ ពិសេសជាងនេះទៅ ការសិក្សានេះបានពញ្ញាក់អារម្មណ៍ដល់អ្នកសិក្សាទូទៅឱ្យយល់ច្បាស់តម្លៃនៃភាសាខ្មែរជាតិរបស់ខ្លួន ឈប់គិតថាវាងាយស្រួលក្នុងការសិក្សាទៀត ពីព្រោះគ្រាន់ការអានភាសាខ្លួនក៏អ្នកសិក្សាជួបបញ្ហានៅឡើយ។ ដូចនេះ ការសិក្សានេះអាចបណ្តុះស្មារតីអ្នកសិក្សាគ្រប់រូប ជាពិសេសក្មេងៗឱ្យស្រឡាញ់ចូលចិត្តការអានភាសាជាតិខ្លួន។

## ១.៧ និយមន័យប្រតិបត្តិនៃពាក្យគន្លឹះ

មុននឹងឈានចូលដល់ការបន្យល់បកស្រាយលើប្រធានបទនិងការពិភាក្សាវែកញែកទៅលើលទ្ធផលនៃការសិក្សានេះ យើងគួរតែងឈ្វេងយល់ពីអត្ថន័យនៃពាក្យគន្លឹះរបស់ប្រធានបទនេះជាមុនសិន។ ពាក្យគន្លឹះក្នុងប្រធានបទនេះមានពាក្យ សមត្ថភាពអំណាន និងអនុវិទ្យាល័យ។

សមត្ថភាពអំណានគឺសំដៅលើការដែលសិស្សអាចអានបាននូវពាក្យពេចន៍ដែលងាយៗនិង ពិបាកៗ ហើយអាចអានអត្ថបទបានទៅយ៉ាងរលូន លើកដាក់សំឡេងបានត្រឹមត្រូវ ព្រមទាំងយល់ខ្លឹមសារអត្ថបទបានយ៉ាងស៊ីជម្រៅទៀតផង។

អនុវិទ្យាល័យសំដៅលើកម្រិតនៃថ្នាក់សិក្សាត្រឹមថ្នាក់ទី៧ដល់ទី៩។ ហើយវានៅចន្លោះកម្រិតរវាងបឋមសិក្សានិងវិទ្យាល័យ។

សរុបមក ប្រធានបទនេះមានបំណងសិក្សាស្រាវជ្រាវពីការយល់ឃើញរបស់សិស្ស គ្រូ និងអាណាព្យាលបាល ទៅលើការដែលសិស្សអាចអានបាននូវពាក្យពេចន៍ដែលងាយៗ និងពិបាកៗ ហើយអាចអានអត្ថបទបានទៅយ៉ាងរលូន លើកដាក់សំឡេងបានត្រឹមត្រូវ ព្រមទាំងយល់ខ្លឹមសារអត្ថបទបានយ៉ាងស៊ីជម្រៅទៀតផង។ នៅកម្រិតសិក្សាថ្នាក់ទី៧។

# ជំពូក ២៖ រំលឹកទ្រឹស្ដី

នៅក្នុងជំពូកនេះពិភាក្សានិងបង្ហាញអំពីទ្រឹស្ដីមួយចំនួនដែលពាក់ព័ន្ធទៅនឹងនិយមន័យរបស់អំណាន បំណិននិងវត្ថុបំណងនៃការបង្រៀនសមត្ថភាពអំណានៅមធ្យមសិក្សាបឋមភូមិ ព្រមទាំងបង្ហាញឱ្យឃើញពីរបាយម៉ោងសិក្សា សមាសភាព និងភាគរយម៉ោងសិក្សាមុខវិជ្ជាភាសាខ្មែរថ្នាក់ទី៧។ បន្ថែមពីនេះទៀត នៅក្នុងជំពូកនេះដដែល ក៏ធ្វើការពិភាក្សាលើវិធីសាស្ត្រនានាក្នុងការបង្រៀនសមត្ថភាពអំណានឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ បញ្ហាប្រឈមនៃការអានតាមប្រទេសមួយចំនួន និងបង្ហាញពីទម្លាប់អានរបស់អ្នកសិក្សានៅកម្ពុជាផងដែរ។

## ២.១ ការពន្យល់បញ្ញត្តិ

### ២.១.១ សមត្ថភាពអំណាន

#### ២.១.១.១ តាមន័យជាតិសព្ទ

សមត្ថភាពអំណាន< សមត្ថភាព+អំណាន

បើតាមវចនសព្ទដែលបានពន្យល់នៅក្នុងវចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាតដែលបានបោះពុម្ពឆ្នាំ១៩៦៧ លោកបានកំណត់និយមន័យរបស់ពាក្យ សមត្ថភាព ថាភាពនៃសេចក្ដីអាចហ៊ាន, សេចក្ដីមោះមុត។ រីឯពាក្យថា អំណាន ជាពាក្យកម្លាយមកពីពាក្យ"អាន" ថ្នាក់ពាក្យជាកិរិយាសព្ទដែលមានន័យថាមើលតាមអក្សរ។ រួចនៅពេលកម្លាយទៅជានាមសព្ទ"អំណាន"

ដែលមានន័យថាការមើលថាតាមអក្សរ។

សរុបមក សមត្ថភាពអំណានមានន័យថាសេចក្តីដែលអាចហ៊ានមើលហើយថាតាមអក្សរបានត្រឹមត្រូវ។

### ២.១.១.២ តាមន័យបច្ចេកសព្ទ

បើតាមបច្ចេកសព្ទ ពាក្យសមត្ថភាពអំណានសំដៅលើ៖

> ឥរិយាបថវិជ្ជមានក្នុងការអានប្រកបដោយប្រសិទ្ធភាព អានស្ទាត់ ចេះលើកដាក់សំឡេង ចេះគោរពសញ្ញាសម្គាល់ មានទឹកមុខ កាយវិការសមរម្យ យល់ដឹងរបៀបអានដើម្បីកំណត់បានខ្លឹមសារនិងរបៀបរកព័ត៌មានក្នុងការចងចាំ យល់ន័យ អនុវត្តវិភាគ វាយតម្លៃនិងបង្កើតថ្មី ដោយឆ្លើយទៅនឹងសំណួរ អ្វី នរណា ឯណា ពេលណា ដូចម្តេច ហេតុអ្វី (MOEY, 2018, p. 71)។

### ២.១.១.៣ តាមទស្សនៈផ្សេងៗ

ការអានគឺជាដំណើរការមួយដែលចាប់ផ្តើមជាមួយការបកស្រាយអក្សរដែលការបកស្រាយអក្សរទាំងនោះជាការបង្កើតឱ្យមានជារូបរាងពាក្យមួយផ្ទាល់របស់វា។ ការអានមួយដែលល្អ នោះគឺតម្រូវឱ្យយើងជាអ្នកអានត្រូវចេះរៀបចំទំនាក់ទំនងរវាងតួអក្សរនីមួយៗជាមួយនឹងសំឡេង ហើយចេះដាក់វាបញ្ចូលគ្នាដោយអនុលោមតាមអត្ថន័យរបស់អត្ថបទ (ស្មៀវ, ២០០៦

as cited in សុផល, ២០១២)។ រីឯSmithនិងRobinson (1980) បានកំណត់ន័យការអានថាជាសកម្មភាពប្រឹងប្រែងមួយរបស់អ្នកអានដើម្បីយល់ដឹងពីសាររបស់អ្នកសរសេរ។ ហើយ តាមរយៈ Toit (2001) បានបង្ហាញថាការអានគឺជាដំណើរការមួយនៃការគិត ការនឹកឃើញវិញ និងការពាក់ព័ន្ធបញ្ញត្តិច្រើន ដែលស្ថិតក្រោមមុខងារនៃពាក្យជាច្រើនក្នុងការសរសេរលាយលក្ខណ៍អក្សរ។

តាមរយៈ De Naeghel, Van keer, Van steenkiste និង Rosseel (2012), "សមត្ថភាពនៃការអានគឺជាសារប្រយោជន៍មួយ ហើយវាពិតជាជំនាញមួយដ៏សំខាន់ផងដែរ។" ជាមួយគ្នានេះដែរ Chhabra និង Mc Cardle (2004) បានបង្ហាញថាសមត្ថភាពក្នុងការអានកំណត់នូវឱកាសការងារនាពេលអនាគត និងជាសារៈសំខាន់សម្រាប់ការសម្រេចបាននូវលទ្ធផលសិក្សា។ ហើយសមត្ថភាពអំណានគឺជាដំណើរការដ៏ស្មុគស្មាញមួយដែលជំនាញដទៃទៀតត្រូវតែប្រើប្រាស់វា(Cain et al,2004)។ ទន្ទឹមនឹងនេះ មានអ្នកស្រាវជ្រាវបីនាក់គឺ Palincsar, Brown និង Samuels បានគូសបញ្ជាក់ស្រដៀងគ្នាថាសមត្ថភាពនៃការអានបានជះឥទ្ធិពលទៅលើកត្តាជាច្រើន ហើយកត្តាទាំងនោះគឺទាក់ទងនឹងអត្ថបទ បរិបទ ការងារ និងអ្នកអាន( Mubashir, Bahram, Mehswish & Frakarh, 2015)។ មួយវិញទៀត វាក្យសព្ទ គឺជាកត្តាសំខាន់មួយក្នុងចំណោមកត្តាសំខាន់ជាច្រើនដែលជះឥទ្ធិពលដល់សមត្ថភាពនៃការអាន( Nagy, 1998 as cited in Mubashir et al, 2015)។

## ២.២ បំណិនអំណានទាំង៥

ដើម្បីបង្រៀនកុមារឱ្យសម្រេចគោលដៅនៃការអានជាសកល គឺការអនុវត្តបំណិនអំណានទាំងប្រាំរួមមាន៖ ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ ការចេះវាក្យសព្ទ ការចេះអានស្ទាត់ និងការអានដើម្បីយល់ន័យ។ ហើយចំពោះការស្គាល់សូរ សំដៅលើការបង្រៀនឱ្យសិស្សមានសមត្ថភាពកំណត់ ប្រើប្រាស់ និងញែកសូរក្នុងពាក្យ។ រីឯ ការស្គាល់តួអក្សរនិងសូរ សំដៅលើការបង្រៀនឱ្យសិស្សយល់និអនុវត្តចំណេះដឹងស្ដីពីទំនាក់ទំនងរវាងតួអក្សរនិងសូរ។ ចំណែកការចេះវាក្យសព្ទ សំដៅដល់ការបង្រៀនឱ្យសិស្សមានចំណេះដឹងស្ដីពីពាក្យ ដោយរាប់ទាំងពាក្យប្រើប្រាស់ផ្ទាល់ខ្លួន និងពាក្យសរសេរដូចជាតាមរយៈការស្គាល់ពាក្យតាមរយៈការឮ និងឃើញ ការមើលឬអាន។ ហើយ ចំពោះការចេះអានស្ទាត់ គឺសំដៅការបង្រៀនដែលជួយពង្រឹងដល់សមត្ថភាពអានឮដោយមានល្បឿនច្បាស់លាស់ និងការបង្ហាញគំនិតត្រឹមត្រូវ។ បំណិនទី៥ចុងក្រោយនៃអំណាន គឺសំដៅការបង្រៀនដែលធ្វើឱ្យសិស្សមានសមត្ថភាពចូលរួមនិងបញ្ចេញន័យដោយប្រើពាក្យសម្ដីផ្ទាល់ខ្លួនពីអត្ថបទដែលបានអាន (MOEYS, 2016)។

## ២.៣ របាយម៉ោងសិក្សា សមាសភាគនិងភាគរយម៉ោងសិក្សាមុខវិជ្ជាភាសាខ្មែរថ្នាក់ទី៧

ការអនុវត្តម៉ោងបង្រៀនសម្រាប់មុខវិជ្ជាភាសាខ្មែរនៅកម្រិតថ្នាក់ទី៧ តម្រូវឱ្យគ្រូបង្រៀន

ក្នុងមួយសប្តាហ៍ ចំនួន៧ម៉ោង។ ហើយក្នុងមួយឆ្នាំសិក្សា កម្មវិធីសិក្សាតម្រូវឱ្យអនុវត្តម៉ោងបង្រៀន ចំនួន៣៥សប្តាហ៍។ ដូច្នេះ ចំនួនម៉ោងសរុបក្នុងមួយឆ្នាំសិក្សាមាន២៤៥ម៉ោង។ រីឯសមាសភាគនិងភាគរយម៉ោងសិក្សាមុខវិជ្ជាភាសាខ្មែរថ្នាក់ទី៧ ត្រូវបានបែងចែកដូចតទៅ៖ ម៉ោងសិក្សាសម្រាប់សមត្ថភាពស្តាប់ មានចំនួន១០% ម៉ោងសិក្សាសម្រាប់សមត្ថភាពនិយាយ មានចំនួន១០% ម៉ោងសិក្សាសម្រាប់សមត្ថភាពអំណាន មានចំនួន៣០% ម៉ោងសិក្សាសម្រាប់សមត្ថភាពសរសេរ មានចំនួន៣០% ម៉ោងសិក្សាសម្រាប់វេយ្យាករណ៍ មានចំនួន១០% និងម៉ោងសិក្សាសម្រាប់បំណិន មានចំនួន១០% (MOEYS, 2018)។

## ២.៤ បញ្ហាប្រឈមនៃការអានតាមប្រទេសមួយចំនួន

នៅក្នុងប្រទេសប៉ាគីស្ថាន សមត្ថភាពនៃការអានភាសាអង់គ្លេសរបស់សិស្សនៅថ្នាក់អនុវិទ្យាល័យនៅមានកម្រិតនៅឡើយ ហើយកត្តាដែលនាំឱ្យពួកគេមានកម្សោយសមត្ថភាពអំណានមកពីការយល់ដឹងលើវាក្យសព្ទតិចតួចពេក ការដែលរៀនសម្រុកសម្រាប់តែទុកប្រឡងដោយមិនបានរៀនឱ្យចេះយល់ដឹងបានពេញលេញ ការមានកម្សោយចំពោះការយល់ដឹងពីសំណង់ប្រយោគតាមកាលនីមួយៗនៃភាសាអង់គ្លេស ការមិនបានប្រើប្រាស់ទិចនិកដើម្បីឱ្យមានការពិចារណាលើបរិបទនៃអត្ថបទ និងការមិនមានទម្លាប់ក្នុងការអាន(Mubashir, Bahram, Mehswish & Fakharh, 2015)។ ចំពោះប្រទេសកម្ពុជាក៏មានការសិក្សាពីកម្សោយនៃការអាន

ភាសាអង់គ្លេសផងដែរ។ ក្នុងនោះលោក Dara(២០១៩) បានបង្ហាញថាកម្សោយការអានភាសាអង់គ្លេសរបស់សិស្សនៅកម្រិតវិទ្យាល័យដោយសារកត្តាដូចជា កង្វះការយល់ដឹងពីភាសា ខ្វះការលើកទឹកចិត្ត វិធីសាស្ត្រនៃការអាននៅមានកម្រិត កម្សោយលើការយល់ដឹងពីដំណើរការនៅការអាន និងចំណេះដឹងភាសាអង់គ្លេសក្នុងកម្រិតថ្នាក់មុនៗនៅមានកម្រិតនៅឡើយ។ លើសពីនេះទៅទៀត បញ្ហាប្រឈមដល់ការអានអត្ថបទរបស់សិស្សដែលនៅចន្លោះវ័យអាយុ១៥ឆ្នាំដល់១៧ឆ្នាំក្នុងព្រះរាជាណាចក្រម៉ារ៉ុកវិញ វាមកពីកត្តាដូចជា (១) សិស្សខ្វះការលើកទឹកចិត្តនិងការធ្វើឱ្យមានចំណាប់អារម្មណ៍ជាមូលដ្ឋានពីសំណាក់អ្នកអប់រំនិងអាណាព្យាបាល (២) មានភាពពិបាកជាមួយនឹងវាក្យសព្ទនិងវេយ្យាករណ៍ដែលមាននៅក្នុងអត្ថបទ (៣) សិស្សពុំមានទម្លាប់ក្នុងការអានប្រចាំថ្ងៃ រួមផ្សំនិងសាលារៀនរបស់ពួកគេពុំមានបណ្ណាល័យផងដែរ (៤) គ្រូបង្រៀនមិនដឹងពីវិធីសាស្ត្របង្រៀនណាខ្លះស៊ីគ្នានឹងការបង្រៀនសមត្ថភាពអំណានដែលវាអាចជួយឱ្យការបង្រៀនមានប្រសិទ្ធភាពនិងងាយស្រួលធ្វើសកម្មភាពឆាប់សម្រេចបាននូវសមត្ថភាពអំណាន (៥) ការមានបញ្ហាជាមួយនឹងសៀវភៅសិក្សាគោល ដោយវាមិនមានការបកប្រែដែលធ្វើឱ្យសិស្សចាប់អារម្មណ៍បាន និងការខ្វះខាតសម្ភារៈប្រើប្រាស់ក្នុងដំណើរការបង្រៀនដែលនាំឱ្យគ្រូប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបែបប្រពៃណី ហើយសិស្សទទួលក្នុងលក្ខណៈអសកម្ម(Ali & Ibrahim, 2019)។ ហើយ តាមរយៈYuan និង Anongkarat (២០២០) បានបង្ហាញថាបញ្ហាខ្សោយការអានរបស់សិស្សនៅប្រទេសថៃ វាទាក់ទងការមានទំនួលខុសត្រូវរបស់សាលាក្នុងការឱ្យ

តម្លៃលើការអាន ហើយការដែលមានទំនួលខុសត្រូវនេះមានប្រសិទ្ធភាពវិជ្ជមានលើសមត្ថភាពអាន។ ព្រមជាមួយគ្នានេះដែរ សកម្មភាពជួយជ្រោមជ្រែងបន្ថែមរបស់គ្រូជាកត្តាប្រយោលក្នុងការជំរុញឱ្យសាលារៀននិងសិស្សយល់ពីតម្លៃនៃការអាន។ មួយវិញទៀត បើក្រឡេកមើលមកកម្ពុជាវិញតាមរយៈការសែតអេឡិចត្រូនិកភ្នំពេញប៉ុស្តិ៍ (២០១៧) ក្រោមចំណងជើងថា ហេតុអ្វីបានជាកូនខ្មែរខ្លះ នៅតែប្រើភាសាខ្លួនមិនត្រូវជ្រុង? បានបង្ហាញថា បញ្ហាប្រើភាសាខ្មែរមិនត្រឹមត្រូវហ្នឹងគឺមកពីកត្តាខាងក្នុងប្រព័ន្ធអប់រំ និងកត្តាខាងក្រៅការអប់រំ។ នៅក្នុងប្រព័ន្ធអប់រំ គឺមានកត្តាពីគ្រូនិងសិស្សដោយពួកគេខ្វះការយកចិត្តទុកដាក់ក្នុងការរៀននិងការបង្រៀន។ ចំពោះកត្តាក្រៅការអប់រំមានដូចជាការដែលអាណាព្យាបាលសិស្សមួយចំនួនឱ្យកូនរៀនភាសាបរទេសមុនភាសាខ្មែរ ពោលគឺមិនបានផ្ដល់តម្លៃឱ្យដល់ភាសាជាតិខ្លួន ហើយគិតថាភាសាជាតិខ្លួនងាយស្រួល រៀនឆាប់ចេះ ប៉ុន្តែជាតុពិតគឺកូនៗពួកគេនិយាយភាសាខ្មែរអត់ច្បាស់ និងអ្នកខ្លះអត់ចេះសរសេរតែម្ដង។ មួយវិញទៀត គេសង្កេតឃើញថាពលរដ្ឋខ្មែរសឹងតែទូទៅហើយដែលមិនមានវប្បធម៌អំណាន សូម្បីតែភាសាខ្លួនឬការសែតស្គង់ដារភាសាខ្មែរក៏ខ្ជិលអានដែរ តែបែរមកចូលចិត្តឱ្យគេអានឱ្យស្ដាប់ឬក៏សំដែងឱ្យមើលទៅវិញ។ ម្យ៉ាងទៀត ការសរសេរកាសែតក្នុងស្រុកមានកំហុសច្រើនតាំងពីពាក្យនិងឃ្លាឃ្លោងភ្ជាប់សេចក្ដីពីមួយទៅមួយទៀត និយាយឱ្យចំគឺគ្មានអ្នកកែសម្រួលភាសាខ្មែរមុនចេញផ្សាយ។

## ២.៥ វិធីសាស្ត្របង្រៀនដែលជំរុញការអានប្រកបដោយប្រសិទ្ធភាព

នៅក្នុងសៀវភៅដែលសរសេរដោយ Sheaនិង Roberts (2016) បានបង្ហាញថាពួកគាត់ជឿជាក់ថាវិធីសាស្ត្រមួយដែលហៅជាអក្សរកាត់ក្នុងភាសាអង់គ្លេសថាFIVES។ សមាសធាតុនៃអក្សរកាត់ទាំងប្រាំនេះមានទំនាក់ទំនងយ៉ាងរឹងមាំក្នុងការអនុវត្តបន្តិចម្តងៗដើម្បីឱ្យការអានទៅដោយរលូន។ F ជាអក្សរកាត់នៃពាក្យពេញ Facts ដែលមានន័យថាការពិត ហើយវាឆ្លើយតបទៅនឹងជំហានដំបូងច្រើននៃជំនាញការគិតរបស់Bloom's taxonomy ។ ទន្ទឹមនឹងនេះ អ្នកនិពន្ធទាំងពីរបានសង្កត់លើសារៈសំខាន់នៃសមាសធាតុនេះពីព្រោះអ្នកអានគួរតែមានជំនាញសម្គាល់រវាងគំនិតសំខាន់ៗចេញពីគំនិតលម្អិត។ ជាអក្សរកាត់នៃពាក្យពេញ Inference ដែលវាក៏ជាផ្នែកមួយជំរុញឱ្យអ្នកអានមានជំនាញក្នុងការគិតជម្រៅបន្តិច។ ចំណូលចិត្តដែលអ្នកអានបង្កើតជាទំនាក់ទំនងមួយរវាងចំណេះដឹងនិងបទពិសោធន៍ជីវិតរបស់គាត់ទៅនឹងមាតិកាដែលបានបង្ហាញនៅក្នុងអត្ថបទ។ V ជាអក្សរកាត់នៃពាក្យពេញ Vocabulary ដែលមានវត្តមានក្នុងអត្ថបទ។ ហើយនៅក្នុងផ្នែកនេះមានរួមបញ្ចូលការយល់ដឹងអំពីវាក្យសព្ទផ្សេងគ្នារបស់អត្ថបទទាំងអស់ផងដែរ ពីព្រោះថាអាចមានការប្រើប្រាស់ពាក្យថ្មីខ្លះ ដូច្នេះការយល់ច្រឡំកើតឡើងប្រសិនបើការប្រើប្រាស់ពាក្យថ្មីមិនត្រូវបានស្ទាត់ជំនាញ។ E ជាអក្សរកាត់នៃពាក្យ Experiences ដែលសំដៅលើបទពិសោធ។ ដូចនេះ នៅពេលសិស្សឆ្លងកាត់ដំណាក់ការនៃភាពពិតដោយអានចាប់យកចំណុចសំខាន់ៗរបស់អត្ថបទ ហើយដំណាក់កាលមានចំណាប់អារម្មណ៍ចូលចិត្តលើអត្ថបទ រួចយល់ពី

វាក្យសព្ទនៃអត្ថបទហើយនោះ វាដល់ដំណាក់កាលដែលសិស្សអាចភ្ជាប់ទំនាក់ទំនងពីខ្លឹមសារនៃអត្ថបទទៅនឹងចំណេះដឹងមានស្រាប់របស់អ្នកអានហើយ។ S ជាអក្សរកាត់នៃពាក្យពេញ Summary ដែលនៅត្រង់ចំណុចនេះ ប្រសិនបើសិស្សអាចយល់ពីខ្លឹមសារនៃអត្ថបទនេះបានច្បាស់លាស់ វាបានន័យថាសិស្សអាចយល់ពីខ្លឹមសារនៃអត្ថបទនោះបាន។ នៅក្នុងបរិបទនេះ ក៏មានអ្នកស្រាវជ្រាវដទៃទៀតបានសិក្សាពីវិធីសាស្រ្តបង្រៀនសមត្ថភាពអំណានឱ្យឆាប់ទទួលបានប្រសិទ្ធភាពផងដែរ។ នៅក្នុងសៀវភៅមួយដែលសរសេរដោយLinda Hoyt (2009) គាត់បានបញ្ជាក់ថាវិធីសាស្រ្តបង្រៀនសមត្ថភាពឱ្យឆាប់ទទួលបានប្រសិទ្ធភាពគឺប្រើវិធីសាស្រ្តបង្រៀនមួយដែលមានឈ្មោះថា "Super six"ដែលក្នុងនោះរួមមានការភ្ជាប់ទំនាក់ទំនង ការស្មានទុកមុន ការសាកសួរ ការត្រួតពិនិត្យ ការមើល និងការសង្ខេប។ បន្ថែមពីនេះទៀត ការបង្រៀនការអានឱ្យយល់ច្បាស់ វាក៏ទាក់ទងនឹងបច្ចេកទេសនៅពេលដែលបង្រៀនផងដែរ។ ចាប់ផ្ដើមបង្រៀនដោយការបង្រៀនវាក្យសព្ទទៅកាន់សិស្ស ពីព្រោះវាធ្វើឱ្យសិស្សយល់ពាក្យសំខាន់ៗដែលជួយសម្រួលដល់ការយល់ដឹងពីខ្លឹមសាររបស់អត្ថបទ។ បន្ទាប់មក ការទស្សន៍ទាយជាបច្ចេកទេសទី២ដែលគ្រូប្រើដើម្បីធ្វើឱ្យចំណេះដឹងមានស្រាប់សកម្ម និងដើម្បីបង្កើតជាស្ពានតភ្ជាប់រវាងកត្តាភាសាវិទ្យានៃអត្ថបទទៅនឹងសមាសភាគនៃភាសាវិទ្យារបស់វា ។ បន្ទាប់មកទៀត យុត្តិសាស្រ្តរងនៃការអានដែលជួយឱ្យសិស្សឈានដល់ចំណុចចាប់ផ្ដើមនៃការអានគឺSkimming(ការអានត្រួតៗដើម្បីដកស្រង់ចំណុចសំខាន់ៗរបស់អត្ថបទ) ហើយយុត្តិសាស្រ្តរងកម្រិតខ្ពស់ដែលពាក់ព័ន្ធនឹង

ការធ្វើឱ្យមានការតភ្ជាប់លម្អិតនិងបង្ហាញការយល់ដឹងកម្រិតខ្ពស់នៃអត្ថបទដោយអាចទាញយកព័ត៌មានលម្អិតនិងអាចធ្វើលំហាត់បាននោះគឺScanning(ការអានដោយយកចិត្តទុកដាក់គ្រប់ពាក្យ គ្រប់ឃ្លាប្រយោគរបស់អត្ថបទដើម្បីទទួលបានសេចក្ដីលម្អិត) (Ali & Ibrahim, 2019)។

## ២.៦ វត្ថុបំណងនៃសមត្ថភាពអំណាននៅកម្រិតមធ្យមសិក្សាបឋមភូមិ

កម្មវិធីភាសាខ្មែរនៅមធ្យមសិក្សាបឋមភូមិ ធានាឲ្យសិស្សមានសមត្ថភាពអាចប្រើប្រាស់ភាសា ក្នុងគមនាគមន៍គំនិតបានត្រឹមត្រូវ តាមតម្រូវការជីវភាពសង្គម ។ តាមរយៈការបណ្ដុះបណ្ដាលសមត្ថភាពទាំងបួន កម្មវិធីនេះត្រូវផ្ដល់បំណិនគ្រប់គ្រាន់ដើម្បីបង្កលក្ខណៈងាយស្រួល ឱ្យសិស្សអាចយល់បានល្អនូវមេរៀនមុខវិជ្ជាដទៃទៀតនៃកម្មវិធីសិក្សា ។ ទន្ទឹមនឹងនេះ បណ្ដុះគំនិត ស្មារតីច្នៃប្រឌិត សីលធម៌ បុគ្គលិកលក្ខណៈ សុខភាព ដើម្បីឱ្យសិស្សក្លាយជាពលរដ្ឋមានសមត្ថភាពចូលរួមក្នុងការអភិវឌ្ឍសង្គម ។ហើយចំពោះសមត្ថភាពអំណាននៅកម្រិតនេះ មានបំណងបណ្ដុះសិស្សដូចជាៈសិស្សមានចំណង់ចំណូលចិត្តក្នុងអំណាន អានយល់អត្ថបទពាក្យរាយ កាព្យ ពណ៌នា និទាន និងពន្យល់ ចេះអានធ្វើបទមូលដ្ឋាន ចេះអានលឺ តាមបែបបទសមស្រប តាមស្ថានភាព អានខ្សឹប អានត្រួសៗ ច្បោលៗ ដកស្រង់គំនិតសំខាន់របស់អត្ថបទ និងព្យាករណ៍ទំនាក់ទំនងក្នុងលំដាប់ ស្គាល់ពាក្យបាលី សំស្ក្រឹត បច្ចេកទេស អក្សរសិល្ប៍ និងកំណត់ន័យពាក្យតាមទីសេចក្ដី ហើយយល់ក្បួនបង្កើតពាក្យ ចេះបកស្រាយរូបភាពដ្យាក្រាម ផែនទី ...និងចេះដកស្រង់បទពិសោធអក្សរសិល្ប៍ ជាគុណប្រយោជន៍នៃជីវភាពរស់នៅបច្ចុប្បន្ន(MoEYS, 2018)។

## ២.៧ ទម្លាប់នៃការអាននៅកម្ពុជា

តាមរយៈការសិក្សាស្រាវជ្រាវមួយរបស់Hay (2017)បានបង្ហាញពីទម្លាប់ក្នុងការអានរបស់សិស្សនៅថ្នាក់មធ្យមសិក្សាថា សិស្សនៅកម្រិតនេះនៅតែមានទម្លាប់អានទាប ដោយចំណាយពេលប្រហែលជាមួយម៉ោងឬតិចជាងនេះក្នុងមួយថ្ងៃ។ ហើយពួកគេភាគច្រើនអានពីចំណេះដឹងទូទៅ បច្ចេកវិទ្យារឿងប្រឌិត(ជីវិតរបស់មនុស្សល្បីៗនៅជុំវិញពិភពលោក) និងរឿងប្រឌិតជាដើម ហើយភាសាខ្មែរនៅតែជាភាសាដែលសិស្សចូលចិត្តអានជាងគេ។ ជាមួយគ្នានេះ សិស្សបានគិតថាបណ្ណាល័យជាកន្លែងដែលមានសៀវភៅច្រើន ប៉ុន្តែពួកគេមិនបានទៅបណ្ណាល័យញឹកញាប់ទេ ពីព្រោះពួកគេមានការប្តេជ្ញាទាបក្នុងការអានសៀវភៅបណ្ណាល័យបើកនៅចំពេលម៉ោងដែលគេកំពុងសិក្សា ហើយបណ្ណាល័យនៅសាលាខ្លះមិនបានបើកជាប្រចាំទេ និងមានការខ្វះខាតសម្ភារៈអានផងដែរ។ លើសពីនេះទៀត ផ្ទះគឺជាកន្លែងដែលមានផាសុកភាពបំផុតសម្រាប់ការអាន ហើយវាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការរៀបចំកន្លែងអាននៅផ្ទះ។ ឪពុកម្តាយ បងប្អូន មិត្តភក្តិ និងគ្រូគឺជាដៃគូអានដ៏សំខាន់សម្រាប់សិស្ស។ មួយវិញទៀត នៅក្នុងយុគសម័យបច្ចេកវិទ្យានេះគឺមិនអាចចៀសផុតបានសម្រាប់មនុស្ស ជាពិសេសក្មេងជំទង់ក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដូចនេះអាណាព្យាបាល និងលោកគ្រូអ្នកគ្រូត្រូវចេះណែនាំពួកគេឱ្យទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យាទាំងនោះសម្រាប់ការកម្សាន្តផងនិងរៀនសូត្រផង។ ទន្ទឹមនឹងនេះ តាមរយៈការសិក្សាបានបង្ហាញបន្ថែមទៀតថា ការអាននៅតែមិនមែនជា

សកម្មភាពប្រចាំថ្ងៃទូទៅ និងមិនត្រូវបានផ្តល់ជាអាទិភាពបើប្រៀបធៀបទៅនឹងការមើលទូរទស្សន៍ ដូច្នេះឪពុកម្តាយត្រូវកំណត់ច្បាប់មូលដ្ឋានដើម្បីកំណត់ពេលវេលានៃការមើលទូរទស្សន៍ និងកំណត់ពេលខ្លះសម្រាប់កូនៗរបស់ពួកគេក្នុងការអាន។ អ្វីដែលពិសេសជាងនេះទៅទៀត យកល្អពួកគេអាចគ្រប់គ្រងពេលវេលាដើម្បីអានជាមួយកូននិងជួយពួកគេឱ្យអាន។

រីឯការសិក្សាមួយទៀត អ្នកស្រាវជ្រាវបានផ្តោលើទម្លាប់នៃការអាននិងឥទ្ធិពលនៃគ្រួសារនៅសាលាសកលវិទ្យាល័យមួយនៅក្នុងរាជធានីភ្នំពេញ។ អ្នកស្រាវជ្រាវពីររូបដែលក្នុងនោះរួមមានNou Panhaka និង Prum Leakhena(២០១៦) បានធ្វើការសិក្សាលើប្រធានបទខាងលើ ហើយលទ្ធផលនៃការស្រាវជ្រាវរបស់ពួកគាត់បានបង្ហាញថាកត្តាគ្រួសារគឺកត្តាសំខាន់មួយក្នុងការកំណត់កម្រិតភាពខ្លាំងនៃការអានរបស់ពួកគេ ដោយក្នុងចំណោមយុវជនកម្ពុជាក្នុងកម្រិតជឿជាក់៦០ភាគរយ។ ហើយយោងតាមការរកឃើញរបស់ពួកគាត់ ៦០ភាគរយនៃអ្នកឆ្លើយតបបានចាត់ទុកខ្លួនឯងថាជាអ្នកអានមធ្យម ២០ភាគរយនៃអ្នកឆ្លើយបានអះអាងថាពួកគេអាននៅពេលដែលត្រូវការតែប៉ុណ្ណោះ ហើយ២០ភាគរយនៃអ្នកឆ្លើយតបផ្សេងទៀត ពួកគេចូលចិត្តការអានខ្លាំង។ ទន្ទឹមនឹងនេះដែរ សម្ភារៈដែលគេអានទូទៅមានដូចជាសៀវភៅ(៨៣%) ព័ត៌មានតាមអ៊ីនធឺណែត(៦៧%) និងសម្ភារៈសិក្សា(៥៣%)។ ហើយចំពោះចំនួនម៉ោងដែលពួកគេអានក្នុងមួយខែបានបង្ហាញថាពួកគេអានត្រឹមតែ២-៤ម៉ោងក្នុងមួយខែ(១៧%) ពួកគេអាន ៥-៨ម៉ោងក្នុងមួយខែ(៣០%) ពួកគេអាចលើស៨ម៉ោងក្នុងមួយខែ(៥៣%)។ ជាមួយគ្នានេះ

លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញទៀតថា អ្នកចូលរួមឆ្លើយតប ៣៧ភាគរយបានអះអាងថា ពួកគេអានសម្រាប់ការសិក្សារបស់ពួកគេ ហើយ៧ភាគរយទៀតអានសម្រាប់ការស្រាវជ្រាវ រីឯ២២ភាគរយទៀតនៃអ្នកចូលរួមឆ្លើយតប ពួកគេអានដើម្បីកាត់បន្ថយភាពអផ្សុក។

ចំពោះការសិក្សាមួយទៀតបានបង្ហាញថា ក្នុងបរិបទសង្គមខ្មែរនាពេលបច្ចុប្បន្ន បញ្ហាដែលធ្វើឱ្យសិស្សខ្មែរនៅថ្នាក់វិទ្យាល័យពុំចូលចិត្តអានដោយសារតែកត្តាប្រាំមួយយ៉ាងគឺ ១) កត្តាទម្លាប់របស់បុគ្គល ២)កត្តាកង្វះខាតសៀវភៅសិស្ស ៣) ចំណងជើងប្រធានបទមិនសមស្របនឹងចំណូលចិត្តសិស្ស ៤) ជាអត្ថបទអំណានមានពាក្យពិបាកឬពាក្យបច្ចេកទេសច្រើន ៥) អត្ថបទមានចំនួនច្រើនទំព័រ និងទី៦)ជាកត្តាកង្វះខាតការជំរុញនិងលើកទឹកចិត្តក្នុងការអានពីសំណាក់ឪពុកម្តាយ គ្រូបង្រៀន និងសហគមន៍ ជាពិសេស គឺទាក់ទងនឹងសិស្សខ្សោយផ្នែកចំណេះដឹងភាសាខ្មែរកាលពីរៀននៅថ្នាក់ក្រោម និងគោលនយោបាយលើកកម្ពស់ការអាននៃវិស័យអប់រំរបស់ជាតិនៅមានកម្រិតទាបនិងមានសន្ទុះតិចតួចប៉ុណ្ណោះ(សុផល, ២០១២)។

# ជំពូក ៣៖ វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងជំពូកទី៣នេះ អ្នកស្រាវជ្រាវបានជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវតាមបែបគុណវិស័យ ដែលបង្កើតសំណួរសម្ភាសតាមទម្រង់សំណួរពាក់កណ្ដាលគម្រោង (semi-structured interview)។ ហើយចំពោះរបៀបនៃការរើសសំណាកវិញ អ្នកស្រាវជ្រាវបានកំណត់យកប្រភេទសំណាកគំរូមានគោលបំណង ដោយរើសយកសំណាក់សិស្សខ្សោយ៦រូប គ្រូបង្រៀនភាសាខ្មែរថ្នាក់ទី៧ចំនួន២រូប អាណាព្យាបាលសិស្សខ្សោយទាំងប្រាំមួយរូប និងអ្នកជំនាញអក្សរសាស្ត្រខ្មែរ ដែលពួកគាត់មានបទពិសោធការងារច្រើនទាក់ទងនឹងអំណាន។ រីឯ ការវិភាគទិន្នន័យគឺអ្នកស្រាវជ្រាវអនុលោមតាមវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ ដោយមានការកំណត់យកគំនិតសំខាន់រួមគ្នាពីខ្លឹមសារសម្ភាស រួចក៏កំណត់ជាកូដបន្តទៀត។

## ៣.១ គម្រោងការស្រាវជ្រាវ

ក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវអំពីសមត្ថភាពអំណានរបស់សិស្សថ្នាក់ទី៧ នៅក្នុងអនុវិទ្យាល័យស្វាយរលំ អ្នកស្រាវជ្រាវបានប្រើវិធីសាស្ត្រស្រាវជ្រាវតាមបែបគុណវិស័យ។ លោក Dawson(2007)បានបង្ហាញថាវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យគឺ ស្វែករកពីឥរិយាបថ អាកប្បកិរិយា និងបទពិសោធន៍ ហើយវាជាវិធីសាស្ត្រស្រាវជ្រាវមួយដែលព្យាយាម

រកនូវគំនិតស៊ីជម្រៅពីអ្នកចូលរួម។ មួយវិញទៀត លោក Fraenkel, Wallen និង Hyun (2012) បានបញ្ជាក់ពីបែបផែននៃវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យនេះថា វាមានការពិចារណាច្រើនជាមួយនឹងស្ថានភាពនៃការយល់ដឹងនិងទស្សនៈរបស់អ្នកចូលរួម។ ហើយការអនុវត្តតាមវិធីសាស្ត្រស្រាវជ្រាវនេះទៀតសោត អ្នកស្រាវជ្រាវអាចមានលទ្ធភាពបត់បែនទិចនិក វិធីសាស្ត្រ ឬយុទ្ធវិធីនៃការស្រាវជ្រាវបានក្នុងកំឡុងពេលនៃដំណើរការស្រាវជ្រាវ។ ជាមួយគ្នានេះ អ្នកស្រាវជ្រាវប្រើសំណួរបើកនិងសំណួរបែបប្រដេញទៅកាន់អ្នកចូលរួម ដើម្បីរកឱ្យបាននូវទិន្នន័យដែលស៊ីជម្រៅ ហើយអ្នកស្រាវជ្រាវមិនមានបំណងយកលទ្ធផលនៃការស្រាវជ្រាវទៅធ្វើជាទូទៅកម្មឬសន្មតក្នុងបរិបទប្រទេសកម្ពុជាបានទាំងមូលនោះទេ ពោលគឺអាចធ្វើទូទៅកម្មបានត្រឹមកម្រិតសាលារៀនដែលអ្នកស្រាវជ្រាវបានចុះទៅធ្វើការស្រាវជ្រាវតែប៉ុណ្ណោះ។

## ៣.២ ទំហំសំណាក និងការធ្វើសំណាក

ដើម្បីឱ្យការស្រាវជ្រាវមួយនេះឆ្លើយតបនឹងសំណួរស្រាវជ្រាវនោះ អ្នកស្រាវជ្រាវកំណត់យកប្រភេទសំណាកគំរូមានគោលបំណង(Purposeful sampling)។ នៅក្នុងសំណាកគំរូមានគោលបំណងនេះ អ្នកស្រាវជ្រាវមានចេតនាជ្រើសរើសបុគ្គលនិងតំបន់ណាមួយដើម្បីសិក្សា ឬយល់ដឹងពីបាតុភូតនៃបញ្ហាដែលប្រធានបទចង់ស្រាវជ្រាវ។ ហើយស្តង់ដារដែលត្រូវបានប្រើក្នុងការជ្រើសរើសអ្នកចូលរួម និងតំបន់ណាមួយគឺអ្នកស្រាវជ្រាវដឹងច្បាស់ថា ពួកគេ

មានព័ត៌មានដែលអ្នកស្រាវជ្រាវចង់បាន(Creswell, 2012) ។ ដូចនេះ បុគ្គលដែលអ្នកស្រាវជ្រាវបានជ្រើសរើសក្នុងការប្រមូលទិន្នន័យនេះមានអ្នកជំនាញខាងអក្សរសាស្ត្រខ្មែរ ដែលពួកគាត់មានបទពិសោធច្រើនទៅលើអំណានភាសាខ្មែរ និងអាណាព្យាបាលរបស់សិស្ស គ្រូ សិស្សដែលខ្សោយការអាន។ ហើយចំពោះការកំណត់អត្តសញ្ញាណទៅលើសិស្សខ្សោយការអានគឺធ្វើឡើងតាមរយៈការសាកសួរទៅកាន់គ្រូ ដែលបង្រៀនមុខវិជ្ជាភាសាខ្មែរផ្ទាល់ មើលទៅលើលទ្ធតេស្តអំណានដែលខាងសាលាបានធ្វើតេស្តវាស់ស្ទង់សមត្ថភាពសិស្សថ្នាក់ទី៧នៅដើមឆ្នាំសិក្សា និងមើលទៅលើលទ្ធផលនៃការប្រឡងប្រឡងប្រចាំខែរបស់សិស្ស រួចក៏កំណត់ជ្រើសយកសិស្សខ្សោយការអានក្នុងមួយថ្នាក់ចំនួន២នាក់។ សូមបញ្ជាក់ផងដែរនៅអនុវិទ្យាល័យស្វាយរលំមានកម្រិតថ្នាក់ទី៧ចំនួន៣ថ្នាក់ ។ ដូចនេះ សិស្សដែលអ្នកស្រាវជ្រាវកំណត់ជ្រើសជាសំណាកគំរូមានចំនួន០៦នាក់ ពីព្រោះអ្នកស្រាវជ្រាវគិតពីពេលវេលានិងភាពងាយស្រួលក្នុងការប្រមូលទិន្នន័យ។ រីឯគ្រូបង្រៀនវិញ អ្នកស្រាវជ្រាវកំណត់យកគ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរនៅកម្រិតថ្នាក់ទី៧ទាំងអស់ចំនួន០២នាក់។ ចំណែកឯអាណាព្យាបាលសិស្ស អ្នកស្រាវជ្រាវកំណត់យក០៦នាក់ ដែលជាអាណាព្យាបាលរបស់សិស្សខ្សោយការអានទាំងប្រាំមួយរូបខាងលើ។

## ៣.៣ ឧបករណ៍សម្រាប់ការស្រាវជ្រាវ

ដើម្បីអាចសម្រេចដល់វត្ថុបំណងនៃការស្រាវជ្រាវ អ្នកស្រាវជ្រាវបានប្រើនូវកិច្ចសម្ភាសបែបសំណួរពាក់កណ្ដាលគ្រោង( semi-structured interview) ដែលមានសំណួរទាំងអស់ជាទម្រង់សំណួរបើក។ ហើយការប្រើសំណួរប្រើក្នុងការសម្ភាសអាចជួយអ្នកស្រាវជ្រាវស្វែររកបាននូវបទពិសោធន៍និងទស្សនៈស៊ីជម្រៅរបស់អ្នកចូលរួមទាក់ទងបញ្ហានៃប្រធានបទរបស់អ្នកស្រាវជ្រាវ។ ការសម្ភាសដោយប្រើសំណួរបើកនេះ ត្រូវអនុវត្តលើអ្នកចូលរួមចំនួន០២នាក់ជាអ្នកជំនាញ ចំនួន០៦នាក់ជាសិស្ស ០៦នាក់ទៀតជាអាណាព្យាបាលសិស្ស និង០២នាក់ផ្សេងទៀតជាគ្រូបង្រៀននៃអនុវិទ្យាល័យស្វាយរលំ ដែលពួកគាត់បង្រៀនមុខវិជ្ជាភាសាខ្មែរនៅថ្នាក់ទី៧។ ជាមួយគ្នានេះដែរ សំណួរបើកនៅក្នុងការសម្ភាសរបស់អ្នកស្រាវជ្រាវ ធ្វើឡើងបួនទម្រង់ខុសគ្នា ពោលគឺទម្រង់សំណួរបើកសម្រាប់អ្នកជំនាញ សិស្ស សម្រាប់គ្រូ និងសម្រាប់អាណាព្យាបាលសិស្ស ប៉ុន្តែខ្លឹមសារនៃសំណួរទាំងអស់គឺផ្ដោតទៅលើការយល់ឃើញពីមូលហេតុនៃកម្សោយការអានរបស់សិស្សទាំងអស់ និងវិធីសាស្ត្រជួយសិស្សឱ្យអភិវឌ្ឍលើសមត្ថភាពអំណានភាសាខ្មែរ ។ ទន្ទឹមនឹងនេះដែរ ដើម្បីឱ្យការឆ្លើយនឹងសំណួរស្រាវជ្រាវប្រកបដោយគុណភាព អ្នកស្រាវជ្រាវបានបង្កើតនូវពិធីសារសម្ភាសដូចដែលមានក្នុងឧបសម្ព័ន្ធ។ យោងតាមលោកCreswell(២០១២) បានបង្ហាញថាពិធីសារសម្ភាសបម្រើក្នុងគោលបំណងរំលឹកអ្នកស្រាវជ្រាវអំពីសំណួរ ហើយផ្ដល់នូវមធ្យោបាយសម្រាប់ការកត់ចំណាំផងដែរ ហើយវាជាទម្រង់

មួយដែលបានចងក្រងឡើងដោយអ្នកស្រាវជ្រាវផ្ទាល់រួមមានបញ្ចូលមានចំណុចដូចជាសេចក្តីណែនាំនៃដំណើរការសម្ភាស សំណួរសម្រាប់សួរនៅពេលសម្ភាស ចន្លោះទំនេរសម្រាប់កត់ត្រាចម្លើយរបស់អ្នកដែលយើងត្រូវសម្ភាស។ ព្រមជាមួយគ្នានេះដែរ ពិធីសារសម្ភាស ការរចនា និងការអភិវឌ្ឍនៃពិធីសារសម្ភាសនានា នឹងបង្ហាញថា អ្នកស្រាវជ្រាវមានមធ្យោបាយរៀបចំការថតសំឡេងនិងការរក្សាការកត់សម្គាល់ (Creswell, 2012)។ បន្ថែមពីនេះទៀត អ្នកស្រាវជ្រាវបានប្រើនូវបំណិននៃអំណានទាំងប្រាំ រួមមានៈ ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ ការចេះអានវាក្យសព្ទ ការចេះអានស្ទាត់ និងការអានដើម្បីយល់ន័យ ក្នុងការវិនិច្ឆ័យទៅលើសមត្ថភាពអំណានរបស់សិស្ស (MoEYS, 2018)។

## ៣.៤ នីតិវិធីនៃការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវប្រើការសម្ភាសសំណួរពាក់កណ្តាលគ្រោង (The semi-structure interview) និងឯកសារជំនួយដល់ការស្រាវជ្រាវផ្សេងទៀត ដែលបានពិនិត្យសម្រេចដោយគ្រូដឹកនាំនិងមានលិខិតអនុញ្ញាតឱ្យចុះប្រមូលស្រាវជ្រាវនៅអនុវិទ្យាល័យស្វាយរលំ ដែលមានការចេញលិខិតនេះដោយលោកនាយកមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី។ មុននឹងធ្វើការសម្ភាស អ្នកស្រាវជ្រាវបានប្រាប់ពីវត្ថុបំណងនៃការស្រាវជ្រាវទៅដល់អ្នកចូលរួមទាំងអស់ឱ្យបានដឹង។ ព្រមទាំងផ្តល់ដំណឹងជាមុនដល់ពួក

គាត់ថាសុំអនុញ្ញាតក្នុងការសម្ភាស ដោយមានការប្រើម៉ាស៊ីនថតសំឡេង ហើយរាល់ព័ត៌មានដែលពួកគាត់ផ្តល់ឱ្យអ្នកស្រាវជ្រាវ អ្នកស្រាវជ្រាវបានរក្សាជាការសម្ងាត់។ ជាមួយគ្នានេះ រាល់សំណួរទាំងអស់ ដែលបានរៀបចំហើយត្រូវបានសួរទៅកាន់អ្នកចូលរួមទាំងអស់និងរួមបញ្ចូលទាំងសំណួរដទៃទៀត ដែលលេចឡើងក្នុងកំឡុងពេលសម្ភាស។ ចំពោះបូនភាគីដែលចូលរួមក្នុងការសម្ភាសមាន អ្នកជំនាញ គ្រូ សិស្ស និងអាណាព្យាបាលសិស្សត្រូវបានធ្វើការសម្ភាសក្នុងពេលវេលាខុសគ្នានិងធ្វើការសម្ភាសម្នាក់ម្តងៗ។ការសម្ភាសបែបនេះជាវិធីសាស្ត្រពេញនិយមមួយដែលគេប្រើច្រើនក្នុងបរិបទស្រាវជ្រាវអប់រំ ហើយការថតសំឡេងនៅពេលសម្ភាសក៏ធ្វើឡើងម្នាក់ម្តងៗដែរ(Creswell, 2012)។

## ៣.៥ ការវិភាគទិន្នន័យ

Creswell (2012)បានពន្យល់ថាការវិភាគទិន្នន័យបែបគុណវិស័យតម្រូវឱ្យអ្នកស្រាវជ្រាវដឹងច្បាស់ពីរបៀបនៃការសម្រួលអត្ថន័យក្នុងការសរសេរឱ្យបានល្អ ទើបអ្នកស្រាវជ្រាវអាចសរសេរចម្លើយស្របទៅនឹងសំណួរស្រាវជ្រាវរបស់ពួកគេ។ ហើយការរៀបចំទិន្នន័យសម្រាប់វិភាគតម្រូវឱ្យមានការរៀបចំព័ត៌មានឱ្យបានស៊ីជម្រៅ ដែលទិន្នន័យបានមកក៏តម្រូវឱ្យអ្នកស្រាវជ្រាវសរសេរសម្រួលពីភាសានិយាយទៅជាភាសាសរសេរមួយដ៏ត្រឹមត្រូវដើម្បីងាយស្រួលក្នុងការវិភាគ។ ក្នុងន័យនេះ បន្ទាប់ពីធ្វើកិច្ចសម្ភាសរួច អ្នកស្រាវជ្រាវត្រូវកត់ត្រារាល់ពាក្យសំដីដែលអ្នកចូលរួមបានផ្តល់ឱ្យ ហើយទិន្នន័យដែលបានមកនោះដែរ

អ្នកស្រាវជ្រាវមានការគិតដោយប្រុងប្រយ័ត្នដើម្បីវិភាគក្នុងការកំណត់គំនិតសំខាន់ (themes)។ និយាយរួមដំណើរការវិភាគទិន្នន័យ ដំបូងគឺអ្នកស្រាវជ្រាវត្រូវអាននិងសរសេរដោយម៉ត់ចត់។ បន្ទាប់មកទៀត ការបកប្រែសម្រួលន័យលើទិន្នន័យតាមករណីសិក្សាក្នុងការវិភាគ។ នៅចុងបញ្ចប់នេះ លទ្ធផលត្រូវបានកំណត់សញ្ញាណមួយច្បាស់លាស់និងធ្វើចំណែកថ្នាក់តាមគំនិតសំខាន់នីមួយៗដូចលទ្ធផលនៃការវិភាគទិន្នន័យ។គួរបញ្ជាក់ផងដែលថា នៅក្នុងការសិក្សាស្រាវជ្រាវនេះមានបួនភាគីចូលរួមដែលក្នុងនោះរួមមានក្រុមសិស្សចំនួន៦នាក់ អ្នកស្រាវជ្រាវបានតាងអក្សរកាត់ថា (អ.ក.ស) ក្រុមអាណាព្យាលចំនួន៦នាក់ អ្នកស្រាវជ្រាវបានតាងអក្សរកាត់ថា (អ.ក.អា) ក្រុមគ្រូចំនួន២នាក់ អ្នកស្រាវជ្រាវបានតាងអក្សរកាត់ថា (អ.ក.គ) និងក្រុមអ្នកជំនាញខាងអក្សរសាស្ត្រខ្មែរ អ្នកស្រាវជ្រាវបានតាងអក្សរកាត់ថា (អ.ក.ជំ)។ បន្ថែមពីនេះទៀត នៅក្នុងក្រុមនីមួយៗ អ្នកស្រាវជ្រាវក៏បានកំណត់អក្សរកាត់ដើម្បីហៅអ្នកចូលរួមនីមួយៗក្នុងក្រុមទាំងនោះដែរ ឧទាហរណ៍៖ អ.ក.ស១ អ.ក.គ២ អ.ក.អា៣ អ.ក.ជំ២ជាដើម។ អ្នកស្រាវជ្រាវបានសម្រេចតាមគំរូខាងលើនេះ ក្នុងបំណងរក្សាការសម្ងាត់ជូនអ្នកចូលរួមផ្តល់ទិន្នន័យក៏ដូចជាបញ្ចៀសការខុសក្រមសីលធម៌នៃការស្រាវជ្រាវ។

## ៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ

នៅពេលដែលអ្នកស្រាវជ្រាវចុះទៅសម្ភាសនៅកន្លែងណាមួយ អ្នកស្រាវជ្រាវតែងតែធ្វើការសុំអនុញ្ញាតពីបុគ្គលផ្ទាល់ដើម្បីសម្ភាស។ រាល់អ្នកចូលរួមទាំងអស់ អ្នកស្រាវជ្រាវបានស្នើ

សុំឱ្យចូលរួមដោយក្តីពេញចិត្តនិងស្ម័គ្រចិត្ត ហើយអ្នកចូលរួមមានសិទ្ធមិនឆ្លើយនឹងសំណួរណា ដែលរសើបឬប៉ះពាល់ដល់គាត់។ បន្ថែមពីនេះទៀត រាល់ព័ត៌មានដែលបានមកពីអ្នកចូលរួម អ្នកស្រាវជ្រាវបានរក្សាវាជាការសម្ងាត់។ សីលធម៌របស់អ្នកស្រាវជ្រាវត្រូវឱ្យច្បាស់ប្រាកដថា លទ្ធផល ដែលចេញមកមិនជះឥទ្ធិពលអាក្រក់ដល់អ្នកចូលរួម។ ការសិក្សាមួយដែលល្អក៏ត្រូវ តែអនុលោមតាមតម្រូវការនៃក្រមសីលធម៌ផងដែរ។

## ៣.៧ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវរបស់អ្នកស្រាវជ្រាវលើប្រធានបទមួយនេះ មានទំហំតូចនៅឡើយ ព្រោះ បានចុះធ្វើការស្រាវជ្រាវ និងប្រមូលទិន្នន័យបានត្រឹមកម្រិតថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំតែ ប៉ុណ្ណោះ។ ដូចនេះអ្នកស្រាវជ្រាវអាចធ្វើការវាយតម្លៃលទ្ធផលនៃសមត្ថភាពអំណានបានត្រឹមតែ សិស្សនៅក្នុងសាលាខាងលើនិងមិនអាចវង្វាយតម្លៃជាលក្ខណៈទូលំទូលាយបាននៅឡើយ ក៏ ប៉ុន្តែលើក្រោយអ្នកស្រាវជ្រាវមានពេលវេលានិងឯកសារគ្រប់គ្រាន់អ្នកស្រាវជ្រាវនឹងនៅតែបន្ត ស្រាវជ្រាវលើប្រធានបទនេះបន្តទៀត តែមានទ្រង់ទ្រាយធំគឺសិក្សាការអានរបស់សិស្សទូទាំង ប្រទេសកម្ពុជាតែម្តង។

# ជំពូក ៤៖ លទ្ធផលនៃការស្រាវជ្រាវ

នៅក្នុងជំពូកនេះបង្ហាញពីលទ្ធផលនៃការសិក្សាស្រាវជ្រាវ បន្ទាប់ពីការប្រមូលទិន្នន័យតាមវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ ការប្រើកិច្ចសម្ភាសបែបពាក់កណ្តាលគម្រោងទៅលើភាគីបួនចូលរួម។ ហើយអ្នកស្រាវជ្រាវបានកំណត់យកបួនភាគីក្នុងការទាញយកព័ត៌មានគន្លឹះៗ ដើម្បីសម្រេចបាននូវសំណួរស្រាវជ្រាវក្នុងជំពូកមួយនិងដោះស្រាយបញ្ហារបស់អ្នកស្រាវជ្រាវទាំងស្រុងបាន។ ជាមួយគ្នានេះ ភាគីទាំងបួនរួមមានអ្នកចូលរួមក្រុមសិស្ស(អ.ក.ស) អ្នកចូលរួមក្រុមអាណាព្យាបាលសិស្ស(អ.ក.អា) អ្នកចូលរួមក្រុមគ្រូ(អ.ក.គ) និងអ្នកចូលរួមក្រុមអ្នកជំនាញ(អ.ក.ជំ)។

ក្នុងលទ្ធផលនៃការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានធ្វើចំណែកថ្នាក់ជាពីរផ្នែកធំៗដែលឆ្លើយតបទៅតាមសំណួរស្រាវជ្រាវដែលមានក្នុងជំពូកមួយ៖ ៤.១) ទស្សនទានចំពោះសមត្ថភាពអំណានភាសាខ្មែរ និង៤.២) និតិវិធីដែលជួយលើកកម្ពស់អំណានភាសាខ្មែរ ។ បន្ថែមពីនេះទៀត អ្នកស្រាវជ្រាវមិនបានបង្ហាញឈ្មោះពិតរបស់អ្នកចូលរួមទេ ដោយប្រើអក្សរកាត់តាងក្រុមនីមួយៗនិងតាងសមាសភាពអ្នកចូលរួមក្នុងក្រុមនីមួយៗជំនួសវិញ ដើម្បីរក្សាការសម្ងាត់ និងសិទ្ធិជាម្ចាស់រាល់ព័ត៌មានរបស់ពួកគេដែលបានផ្តល់ជូនអ្នកស្រាវជ្រាវ។

ជាការពិតណាស់ លទ្ធផលនៃការស្រាវជ្រាវសំខាន់ៗដែលបានបង្ហាញ វាបានឆ្លើយតបនឹងសំណួរស្រាវជ្រាវនិងវត្ថុបំណងនៃការស្រាវជ្រាវបានមួយភាគធំ។ ហើយវាបានបង្ហាញពីទស្សនៈរបស់សិស្ស អាណាព្យាបាលសិស្ស គ្រូ និងអ្នកជំនាញទៅលើបញ្ហានៃការស្រាវជ្រាវ។ ជាមួយគ្នានេះដែរ រាល់ទស្សនៈពីក្រុមភាគីទាំងបួនបានបង្ហាញពីភាពស្របគ្នា ក៏ដូចជាផ្ទុយខ្លះផងដែរ។ តាមរយៈការសម្ភាស ដំណើរការសម្រួលភាសានិយាយមកជាភាសាសរសេរ ការចាប់កូដនិងការវិភាគទិន្នន័យ អ្នកស្រាវជ្រាវបានកំណត់យកផ្នែកនៃចំណុចសំខាន់ៗពីរ ហើយនៅក្នុងគំនិតសំខាន់ៗទាំងពីរដែលអ្នកស្រាវជ្រាវបានធ្វើចំណែកថ្នាក់នោះ អ្នកស្រាវជ្រាវបានចែកជាផ្នែកតូចៗបន្តបន្ទាប់ទៀត។ ជាក់ស្តែង នៅក្នុងផ្នែកទីមួយ(៤.១)មានប្រាំពីរចំណុចបន្តទៀតដែលក្នុងនោះរួមមាន ១.១) សមត្ថភាពអំណានភាសាខ្មែរ (១.២) ផ្នែកដែលសិស្សមានកម្សោយអំណាន (១.៣) មូលហេតុនៃកម្សោយការអាន (១.៤) ទម្លាប់នៃការអាន (១.៥) វត្ថុបំណងនៃសមត្ថភាពអំណាន និង (១.៦) ដំណើរការនៃការបង្រៀនអំណាន។ ទន្ទឹមនឹងនេះដែរ នៅក្នុងផ្នែកតូចៗខាងលើ អ្នកស្រាវជ្រាវបានចែកជាចំណុចតូចនៅក្នុងនោះបន្ថែមទៀតដែរ។ ហើយចំពោះចំណុចសំខាន់នៅផ្នែកទីពីរ(៤.២) មានចំណុចសំខាន់ពីរបន្ថែមទៀត ពោលគឺ ២.១) នីតិវិធីដែលធ្លាប់អនុវត្តកន្លងមកក្នុងការលើកកម្ពស់អំណាន និង ២.២) នីតិវិធីដែលនឹងអនុវត្តបន្តដើម្បីលើកកម្ពស់អំណាន។ សូមបញ្ជាក់បន្ថែម រាល់ចំណុចដែលបែងចែកក្នុងគំនិតសំខាន់ទាំងពីរសុទ្ធតែគាំទ្រនិងផ្តល់ព័ត៌មានយ៉ាងលម្អិតទៅលើផ្នែកទាំងនោះ។

## ៤.១ ទស្សនទានចំពោះសមត្ថភាពអំណានភាសាខ្មែរ

វត្ថុបំណងនៃផ្នែកទីមួយនេះគឺចង់បង្ហាញពីទស្សនៈនៃការយល់ឃើញរបស់អ្នកចូលរួមទៅលើសមត្ថភាពនៃការអានភាសាខ្មែរ។ តាមរយៈការសម្ភាសទៅកាន់អ្នកចូលរួមបួនភាគីផ្សេងគ្នាបានបង្ហាញពីការយល់ឃើញនូវចំណុចប្រហាក់ប្រហែលគ្នាខ្លះ ចំណុចខុសគ្នាខ្លះ និងផ្ទុយគ្នាផងដែរទៅលើសមត្ថភាពអំណានភាសាខ្មែររបស់សិស្ស។ ទស្សនៈយល់ឃើញនៃបួនភាគី(សិស្ស អាណាព្យាបាលសិស្ស គ្រូនិងអ្នកជំនាញ) ទៅលើសមត្ថភាពអំណានភាសាខ្មែរបានបង្ហាញលម្អិតដូចតទៅ។

### ៤.១.១ សមត្ថភាពអំណានភាសាខ្មែរ

សមត្ថភាពអំណានភាសាខ្មែរនៅកម្រិតថ្នាក់បឋមសិក្សាទុតិយភូមិ គឺសំដៅលើការដែលសិស្សអាចអានអត្ថបទបានរលូន សមត្ថភាពសិស្សអាចកំណត់ន័យពាក្យតាមទីសេចក្តី សិស្សអាចបកស្រាយរូបភាព ដ្យាក្រាម និងចេះដកស្រង់បទពិសោធអក្សរសិល្ប៍ជាគុណប្រយោជន៍នៃជីវភាពរស់នៅបច្ចុប្បន្ន។ ជាក់ស្តែង សមត្ថភាពនៃអំណានរបស់សិស្សនៅក្នុងថ្នាក់ទី៧នេះមិនប្រាកដថាពួកគេអាចសម្រេចឈានដល់វត្ថុបំណងដែលកម្មវិធីសិក្សាបានកំណត់ទេ។

តាមរយៈទស្សនៈរបស់អ្នកចូលរួមដែលបានពីការសម្ភាសបង្ហាញថា ក្រុមគ្រូបង្រៀន(អ.ក.គ) យល់ស្របដូចគ្នាថាក្នុងចំណោមសិស្សថ្នាក់ទី៧ទាំងអស់មានសិស្សដែលមានសមត្ថភាពអានបានល្អ(អានបានរលូនដោយលើកដាក់សំឡេងបានត្រឹមត្រូវ ចេះពន្យល់ពាក្យពិបាកៗ និង

ឆ្លើយសំណួរលើអត្ថបទបានត្រឹមត្រូវស្ទើរតែទាំងអស់)ត្រឹមតែ២០% ប៉ុណ្ណោះ ហើយសិស្សមានសមត្ថភាពអានបានល្អបង្គួរ( អានបានរលូន អាចយល់ន័យពាក្យពិបាកបានខ្លះ អាចឆ្លើយសំណួរលើអត្ថបទបានត្រឹមត្រូវមួយចំនួន)មាន២០%។ រីឯសិស្សដែលមានសមត្ថភាពអំណានមធ្យម(អាននៅរដាក់រដុបត្រង់ពាក្យពិបាកៗ ពាក្យកម្ចីពីបាលីសំស្ក្រឹត ការពន្យល់ពាក្យបានលើពាក្យងាយៗឬពាក្យដែលឧស្សាហ៍ជួបប្រទះតែប៉ុណ្ណោះ)មាន៣០% ហើយចំពោះសិស្សខ្សោយអំណានតែម្តង(អាននៅរដាក់រដុបច្រើន មិនអាចពន្យល់ពាក្យក្នុងអត្ថបទបាន និងអាចឆ្លើយសំណួរលើអត្ថបទបានតែសំណួរស្រួលដែលមានក្នុងអត្ថបទស្រាប់)មាន៣០%។ ជាក់ស្តែង អ.ក.គ១និងអ.ក.គ២បាននិយាយថា៖

យល់ថា ៣០ភាគរយគឺខ្សោយការអាន(អត់ដឹងថាពាក្យនោះអានថាដូចម្តេច ចំណាយពេលប្រកបពាក្យយូរ) ៣០ភាគរយគឺមធ្យម(អានបានខ្លះ នៅមានការប្រកបពាក្យបន្តិចបន្តួច( ២០ភាគរយគឺល្អបង្គួរ(ពាក្យងាយនិងពាក្យពិបាកដែលធ្លាប់ជួបអាចអានបានភាគច្រើន) ២០ភាគរយគឺ ល្អ(អានបានត្រឹមត្រូវទាំងពាក្យងាយស្រួលនិងពិបាក ចំពោះល្បឿននិងការលើកដាក់សំលើកដាក់សំឡេងបានត្រឹមត្រូវល្អ)។(អ.ក.គ១)

*"សិស្សអានឆ្លើយសំណួរដែលមានចម្លើយក្នុងសៀវភៅប្រហែល៦០ភាគរយទៅ៧០ភាគរយ ហើយចំពោះការយល់ន័យលើពន្យល់ពាក្យដូចជាមិនមានច្រើនទេប្រហែល*

*២០ភាគរយទៅ៣០ភាគរយ ប៉ុន្តែជាទូទៅពាក្យពិបាកយើងមាននៅផ្នែកខាងក្រោយនៃសៀវភៅពុម្ពពេលខ្លះគាត់អាចធ្វើបានទៅតាមហ្នឹង។" [អ.ក.គ២]*

ជាមួយគ្នានេះដែរ មានអ្នកជំនាញខាងអក្សរសាស្ត្រមួយរូប(អ.ក.ជំ២) គាត់បានបង្ហាញពីលទ្ធផលពីលទ្ធផលនៃការរកឃើញរបស់ក្រុមការងារគាត់ថាសិស្សនៅថ្នាក់ទី៧ភាគច្រើនពុំមានសមត្ថភាពអំណានភាសាខ្មែរសមស្របទៅនឹងកម្រិតសិក្សាភាសាខ្មែរថ្នាក់ទី៧នៅឡើយទេ។ ខាងក្រោយនេះ វាជាអ្វីដែលអ.ក.ជំ២បានលើកឡើងៈ

*"គម្រោងដែលអនុវត្តបន្ទាប់ពីក្រុមខ្ញុំបានបញ្ចប់គឺហៅថាបំណិនជីវិតដែលមាន៣២ប្រធានបទ ហើយប្រធានមួយក្នុងចំណោមបំណិនជីវិតហ្នឹង គេបង្កើតក្លឹបសិក្សា ហើយវាជាទូទៅបញ្ហាច្រើនមែនទែនឱ្យតែក្មេងៗដល់ថ្នាក់ទី៧ហ្នឹងអត់សូវចេះអានដល់កម្រិតថ្នាក់ដែលរៀនថ្នាក់ទី៧ហ្នឹងទេ។" [អ.ក.ជំ២]*

សរុបសេចក្តីមក អ្នកចូលរួមទាំងអស់ជាពិសេសគ្រូៗដែលបង្រៀនសិស្សផ្ទាល់បានកំណត់ច្បាស់ពីចំនួនសិស្សដែលសមត្ថភាពលើអំណានភាសាខ្មែរ។ ហើយតាមរយៈការបង្ហាញពីពួកគាត់ យើងអាចនិយាយបានថាសមត្ថភាពអំណានរបស់សិស្សនៅមានកម្រិតនៅឡើយដែលជាបញ្ហាគួរឱ្យកត់សម្គាល់ផង។

### ៤.១.២ ផ្នែកដែលសិស្សមានកម្សោយអំណាន

សមត្ថភាពអំណានមិនសំដៅតែលើល្បឿននៃការអានពាក្យរបស់សិស្សបានលឿនតែម្យ៉ាងទេ ប៉ុន្តែសិស្សត្រូវមានសមត្ថភាពក្នុងការយល់ន័យរបស់ពាក្យពិបាកៗក្នុងអត្ថបទ យល់ន័យសេចក្តីរបស់អត្ថបទ ក៏ដូចជាអាចចូលរួមឆ្លើយសំណួរលើអត្ថបទបានត្រឹមត្រូវផងដែរ។ ក្នុងន័យនេះ តាមរយៈការសម្ភាសគ្រូបង្រៀនទាំងពីររូប បានបង្ហាញថាសិស្សនៅថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំ មានកម្សោយការអាន៣០ភាគរយនិងមធ្យម៣០ភាគរយដែរ។ ដូចនេះកម្សោយការអានរបស់សិស្សទៅតាមផ្នែកនីមួយនៃសមត្ថភាពអំណានដែលក្នុងនោះ តាមរយៈការសម្ភាសទៅកាន់អ្នកចូលរួម អ្នកស្រាវជ្រាវបានរកឃើញផ្នែកមានកម្សោយអំណានស្របគ្នាចំនួនបីចំណុច ពោលគឺ(១) ល្បឿននៃការអាន(អត្ថបទដែលមានពាក្យពិបាក ត្រួតជើងច្រើន ឬពាក្យដែលខ្ចីពីបាលីសំស្ក្រឹត) ពួកគេនៅអានរាងទាក់ៗ មិនរលូនល្អឡើយ។ ហើយមានកូនសិស្សបីនាក់ក្នុងចំណោមប្រាំមួយនាក់ដែលចូលរួម បានបញ្ជាក់ថាពេលពួកគេអាន ពួកគេមានអារម្មណ៍រាងភ័យៗបន្តិច ដែលនេះជាហេតុធ្វើឱ្យពួកគេអានទាក់ៗ មិនរលូនល្អ។ ចំពោះចំណុចដែលស្របគ្នាទី២ គឺពួកគេទាំងអស់ពិតជាមានភាពពិបាកក្នុងការពន្យល់ន័យរបស់ពាក្យពិបាកៗដែលមានក្នុងអត្ថបទអំណាន។ ក្នុងនោះ មានសិស្សម្នាក់បាននិយាយថា៖

*"ពាក្យពិបាកខ្លះដែលខ្ញុំធ្លាប់បានជួបពីមុន ខ្ញុំអាចយល់ន័យវាបាន ប៉ុន្តែមិនដឹងថានឹងត្រូវរៀបពាក្យនិយាយយ៉ាងណា ដើម្បីឱ្យអ្នកដទៃអាចយល់ន័យពាក្យនោះដូចខ្ញុំដែរ។[អ.ក.ស១]*

ហើយសិស្សខ្លះទៀតបានបញ្ជាក់ថាពួកគេមិនអាចពន្យល់ន័យរបស់ពាក្យបាន ប្រហែលមកពីពួកគេមិនសូវមានទម្លាប់អាននិងមិនបានជួបពាក្យទាំងនោះពីមុនមក។ រីឯចំណុចទីបីដែលស្របគ្នានោះដែរ គឺការដែលពួកគេមិនមានសមត្ថភាពក្នុងការឆ្លើយសំណួរលើអត្ថបទណាដែលពិបាកៗ ទាមទារឱ្យមានការវិភាគស៊ីជម្រៅលើខ្លឹមសាររបស់អំណាន ឬទាក់ទងនឹងបំណិនក៏ដូចជាវេយ្យាករណ៍ដែលគេរៀនពីមុនមក។ ជាឧទាហរណ៍អ.ក.ស១និងអ.ក.ស៨បានលើកឡើងថា៖

*"បើរឿងយល់ន័យរបស់សំណួរហ្នឹង ខ្ញុំអាចឆ្លើយត្រូវបានហាសិបភាគរយ។ សំណួរនៅផ្នែកខាងលើសំណួរទីមួយទីពីរអីហ្នឹងគឺអាចឆ្លើយបានហើយ ពីព្រោះវាងាយស្រួល ចំពោះសំណួរទាក់ទងនឹងអត្ថន័យអប់រំ វេយ្យាករណ៍អីហ្នឹង យើងអាចឆ្លើយបានតិចៗទេ ហើយមូលហេតុដែលឆ្លើយមិនបានទីមួយខ្លាចខុស ទីពីរអត់យល់ន័យអត់ចេះ។[អ.ក.ស១]*

*"សំណួរត្រិះរិះនៅផ្នែកខាងក្រោមវាពិបាកពេក វាឱ្យគិតស្រាវជ្រាវច្រើន វិភាគជ្រៅៗ ហើយសំណួរខាងលើ គ្រាន់តែអានអត្ថបទអានរកមកឆ្លើយបាន។[អ.ក.ស៨]*

ជាមួយគ្នានេះ អ.ក.គនិងអ.ក.ជំ២ក៏បានបង្ហាញពីផ្នែកនៃកម្សោយការអានស្របទៅនឹងអ.ក.សផងដែរ ពោលគឺសិស្សខ្សោយល្បឿននៃការអាន ការយល់ន័យរបស់ពាក្យពិបាកៗ និងការឆ្លើយសំណួរលើអត្ថបទ។ ជាក់ស្តែងអ.ក.គ២បាននិយាយថា៖

*"ខ្ញុំអាចនិយាយបានថាសិស្សនៅមានកម្រិតទៅលើល្បឿននៃការអានពាក្យ ទីពីរឈរ*

*លើកការយល់ន័យរបស់ពាក្យនីមួយៗ និងទីបីគាត់អានឆ្លើយសំណួរហ្នឹងបាន។ ហើយខ្ញុំសូមបញ្ជាក់ផងដែរ ប៉ុន្តែពេលខ្លះសិស្សអាចអានបានមែនប៉ុន្តែគាត់មិនសូវយល់ន័យ និងមិនសូវអានឆ្លើយសំណួរបានទេ មិនដឹងឆ្លើយពីណាទៅណា។"[អ.ក.គ២]*

សរុបសេចក្តីមក សិស្សភាគច្រើនមានកម្សោយលើការពន្យល់ពាក្យ ការយល់ន័យរបស់អត្ថបទ និងពិបាកក្នុងការឆ្លើយសំណួរដែលទាមទារឱ្យពួកគេពិចារណាស៊ីជម្រៅ។

### ៤.១.៣ មូលហេតុនៃកម្សោយអំណាន

បញ្ហាសិស្សខ្សោយការអានមិនមែនជារឿងតូចតាចដែលភាគីពាក់ព័ន្ធត្រូវមើលរំលងនោះទេ ពីព្រោះកាលណាដែលសិស្សខ្សោយការអាន វានឹងមានឥទ្ធិពលអវិជ្ជមានដល់ការសិក្សាមុខវិជ្ជាដទៃទៀតជាមិនខាន។ អាស្រ័យហេតុនេះ តាមរយៈការសម្ភាស អ្នកស្រាវជ្រាវបានទទួលទិន្នន័យដែលពាក់ព័ន្ធលើមូលហេតុដែលនាំឱ្យសិស្សមានកម្សោយការអានបានចំនួន៧កត្តា។ នៅក្នុងនោះដែរ អ.ក.ស អ.ក.គ អ.ក.អា និងអ.ក.ជំ១ បានបង្ហាញនៅមូលហេតុស្រប មួយដែលធ្វើឱ្យសិស្សខ្សោយអាន នោះគឺកត្តាបញ្ហារបស់សិស្សផ្ទាល់ដែលមិនបានយកចិត្តទុកដាក់ខិតខំរៀនអាន ខ្ជិលអាន មិនទម្លាប់ក្នុងការអាន។ ហើយក្នុងចំណុចនេះ អ.ក.ជំ២បានបដិសេធទៅមូលហេតុមួយនេះដោយគាត់លើកឡើងថា៖

*"ចឹងនិយាយសរុបមកកត្តាកុមារហ្នឹងវាជះឥទ្ធិពលពីសង្គមដែលមិនទាន់មានគំរូមនុស្សរៀនសូត្រ មនុស្សអានសៀវភៅ ហើយការស្រាវជ្រាវទៅរកឃើញថា ការឱ្យតម្លៃឱ្យបាន*

*ខ្ពង់ខ្ពស់ថ្លៃថ្លាអីចឹង វាមិនទាន់មាន ហើយមិនអាចទម្លាក់កំហុសនេះទៅដល់ក្មេងបានទេ ជាការពិតក្មេងរងឥទ្ធិពលពីមនុស្សធំដែលនៅជុំវិញខ្លួនពួកគេ។" [អ.ក.ជំ១]*

បន្ថែមពីនេះ មូលហេតុនៃកម្សោយការអាន មកពីកត្តាបញ្ហាសាលារៀនដែលសំដៅយក ការដឹកនាំរៀបចំ ការជំរុញការអានពីគណៈនាយកសាលា ការប្រើវិធីសាស្ត្របង្រៀនតាមបែប ប្រពៃណីរបស់គ្រូដែលមិនបានប្រើវិធីសាស្ត្របង្រៀនថ្មីជំរុញដល់ការអាន និងបញ្ហាចំនួនសិស្ស ច្រើនក្នុងមួយថ្នាក់ៗ(៥០ទៅ៦០នាក់/ថ្នាក់)។ ហើយមូលហេតុនេះ បានលើកឡើងដោយ អ.ក.ស២ អ.ក.ស៦ អ.ក.គ និងអ.ក.ជំ។ ទន្ទឹមនឹងនេះ កត្តាទី៣ដែលធ្វើឱ្យសិស្សមានកម្សោយការអានគឺកត្តា បញ្ហាគ្រួសារ។ ក្នុងបញ្ហានេះ អ.ក.គនិងអ.ក.ជំ២ បានលើកឡើងថា បញ្ហាគ្រួសារជាកត្តាចម្បង ដែលជួយជំរុញកូនឱ្យអាន តែកាលណាអាណាព្យាបាលមិនចូលចិត្តអាន នោះទង្វើនេះ វានឹង ជះឥទ្ធិពលដល់កូន។ បន្ថែមពីនេះទៀត កាលណាដែលអាណាព្យាបាលខ្វះការយកចិត្តទុកលើ ការទិញសៀវភៅផ្សេងៗ មិនបានរៀបចំកន្លែងរៀនឱ្យកូននៅផ្ទះសមរម្យ និងមិនខ្វល់ពីការជំរុញ បន្ថែមលើការសិក្សា នោះការសិក្សារបស់កូនគាត់នឹងធ្លាក់ចុះជាក់ជាមិនខាន។ ពិសេសជាងនេះ ទៅទៀត អ.ក.គ១និង អ.ក.ជំ២ បានបង្ហាញគំនិតស្របគ្នាលើមូលហេតុមួយទៀត គឺសិស្សខ្វះ មូលដ្ឋានគ្រឹះពីថ្នាក់បឋមមក ដោយពួកគាត់លើកឡើងថា៖

*"សិស្សខ្សោយអំណានអាចមកពីកត្តាមួយចំនួនដូចជាខ្វះមូលដ្ឋានគ្រឹះជាថ្នាក់បឋមមក សិស្សអត់ចូលរួមអនុវត្តការអានទាំងនៅក្នុងថ្នាក់ និងនៅផ្ទះ ហើយសិស្សខ្លះមិនយកចិត្ត*

*ទុកដាក់ក្នុងការអាន ព្រមទាំងបញ្ហាគ្រួសារ(មិនចូលចិត្តអាន)ផងដែរ។"[អ.ក.គ១]*

*"មូលហេតុចំបងហ្នឹងមកពីការរៀននៅតំបន់ថ្នាក់ទាបៗហ្នឹងវាអត់ត្រឹមត្រូវ បានន័យថា បើយើងនិយាយពីថ្នាក់ទីមួយទីពីរហ្នឹង។ មួយទៀតគឺមាតាបិតានិងសហគមន៍យើង មើលទៅ ពិសេសនៅតំបន់ជនបទអីហ្នឹងគឺគាត់មិនបានយកចិត្តទុកដាក់មើលអាហ្នឹងទេ ឱ្យមែនទែនទេ។"[អ.ក.ជំ២]*

ចំពោះមូលហេតុ ស្របគ្នាមួយទៀតដែលលើកឡើងដោយអ.ក.គ២និងអ.ក.ជំ២ នោះគឺ កត្តាបញ្ហាបណ្ណាល័យដែលបណ្ណាល័យនៅសាលាអត់បានរៀបចំទីកន្លែងឱ្យមានការទាក់ទាញ ដល់សិស្សនិងពុំមានសៀវភៅសំបូរបែបសម្រាប់សិស្សដែលជាអ្នកអានផងដែរ។ ហើយអ.ក.គ២ បាននិយាយថា៖

*"ណាមួយបណ្ណាល័យសាលាយើងអត់មានសៀវភៅអ្វីទាក់ទាក់ឱ្យសិស្សចូលអានទេ ហើយបណ្ណាល័យក៏តូចចង្អៀតដែរ។ ខ្ញុំធ្លាប់ជំរុញឱ្យសិស្សចូលអានដែរ ប៉ុន្តែសិស្សតប វិញថាក្នុងហ្នឹងមានសៀវភៅដូចតែយើងរៀនហ្នឹងដែរ មានដូចជាសៀវភៅពុម្ព រឿងព្រេង ហ្នឹងក៏មិនសូវមាន។"[អ.ក.គ២]*

រីឯមូលហេតុចំនួនពីរទៀតដែលទទួលបានពីអ្នកចូលរួម នោះគឺកត្តាសង្គមដែលខ្វះការ ឱ្យតម្លៃលើការអាននិងកត្តាសៀវភៅគោលដែលគួរតែធ្វើបច្ចុប្បន្នកម្មឱ្យមានលក្ខណៈទាក់ទាញ បន្ថែមទៀតដល់អ្នកសិក្សា។

សរុបសេចក្តីមក បញ្ហាដែលនាំឱ្យសិស្សមានកម្សោយការអានភាសាខ្មែរនៅកម្រិតថ្នាក់ទី៧នៃសាលាអនុវិទ្យាល័យស្វាយរលំ អ្នកចូលរួមភាគច្រើនបានលើកឡើងពីផលជះមកពីកត្តាខាងក្រៅភាសាច្រើនជាងកត្តាដែលមានក្នុងភាសា ពោលគឺការមិនខិតខំរៀនអានរបស់សិស្ស ការមិនទម្លាប់អានតាំងពីតូច ការដែលគ្រប់ភាគីមិនបានចូលរួមយកចិត្តទុកដាក់និងជំរុញបន្ថែម បញ្ហាបណ្ណាល័យ និងម្សោយការអានតាំងពីថ្នាក់មូលដ្ឋានមក។

### ៤.១.៤ ទម្លាប់នៃអំណាន

ប្រជាជនខ្មែរភាគច្រើនក្នុងចង្កោមអ្នកសិក្សាគឺបានយល់ច្បាស់ពីអត្ថប្រយោជន៍នៃការអានសៀវភៅ ពោលគឺការអានជាសកម្មភាពមួយដែលល្អបំផុតក្នុងការជួយពួកគេឱ្យបានរីកចម្រើននូវផ្នែកបញ្ញា។ អាស្រ័យហេតុនេះ ពួកគេត្រូវតែធ្វើឱ្យការអានក្លាយជាទម្លាប់ប្រចាំថ្ងៃ។ ប៉ុន្តែ វាមានឧបសគ្គជាច្រើនក្នុងការបណ្តុះទម្លាប់អានរបស់មនុស្សខ្មែរក្នុងបច្ចុប្បន្ននេះ។ ជាក់ស្តែងតាមរយៈការសម្ភាសក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានទទួលបានទិន្នន័យដែលពាក់ព័ន្ធនឹងទម្លាប់អានចំនួនបីចំណុច នោះគឺ ឥរិយាបថនៃទម្លាប់អាន បញ្ហាប្រឈមនៃទម្លាប់អាន និងវិធីសាស្ត្របណ្តុះទម្លាប់អាន។

#### ៤.១.៤.១ ឥរិយាបថនៃទម្លាប់អាន

ការដែលមនុស្សរាល់គ្នាមានទម្លាប់អាន វាជាកត្តាសត្យានុម័តឆ្លុះបញ្ចាំងក្នុងន័យវិជ្ជមាន

ទៅដល់សមត្ថភាពអានរបស់ពួកគេ។ ជាមួយគ្នានេះដែរ ឥរិយាបថនៃការអានក៏កាន់តែសបញ្ជាក់ឱ្យឃើញច្បាស់ពីការដែលមានទម្លាប់អានឬក៏មិនមានទម្លាប់អានរបសមនុស្សផងដែរ។ ហើយបើក្រឡេកមកមើលពីឥរិយាបថនៃទម្លាប់អានរបស់សិស្សថ្នាក់ទី៧នៃសាលាអនុវិទ្យាល័យស្វាយរលំ អ្នកស្រាវជ្រាវបានរកឃើញថាពួកគេមិនមានឥរិយាបថវិជ្ជមានប៉ុន្មានទេក្នុងទម្លាប់អាន។ ជាក់ស្តែងតាមរយៈការសម្ភាសរបស់អ.ក.ស អ.ក.គ និងអ.ក.អា បានបង្ហាញនូវចំណុចរួមមួយ គឺអ.ក.ស មិនសូវចូលចិត្តការអានសៀវភៅនោះទេ ពោលគឺក្នុងមួយថ្ងៃពួកគេចំណាយពេលក្នុងការអានមិនលើសពី៣០នាទីទេ។ បើគិតទៅអ្នកចូលចិត្តអានមានតែ១០ភាគរយតែប៉ុណ្ណោះ ផ្ទុយពីនេះពួកគេចូលចិត្តលេងទូរស័ព្ទ(លេងហ្គេម Facebook YouTube Tik Tok) ច្រើនជាង។ បន្ថែមពីនេះ តាមការសង្កេតរបស់អ.ក.គ ពួកគាត់បានលើកឡើងថា ពេលចេញលេង កូនសិស្សរបស់គាត់ចូលចិត្តលេងជាជាងកាន់សៀវភៅអាន។ ហើយនៅពេលម៉ោងលីប គ្រូបានប្រាប់ឱ្យពួកគេចូលបណ្ណាល័យដែរ ប៉ុន្តែពួកគេហាក់មិនចាប់អារម្មណ៍នឹងការចូលបណ្ណាល័យទេ។ ចំពោះការចូលបណ្ណាល័យនេះដែរ អ.ក.គ២បាននិយាយថា៖

> *"សិស្សប្រាប់ខ្ញុំថា ពេលចូលបណ្ណាល័យតែឯង គាត់មានអារម្មណ៍ថាខ្លួនចម្លែកខុសគេយូរៗទៅលែងហ៊ានចូល។"[អ.ក.គ២]*

លើសពីនេះទៀត អ.ក.ស បានបញ្ជាក់ទៀតថា សៀវភៅដែលពួកគេអានភាគច្រើន គឺជាសៀវភៅពុម្ពតាមមុខវិជ្ជានីមួយៗ ហើយមានតែសិស្សពីរនាក់ក្នុងចំណោមសិស្ស៦ដែលបាន

ចូលផ្តល់បទសម្ភាសប៉ុណ្ណោះ ដែលបានបញ្ជាក់ថា ពួកគេមានសៀវភៅរឿងទិនាននៅផ្ទះ សម្រាប់អាន ប៉ុន្តែមិនមានច្រើនក្បាលនោះទេ។ បើនិយាយពីឥរិយាបថរបស់អាណាព្យាបាល ទៅលើការជួយជំរុញការអានរបស់កូនគាត់នៅផ្ទះវិញ គឺមានភាគរយតិចណាស់ ពីព្រោះពួកគាត់បានត្អូញត្អែថាគាត់រវល់ធ្វើការងារ រកស៊ី មិនមានពេលសួរនាំ ដេញដោលឬតាមដានការសិក្សារបស់កូន ក៏ដូចជាជំរុញឱ្យកូនអាននៅផ្ទះនោះទេ ពោលគឺឱ្យតែគាត់មកដល់ផ្ទះអស់កម្លាំង គាត់សម្រាកហើយ។ ចំណុចមួយទៀត គួរឱ្យចាប់អារម្មណ៍ដែរ គឺឥរិយាបថរបស់សិស្សភាគច្រើននៅពេលអាន ពួកគាត់ឆាប់ធុញ ហើយការអាននោះទៀតសោត អ.ក.ស៤ អ.ក.ស១ អ.ក.ស២ បានបង្ហាញផងដែរថា ពួកគេអានក្នុងបំណងអានឱ្យតែដាច់ទៅរលូនតែប៉ុណ្ណោះ ដោយពួកគេមានបានផ្តោតទៅលើអត្ថន័យ ខ្លឹមសាររបស់ពាក្យឬអត្ថបទប៉ុន្មាននោះទេ។ ជាក់ស្តែង អ.ក.ស១ និង អ.ក.អា៦ បាននិយាយថា៖

*"ខ្ញុំអានយ៉ាងច្រើនប្រាំនាទីអីហ្នឹងខ្ជិលហើយអ្នកគ្រូ។ ហើយនៅពេលអានទៅវាច្រើនពេកមានអារម្មណ៍ថាធុញ។"[អ.ក.ស១]*

*"បាទភាគច្រើនគាត់រៀនអានដើម្បីឱ្យអានទៅរលូនសិនមិនទាន់បានអានផ្តោតយកការយល់អត្ថន័យនៃសាច់រឿងនៅឡើយទេ។"[អ.ក.អា៦]*

សរុបសេចក្តីមក ឥរិយាបថនៃទម្លាប់អានរបស់សិស្ស ក៏ដូចជាអាណាព្យាបាលសិស្សនៅសាលាអនុវិទ្យាល័យស្វាយរលំភាគច្រើនមានឥរិយាបថអវិជ្ជមានដែលមិនជំរុញដល់ទម្លាប់

អាននោះទេ ដែលជាហេតុនាំឱ្យសិស្សមានកម្សោយលើសមត្ថភាពអំណានផងដែរ។

### ៤.១.៤.២ បញ្ហាប្រឈមនៃទម្លាប់អាន

តាមរយៈការសម្ភាសជាមួយអ.ក.ជ១ អ្នកស្រាវជ្រាវបានទទួលបានទិន្នន័យពីបញ្ហាប្រឈមនៃទម្លាប់អានជាទូទៅ។ តាមទស្សនៈរបស់គាត់ គាត់យល់ឃើញថាបញ្ហាប្រឈមនៃទម្លាប់អានមាន៥ចំណុចដែលក្នុងនោះ រួមមានការដែលមិនទម្លាប់អានតាំងពីតូច សិស្សផ្ទាល់គ្មានពេលនិងមិនមានអារម្មណ៍ផ្ចង់ ដើម្បីការអានបានល្អ គ្រួសារ សាលារៀន សង្គមមិនបានធ្វើជាគំរូដល់ការអាន វិធីសាស្ត្របង្រៀនរបស់គ្រូមិនជំរុញដល់ការអាន និងបញ្ហាបណ្ណាល័យនៅក្នុងសាលារៀន។

### ៤.១.៤.៣ វិធីសាស្ត្របណ្តុះទម្លាប់អាន

ទម្លាប់អានរបស់មនុស្សគ្រប់រូប មិនមែនកសាងឡើងមួយថ្ងៃពីរនោះទេ វាទាមទារឱ្យអ្នករាល់គ្នា អនុវត្តការអាននេះជាប្រចាំទៅលើអ្វីដែលខ្លួនពេញចិត្តនិងចាប់អារម្មណ៍ក្នុងការអាន។ នៅក្នុងនោះដែរ មានវិធីសាស្ត្រជាច្រើនដើម្បីបណ្តុះទម្លាប់អាននេះ។ ហើយតាមរយៈការសម្ភាសទៅកាន់អ.ក.ជ១ អ្នកស្រាវជ្រាវបានទទួលទិន្នន័យពីវិធីសាស្ត្របណ្តុះទម្លាប់អានរបស់សិស្សអាចប្រព្រឹត្តទៅបាន លុះត្រាតែក្រសួង ស្ថាប័ន ដែលទាក់ទងនឹងអំណានផលិតសៀវភៅឱ្យមានភាពចម្រុះនៃប្រធានបទ ដើម្បីបំពេញទៅតាមចំណង់ចំណូលចិត្តរបស់

អ្នកអានបាន។ បន្ថែមពីនេះ ក៏ត្រូវបណ្តុះបណ្តាលអ្នកជំនាញអានផងដែរ ហើយជាមួយគ្នានេះ គាត់បានបញ្ជាក់បន្ថែមថា គ្រូគឺជាគំរូល្អដល់សិស្សក្នុងការអាន ព្រមទាំងបង្ហាត់សិស្សពីររបៀបអាន។ ហើយភារកិច្ចរបស់សាលារៀនត្រូវរៀបចំឱ្យមានម៉ោងចូលបណ្ណាល័យឱ្យបានត្រឹមត្រូវ ចៀសវាងបណ្ណាល័យបើកទ្វារឱ្យចូលអាន សិស្សរវល់រៀននៅថ្នាក់ ដល់ពេលសិស្សទំនេរ បណ្ណាល័យបិទទៅវិញ។

សរុបមក ការបណ្តុះទម្លាប់អានមិនមែនជារឿងងាយស្រួលទេ វាតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីដែលពាក់ព័ន្ធមិនថាសិស្ស គ្រូ អាណាព្យាបាលសិស្ស នាយកសាលារៀន និងអ្នកនៅថ្នាក់ក្រសួងឬស្ថាប័ននានា។

### ៤.១.៥ វត្ថុបំណងនៃសមត្ថភាពអំណាន

ការបង្រៀនក្នុងសមត្ថភាពនីមួយៗក្នុងសៀវភៅភាសាខ្មែរ ក្រសួងបានកំណត់វត្ថុបំណងជាក់លាក់ ដើម្បីឱ្យគ្រូបង្រៀនប្រើវិធីសាស្ត្រយ៉ាងណាឱ្យឈានទៅដល់ការសម្រេចវត្ថុបំណងទាំងនោះ។ ជាក់ស្តែង ការបង្រៀនមុខវិជ្ជាភាសាខ្មែរនៅថ្នាក់ទី៧ ចំពោះសមត្ថភាពអំណាន អ.ក.គបានបង្ហាញថា ពួកគាត់ប្រឹងប្រែងបង្រៀនដោយប្រើវិធីសាស្ត្រផ្សេងៗ ដើម្បីឱ្យសិស្សចេះអានពាក្យ អានអត្ថបទ យល់ខ្លឹមសារអត្ថបទ និងតម្លៃអប់រំ។ បន្ថែមពីនេះទៀតសិស្សមានសមត្ថភាពក្នុងការអានដោយមានការលើកដាក់សំឡេងបានត្រឹមត្រូវនិងពេលពួក

គេអានចប់ ពួកគេអាចដឹងច្បាស់ថាអត្ថបទនោះ អ្នកនិពន្ធចង់និយាយអំពីអ្វី។

សរុបសេចក្តីមក ការបង្រៀនសមត្ថភាពអំណាននៅថ្នាក់ទី៧នេះ វត្ថុបំណងដែលគ្រូចង់បានគឺឱ្យសិស្សចេះអានពាក្យបានត្រឹមត្រូវ ចេះអានអត្ថបទដោយមានការលើកដាក់សំឡេងបានល្អ និងយល់ន័យរបស់ពាក្យឬអត្ថបទ។

### ៤.១.៦. ដំណើរការនៃការបង្រៀនអំណាន

#### ៤.១.៦.១. លំនាំនៃការបង្រៀនអំណានភាសាខ្មែរ

នៅក្នុងសមត្ថភាពនីមួយៗនៃមុខវិជ្ជាភាសាខ្មែរមានលំនាំឬដំណើរការនៃការបង្រៀនមិនដូចគ្នាទេ។ តាមរយៈការសម្ភាសទៅកាន់អ្នកគ្រូទាំងពីរនាក់ដែលបង្រៀនបានបង្រៀននៅថ្នាក់ទី៧នៃសាលាអនុវិទ្យាល័យស្វាយរលំរួចមក ពួកគាត់ទាំងពីរបានបង្ហាញពីដំណើរការនៃការបង្រៀនសមត្ថភាពអំណានមានលក្ខណៈប្រហាក់ប្រហែលគ្នា ពោលគឺជំហានដំបូង ពួកគាត់ធ្វើការសិក្សាលើចំណងជើង រូបភាព សួរនាំពីទំនាក់ទំនងរូបភាពទៅនឹងចំណងជើង និងសិក្សាលើពន្យល់ពាក្យ។ បន្ទាប់មក ពួកគាត់ឱ្យសិស្សអានសំណួរត្រិះរិះនិងធ្វើការចែកក្រុម ដើម្បីពិភាក្សាទៅលើសំណួរដែលមាន។ បន្ទាប់មកទៀត សិស្សធ្វើការអានអំណាន ហើយឡើងសរសេរចម្លើយលើក្តារខៀន។ ហើយក្រោយមក គ្រូឱ្យសិស្សកត់ចម្លើយចូលសៀវភៅរៀងៗខ្លួន។ ហើយចំពោះត្រង់ចំណុចនេះ អ.ក.គ១ មិនបានឱ្យសិស្សកត់រាល់ចម្លើយនោះទេ គឺឱ្យកត់តែចម្លើយណាដែលគ្រូគិតថាសំខាន់និងចាំបាច់តែប៉ុណ្ណោះ។ ចំពោះជំហានចុងក្រោយ បើក្នុង

ករណីដែលសល់ពេលទើបគ្រូឱ្យសិស្សពីរឬបីនាក់ឡើងអានឃ្លាប្រយោគ ដើម្បីពិនិត្យទៅលើការលើកដាក់សំឡេង។ ហើយក្នុងដំណាក់កាលនេះដែរ អ.ក.គ២ បានអនុវត្តបានញឹកញាប់ជាងអ.ក.គ១ ពីព្រោះអ.ក.គ១បានចំណាយពេលដើមម៉ោងរបស់ខ្លួនបង្រៀនមូលដ្ឋានគ្រឹះស្រៈព្យញ្ជនៈ ការប្រកបពាក្យអស់រយៈពេល១៥នាទីទៅហើយ អាស្រ័យហេតុនេះ វាដូចជាគ្មានពេលគ្រប់គ្រាន់ក្នុងការអនុវត្តជំហានចុងក្រោយនេះទេ។

សរុបសេចក្តីមក ដំណើរការនៃការបង្រៀនអំណានពីជំហានមួយទៅជំហានមួយទៀតរបស់អ្នកគ្រូទាំងពីរពុំមានលក្ខណៈខុសគ្នាប៉ុន្មានទេ ប៉ុន្តែអ្វីដែលលើសខ្វះគ្នានៅត្រង់សំណួរចម្លើយដែលសិស្សត្រូវកត់ចូលសៀវភៅនិងជំហានចុងក្រោយនៃការអានអត្ថបទ ដើម្បីដឹងពីរបៀបនៃការលើកដាក់សំឡេងតែប៉ុណ្ណោះ។

### ៤.១.៦.២. របៀបនៃការអនុវត្តអំណាន

របៀបនៃការអានមានច្រើនបែបច្រើនយ៉ាង ដោយក្នុងនោះមានការអានស្ងាត់ ការអានឮ ការអានបណ្តាក់គ្នាជាដើម។ ហើយចំពោះបែបបទនៃការអានទាំងនោះខុសៗគ្នាដោយសារតែវាអាស្រ័យទៅលើវត្ថុបំណងដែលគ្រូចង់ឱ្យសិស្សអភិវឌ្ឍទៅលើចំណុចអ្វី។ ឧទាហរណ៍ គ្រូឱ្យសិស្សអានអត្ថបទស្ងាត់ៗក្នុងបំណងឱ្យសិស្សប្រមូលអារម្មណ៍ផ្តោតទៅលើអត្ថន័យនិងមិនបង្កជាសំឡេងរំខានដល់អ្នកដទៃ។ ហើយចំពោះដំណើរការបង្រៀនសមត្ថភាពអំណានរយៈពេលពីរម៉ោងនេះ អ.ក.គ នៅកម្រិតថ្នាក់ទី៧នៃសាលាអនុវិទ្យាល័យស្វាយរលំបានប្រើរបៀបឬ

ទិចនិចនៃការអានលាយចម្រុះគ្នា ពោលគឺមានទាំងឱ្យសិស្សអានស្ងាត់លើអត្ថបទ ដើម្បីរកពាក្យពិបាក អានឮៗ អានបណ្ដាក់គ្នាចម្រុះសមត្ថភាពសិស្សនៅពេលអានអំណានត្រៀមឆ្លើយនឹងសំណួរផងដែរ។

សរុបសេចក្ដីមក ការប្រើរបៀបឬទិចនិចដើម្បីឱ្យសិស្សអានរបស់គ្រូទាំងពីរមិនខុសគ្នាទេ ដែលក្នុងនោះមានទាំងការអានស្ងាត់ អានឮៗ និងអានបណ្ដាក់គ្នា។

## ៤.២ នីតិវិធីដែលជួយលើកកម្ពស់សមត្ថភាពអំណានភាសាខ្មែរ

បែបផែននៃការប្រព្រឹត្តទៅក្នុងការជួយលើកកម្ពស់អំណានភាសាខ្មែរដែលទទួលបានពីការសម្ភាសរបស់អ្នកចូលរួម អ្នកស្រាវជ្រាវបានសិក្សាឃើញពីរចំណុច៖ (១) នីតិវិធីដែលធ្លាប់អនុវត្តកន្លងមកក្នុងការលើកកម្ពស់អំណាននិង(២) នីតិវិធីដែលនឹងអនុវត្តបន្តដើម្បីលើកម្ពស់អំណាន។ នៅខាងក្រោមនេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីសេចក្ដីលម្អិតទៅលើយន្តការទាំងពីរ។

### ៤.២.១. នីតិវិធីដែលធ្លាប់អនុវត្តកន្លងមកក្នុងការលើកកម្ពស់សមត្ថភាពអំណាន

សមត្ថភាពអានពិតជាសំខាន់ណាស់ នៅក្នុងការសិក្សាអំពីភាសា។ ចំណុចនេះ ត្រូវបានគេគិតគូរនិងរកវិធីសាស្ត្រពង្រឹងសមត្ថភាពសិស្សតាំងពីនៅកម្រិតបឋមសិក្សាមកម្ល៉េះ។ ហើយនៅក្នុងនោះ នាពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អ្នកស្រាវជ្រាវឃើញថា ក្រសួងអប់រំ យុវជន និង

កីឡាបានពង្រឹងកាន់តែខ្លាំង ដោយបង្កើតឱ្យមានកម្មវិធីអំណានដំបូងនិងគណិតដំបូងនៅក្នុងកម្រិតបឋមសិក្សាទៀតផង។ ប៉ុន្តែទោះជាយ៉ាងនេះក្តី សមត្ថភាពអំណានរបស់សិស្សដែលបន្តការសិក្សាទៅដល់កម្រិតអនុវិទ្យាល័យនៅតែជួបបញ្ហាមួយចំនួនគួរឱ្យកត់សំគាល់។ អាស្រ័យហេតុនេះបានជាពេលដែលអ្នកស្រាវជ្រាវធ្វើការសម្ភាស អ្នកស្រាវជ្រាវទទួលបានទិន្នន័យមួយចំនួនពីអ.ក.គបន្ថែមអំពីនីតិវិធីដែលពួកគាត់ធ្លាប់អនុវត្តកន្លងមក ក្នុងការជួយលើកកម្ពស់សមត្ថភាពអំណានភាសាខ្មែរនេះ។ អ.ក.គ បានបង្ហាញថា ដើម្បីជួយឱ្យសិស្សរបស់ពួកគាត់បានអនុវត្តការអាននិងមានភាពរីកចម្រើនចំពោះសមត្ថភាពអំណាននេះ គាត់បានឱ្យកូនសិស្សហាត់អានពាក្យពិបាកជាមួយគាត់ច្រើនដងក្នុងម៉ោងរៀន ហើយក៏បានចំណាយពេលខ្លះដើម្បីសរសេរពាក្យពិបាកមួយចំនួនលើក្ដារឆ្នួនឬឆ្លៀតសរសេរតាមអានជាដើម។ បន្ថែមពីនេះទៀតចំពោះអ.ក.គ១ថែមទាំងដាក់ឱ្យមានការហ្វឹកហាត់ការអានអត្ថបទខ្លីជាក្រុមនិងនៅដើមម៉ោងសិក្សាប្រហែល១៥នាទីរៀងរាល់ម៉ោងសិក្សាភាសាខ្មែរ គាត់បានបង្រៀនមូលដ្ឋានគ្រឹះនៃអំណាន ដូចជាការបង្ហាញពីព្យញ្ជនៈ ស្រៈ ការប្រកបពាក្យជាដើម។ ហើយនៅពេល លោកនាយកមានការប្រជុំអាមួយអាណាព្យាបាលសិស្ស គាត់ក៏បានប្រាប់ទៅអាណាព្យាបាលសិស្សឱ្យចូលរួមតាមដាន និងជំរុញបន្ថែមទៅលើសកម្មភាពអានរបស់កូនគាត់នៅផ្ទះផងដែរ។ ជាក់ស្តែងអ.ក.គ១បាននិយាយថាៈ

រាល់ម៉ោងបង្រៀន ខ្ញុំតែងចំណាយពេលប្រាំនាទីក្នុងការរំលឹកព្យញ្ជនៈ ស្រៈ ឧស្សាហ៍ឱ្យ

សិស្សសរសេរពាក្យពិបាកនិងពាក្យដែលប្រើក្នុងជីវិភាពរស់នៅប្រចាំថ្ងៃលើក្ដារឆ្នួន រួច ប្រកប អានឱ្យសិស្សស្ដាប់ រួចសិស្ស ប្រកប អានជាក្រោយ។ ពេលអានស្ទាត់ខ្ញុំតែងដើរ ទៅជិតសិស្សខ្សោយអំណានរួចប្រាប់គាត់ឱ្យរកពាក្យពិបាក រួចខ្ញុំសរសេរពាក្យពិបាក ដាក់លើកក្ដារខៀននិងអានវាបីឬបួនដងឱ្យសិស្សស្ដាប់។ ខ្ញុំក៏ឧស្សាហ៍ហៅសិស្ស ខ្សោយឡើងអាននិងតែងលើកទឹកចិត្តពួកគេឱ្យចូលរួមអាន ហើយទៅផ្ទះរៀនអានបី បួនបន្ទាត់បើពាក្យណាអត់ចេះ ភ្លេចកូនអាចមកសួរអ្នកគ្រូបាន និងបាននិយាយ ណែនាំកូនសិស្សរបស់ខ្ញុំឱ្យពួកគេទិញសៀវភៅណាដែលពួកគេចូលចិត្តមកអាន។ ជាមួយគ្នានេះដែលពេលប្រជុំជាមួយអាណាព្យាបាលឱ្យជួយទិញសៀវភៅឱ្យកូនៗ ផង ហើយខ្ញុំតែងចុះហត្ថលេខាលើសៀវភៅនិងបន្ថែមពិន្ទុឱ្យពួកគេដែរពីព្រោះវាជា ការលើកទឹកចិត្តគាត់។(អ.ក.គ១)

រីឯបែបផែនដែលអ.ក.គ២ បានអនុវត្តកន្លងមកក្នុងការលើកកម្ពស់សមត្ថភាពអំណាន របស់សិស្សគាត់វិញ គឺគាត់តែងតែធ្វើការលើកទឹកចិត្តសិស្សខ្សោយឱ្យចូលរួមអាន ព្រមទាំង ឆ្លៀតជួយសិស្សខ្សោយឱ្យអានចំពោះមុខគាត់នៅពេលម៉ោងចេញលេង។

សរុបសេចក្ដីមក យន្តការដែលអ.ក.គធ្លាប់អនុវត្តកន្លងមកក្នុងការលើកកម្ពស់សមត្ថភាព អំណានមាន៧ចំណុច ពោលគឺការជួយបង្រៀនមូលដ្ឋានគ្រឹះនៅរាល់ដើមម៉ោងសិក្សា ការឱ្យ សិស្សហាត់អានពាក្យពិបាកនិងសរសេរពាក្យពិបាកលើក្ដារឆ្នួន ការឱ្យសិស្សហ្វឹកហាត់ការអាន

អត្ថបទខ្លីជាក្រុម ការលើកទឹកចិត្តសិស្សខ្សោយឱ្យបានចូលរួមអាន ការជំរុញអាណាព្យាបាលសិស្សឱ្យចូលរួមជួយការអានរបស់កូនគាត់នៅផ្ទះ និងការឆ្លៀតជួយសិស្សខ្សោយអំណាននៅក្នុងម៉ោងចេញលេង។

### ៤.២.២. វិធីសាស្រ្តដែលនឹងអនុវត្តបន្តដើម្បីលើកកម្ពស់សមត្ថភាពអំណាន

សមត្ថភាពអានរបស់សិស្សនៅតែមានកម្រោយគួរឱ្យកត់សំគាល់ ទោះបីជាពួកគេរៀនដល់កម្រិតអនុវិទ្យាល័យក៏ដោយ។ ហេតុដូចនេះ គ្រប់ភាគីពាក់ព័ន្ធត្រូវតែពិចារណាទៅលើយន្តការបន្តទៀតដែលត្រូវនឹងអនុវត្តដើម្បីលើកកម្ពស់សមត្ថភាពអំណានទៅថ្ងៃខាងមុខ។ ជាក់ស្តែងតាមរយៈការសម្ភាសអ្នកចូលរួមក្នុងការសិក្សានេះ អ្នកស្រាវជ្រាវបានទទួលទិន្នន័យសំខាន់ៗជាច្រើនដែលនឹងត្រូវអនុវត្ត ដើម្បីជួយលើកកម្ពស់សមត្ថភាពអំណានរបស់សិស្ស។ នៅក្នុងនេះដែរអ្នកស្រាវជ្រាវបានទទួលទិន្នន័យបញ្ជាក់ពីអ.ក.អា៣ អ.ក.អា៦ អ.ក.គ១ និងអ.ក.ជំ១នូវគំនិតរួមគ្នាមួយថា ការបណ្តុះទម្លាប់អានដល់សិស្សជាកត្តាសំខាន់ដើម្បីលើកកម្ពស់សមត្ថភាពអានរបស់សិស្ស ដោយក្នុងនោះ គ្រូត្រូវឈ្វេងយល់ពីវិធីសាស្រ្តបង្រៀនផ្សេងទៀតដែលជំរុញការអានបានល្អនិងមានទម្លាប់អាន។ ព្រមជាមួយគ្នានេះដែរ ក្នុងនាមជាគ្រូត្រូវធ្វើជាគំរូល្អក្នុងការអានដល់សិស្ស និងជំរុញការអានរបស់សិស្សនៅផ្ទះបន្ថែមផង។ ទន្ទឹមនឹងនេះ អាណាព្យាបាលក៏ជាចលករមួយដ៏សំខាន់ក្នុងការជំរុញការអានរបស់កូនគាត់។ បន្ថែមពីនេះទៀត អ.ក.គនិង

អ.ក.ជំ បានមានគំនិតរួមគ្នាមួយដែរ ទៅលើគោលជំហរអំពីការជួយរបស់ក្រសួងអប់រំ យុវជន និងកីឡា ហើយការជួយនេះ ពួកគាត់បានបញ្ជាក់ថា ក្រសួងគួរគិតពីការកំណត់ចំនួនសិស្សក្នុងមួយថ្នាក់ៗត្រឹមតែ៣៥នាក់ចុះក្រោមបានហើយ នោះវាជាកត្តាមួយដែលអាចឱ្យគ្រូមានលទ្ធភាពអាចជួយសិស្សបានពេលលេញ ហើយការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗដែលជំរុញដល់ការអាននឹងអាចប្រើប្រាស់បានច្រើនផងដែរ។ ពិសេសជាងនេះ ពួកគាត់មានបំណងចង់ឱ្យក្រសួងប្រើប្រាស់បណ្តាញសង្គមក្នុងការគាំទ្រដល់ការអាន និងបើសិនអាច ក្រសួងមានលទ្ធភាពក៏គួរតែពិនិត្យឡើងវិញទៅលើសៀវភៅគោលភាសាខ្មែរសព្វថ្ងៃ ហើយក្រសួងក៏នឹងត្រូវតែពិចារណាទៅលើការបង្កើតសៀវភៅជំនួយបន្ថែមទៅលើសៀវភៅគោល ដែលទាក់ទងនឹងលំហាត់។ ជាក់ស្តែង អ.ក.គ១និងអ.ក.ជំ២ បានលើកឡើងថា៖

*"ប្រសិនជាសិស្សចូលចិត្តមើលsocial media វិស័យអប់រំគួរតែធ្វើជាវីដេអូបង្ហាញពីការអប់រំនឹងអត្ថប្រយោជន៍អានបង្ហោះតាមប្រព័ន្ធបណ្តាញសង្គមទាំងនោះ(facebook TiK Tok) និងសូមឱ្យក្រសួងគិតគូរឡើងវិញពីចំនួនសិស្សនៅក្នុងថ្នាក់នីមួយៗកុំឱ្យដាក់សិស្សច្រើនពេកក្នុងមួយថ្នាក់ៗទូទាំងប្រទេសកម្ពុជា។"(អ.ក.គ១)*

*"ហើយហ្នឹងទីប្រាំនៅថ្នាក់ទី៤ ៥ ៦ ឡើងទៅត្រូវប្រើវិធីសាស្ត្របែបដាក់គម្រោងឱ្យសិស្សធ្វើដូចម្តែងនិយាយមិញ ដោយឱ្យមានការបង្រៀនបញ្ចូលការស្រាវជ្រាវនិងបង្រៀនប្រើវិធីសាស្ត្របង្រៀនបែបទំនើបហ្នឹងលាយចូលមកខ្លះ បែកឌីជីថលអីមកខ្លះ។"(អ.ក.ជំ២)*

លើសពីនេះទៀត  អ.ក.គ១និងអ.គ.ជំ១មានគំនិតរួមគ្នាមួយទៀតដែរទៅលើការពង្រឹងគុណភាពបណ្ណាល័យដែលអាចជួយលើកកម្ពស់សមត្ថភាពអានរបស់សិស្ស ហើយក្នុងចំណុចនេះដែរ គឺត្រូវបង្កើតឱ្យមានបណ្ណាល័យដែលមានគុណភាពនៅក្នុងថ្នាក់រៀនផ្ទាល់(កៀនថ្នាក់) សាលារៀន និងនៅផ្ទះ។ ហើយចំណុចពីរទៀតដែលអ.ក.គ១បានលើកមកបន្ថែម នោះ គឺសិស្សត្រូវមានស្មារតីភ្ញាក់រឭកដោយខ្លួនឯងទៅលើការហ្វឹកហាត់ការអាននេះហើយប្រសិនបើអាចខាងសាលារៀនគួរតែកាត់បន្ថយបន្ទុកការងារគ្រូឬមានគ្រូជំនួយរដ្ឋបាលម្នាក់ទៀត ដែលនេះជាហេតុធ្វើឱ្យគ្រូមានពេលគ្រប់គ្រាន់ក្នុងការជួយដល់សមត្ថភាពអានរបស់សិស្សបន្ថែមទៀត។

សរុបមក តាមរយៈការសម្ភាស អ្នកស្រាវជ្រាវទទួលបានយន្តការចម្បងៗចំនួន៥ដែលនឹងត្រូវអនុវត្ត ដើម្បីលើកកម្ពស់អំណានភាសាខ្មែរ ដែលក្នុងនោះរួមមាន ការបណ្ដុះទម្លាប់អានដល់សិស្ស  គោលជំហរនៃការជួយពីក្រសួងអប់រំ យុវជន និងកីឡា (ជួយគិតគួរបន្ថយចំនួនសិស្សក្នុងមួយថ្នាក់ៗ ការបង្កើតកម្មវិធីគាំទ្រដល់ការអានដាក់ក្នុងបណ្ដាញសង្គមផ្សេងៗ) ការពង្រឹងគុណភាពបណ្ណាល័យ(កៀនថ្នាក់ សាលារៀន និងនៅផ្ទះ) ការដែលសិស្សត្រូវមានស្មារតីភ្ញាក់រឭកដោយខ្លួនឯងចំពោះការហ្វឹកហាត់ការអាន  និងការដែលខាងសាលារៀនគួរគិតគូរពីការបន្ថយបន្ទុកការងារគ្រូឬមានគ្រូជំនួយរដ្ឋបាលម្នាក់ទៀត។

# ជំពូក ៥៖ ការពិភាក្សា

នៅក្នុងជំពូកនេះសរសេរឡើងក្នុងបំណងពិភាក្សារវាងលទ្ធផលដែលការសិក្សានេះរកឃើញជាមួយលទ្ធផលនៃការសិក្សាផ្សេងទៀតដែលមានបង្ហាញក្នុងជំពូកទី២ ហើយលទ្ធផលនៃការសិក្សាទាំងពីរអាចមានទំនាក់ទំនងគ្នានិងប្លែកគ្នាមួយចំនួនដែរ។ នៅក្នុងលទ្ធផលនៃការសិក្សានេះផងដែរ អ្នកស្រាវជ្រាវបានបែងចែកគំនិតសំខាន់ជាពីរចម្បងៗ ហើយនៅក្នុងនោះមានគំនិតសំខាន់តូចៗជាច្រើនបន្ថែមទៀត ដែលសុទ្ធតែគាំទ្រឱ្យប្រធានបទនៃការស្រាវជ្រាវនេះ។ ចំពោះក្នុងជំពូកទី៥ អ្នកស្រាវជ្រាវបានបែងចែកគំនិតសំខាន់ជាប្រាំចំណុចដែលចាប់ផ្តើមពី៥.១រហូតដល់៥.៥។ ក្នុងចំណុច៥.១ អ្នកស្រាវជ្រាវបានធ្វើការពិភាក្សាអំពីបញ្ហាប្រឈមនៃការអាន ៥.២ បានពិភាក្សាផ្តោតលើលំនាំនៃការបង្រៀនដែលជំរុញការអានប្រកបដោយប្រសិទ្ធភាព ៥.៣ ពិភាក្សាផ្តោតលើវត្ថុបំណងនៃការបង្រៀនសមត្ថភាពអំណាន ៥.៤ ពិភាក្សាទៅលើឥរិយាបថនៃការអានរបស់សិស្ស ហើយចំណុច៥.៥ ពិភាក្សាផ្តោតលើមូលហេតុចម្បងៗដែលសិស្សមិនមានទម្លាប់អាន។

## ៥.១ បញ្ហាប្រឈមនៃការអាន

នៅក្នុងការសិក្សាស្រាវជ្រាវនេះបានរកឃើញពីបញ្ហាប្រឈមនៃការអានមួយចំនួនដែលក្នុនោះរួមមាន៖ បញ្ហាសិស្សផ្ទាល់មិនយកចិត្តទុកដាក់ ខ្ជិលក្នុងការអាន បញ្ហាសាលារៀន

នាយកសាលាមិនដឹកនាំរៀបចំ ឬជំរុញដល់ការអាន ហើយគ្រូបង្រៀនទៀតសោតក៏ប្រើវិធីសាស្ត្របង្រៀនអំណានបែបប្រពៃណី បញ្ហាគ្រួសាររបស់សិស្សដែលអាណាព្យាបាលមិនយកចិត្តទុកដាក់ជំរុញបន្ថែមក៏ដូចជាមើលការខុសត្រូវលើការសិក្សារបស់កូន បញ្ហាសិស្សខ្វះមូលដ្ឋានគ្រឹះទាក់ទងនឹងសមត្ថភាពអំណានតាំងពីថ្នាក់បឋមសិក្សា បញ្ហាបណ្ណាល័យនៅសាលារៀនដែលមិនមានការៀបចំឱ្យមានភាពទាក់ទងនិងខ្វះខាតសៀវភៅជាដើម  បញ្ហាសង្គមខ្វះការឱ្យតម្លៃលើការអាន និងកត្តាសៀវភៅគោលដែលផលិតមកមានខ្លឹមសារមិនគួរជាទីទាក់ទាញដល់អ្នកអានក៏ដូចជាអ្នកសិក្សា។ បញ្ហាប្រឈមដែលរកឃើញទាំងប៉ុន្មានខាងលើមិនខុសគ្នាពីការរកឃើញរបស់AliនិងIbrahin (2019) ដែលសិក្សាស្រាវជ្រាវលើបញ្ហាប្រឈមដល់ការអានអត្ថបទរបស់សិស្សនៅចន្លោះវ័យ១៥ឆ្នាំដល់១៧ឆ្នាំ ក្នុងព្រះរាជាណាចក្រម៉ារ៉ុកនោះទេ។ ប៉ុន្តែអ្វីដែលAliនិងIbrahim រកឃើញប្លែកពីការសិក្សានេះ គឺសិស្សមានបញ្ហាប្រឈមក្នុងការអានអត្ថបទដោយសារភាពពិបាកជាមួយនឹងវាក្យសព្ទនិងវេយ្យាករណ៍ដែលមានក្នុងអត្ថបទ។ ទន្ទឹមនឹងគ្នានេះដែរ ការស្រាវជ្រាវ, Mubashir et al. (2015) ក៏បានបង្ហាញពីបញ្ហាប្រឈមនៃការអានមកពីបញ្ហាមិនយល់វាក្យសព្ទនិងទម្រង់វេយ្យាករណ៍ ដែលដូចនឹងការរកឃើញរបស់AliនិងIbrahimផងដែរ។ ហើយចំណុចពីរទៀតដែលការស្រាវជ្រាវរបស់ Mubashir, Bahram, Mehswish និងFakharh (2015) រកឃើញដូចការសិក្សានេះ គឺបញ្ហាប្រឈមនៃវិធីសាស្ត្របង្រៀននិងការមិនទម្លាប់អានរបស់សិស្សដែលជាហេតុធ្វើឱ្យសិស្សមានបញ្ហាប្រឈមក្នុងការអាន។

## ៥.២ លំនាំនៃការបង្រៀនដែលជំរុញការអានប្រកបដោយប្រសិទ្ធភាព

ទាក់ទងនឹងលំនាំនៃការបង្រៀនអំណានប្រកបដោយប្រសិទ្ធភាពនេះ ការស្រាវជ្រាវរបស់AliនិងIbrahim (2019) បានបង្ហាញពីលំនាំបង្រៀនដែលចាប់ផ្ដើមពីការបង្រៀនវាក្យសព្ទទៅកាន់សិស្ស បន្ទាប់មកឱ្យសិស្សធ្វើការទស្សន៍ទាញដោយផ្អែកលើចំណេះដឹងមានស្រាប់ ហើយបន្តឱ្យសិស្សអានអត្ថបទត្រួតៗដើម្បីស្រង់នូវចំណុចសំខាន់ៗ បន្ទាប់មកនៅជំហានចុងក្រោយគឺឱ្យសិស្សអានអត្ថបទលម្អិត ដើម្បីឆ្លើយតបនឹងសំណួរនិងអាចធ្វើលំហាត់បាន។ លំនាំនៃការបង្រៀននេះមិនខុសគ្នាប៉ុន្មានពីការរកឃើញរបស់ស្រាវជ្រាវនេះទេ ព្រោះលំនាំនៃការបង្រៀនអំណានក្នុងភាសាខ្មែរមានជំហានដំបូងដែលឱ្យសិស្សយល់ពីវាក្យសព្ទនៃអត្ថបទ បន្ទាប់មកឱ្យសិស្សអានអត្ថបទត្រួតៗនិងអានលម្អិតបន្ថែមទៀត ដើម្បីអានឆ្លើយសំណួរលើអត្ថបទបានផងដែរ។ ហើយលំនាំបង្រៀនអំណានក្នុងភាសាខ្មែរលើសពីលំនាំបង្រៀនរបស់ AliនិងIbrahimនោះ គឺនៅត្រង់ជំហានចុងក្រោយក្នុងការបង្រៀនអំណានមានសកម្មភាពមួយដែលឱ្យសិស្សពីរទៅបីនាក់ឡើងអានឃ្លាឬល្បះមួយចំនួនឡើងវិញឱ្យលឺ ដើម្បីចង់ដឹងពីសមត្ថភាពនៃការលើកដាក់សំឡេងរបស់សិស្ស។

## ៥.៣ វត្ថុបំណងនៃការបង្រៀនសមត្ថភាពអំណាន

វត្ថុបំណងបំណងនៃសមត្ថភាពអំណានដែលការសិក្សាស្រាវជ្រាវនេះបានរកឃើញ វា

មិនមានភាពខុសប្លែកពីវត្ថុបំណងនៃសមត្ថភាពអំណានដែលក្រសួងអប់រំ យុវជន និងកីឡាបានបោះពុម្ពឆ្នាំ២០១៨នោះទេ។ អាស្រ័យហេតុនេះ វាបានន័យថាគ្រូបង្រៀននៅកម្រិតថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំបានយល់ច្បាស់ពីវត្ថុបំណងនៃការបង្រៀនសមត្ថភាពអំណានរបស់ក្រសួងបានកំណត់ ដោយពួកគាត់ខិតខំបង្រៀនឱ្យសិស្សចេះអានពាក្យ ចេះអានអត្ថបទគ្រប់ប្រភេទ យល់ពីខ្លឹមសារនៃអត្ថបទ និងតម្លៃអប់រំផងដែរ។ ប៉ុន្តែគ្រាន់តែជាលទ្ធផល សិស្សមានបញ្ហាច្រើនទៅការយល់ន័យរបស់ពាក្យនិងអត្ថបទ។

## ៥.៤ ឥរិយាបថនៃការអានរបស់សិស្ស

ឥរិយាបថនៃការអានរបស់សិស្សដែលបានរកឃើញនៅក្នុងការស្រាវជ្រាវនេបានបង្ហាញថាសិស្សនៅក្នុងកម្រិតថ្នាក់ទី៧មិនសូវចូលចិត្តការអាននោះទេ ដោយក្នុងមួយថ្ងៃ ពួកគេចំណាយពេលក្នុងការអានមិនលើសពី៣០នាទីនោះទេ។ ហើយបើតាមការសិក្សាស្រាវជ្រាវរបស់Hay (2017)ក៏បានបង្ហាញថាសិស្សនៅកម្រិតថ្នាក់មធ្យមសិក្សាមិនសូវចូលចិត្តការអានដូចគ្នា ពោលគឺពួកគេចំណាយពេលអានប្រហែលមួយម៉ោងឬតិចជាងនេះនៅក្នុងមួយថ្ងៃ។ បន្ថែមពីនេះទៀតទំនោរនៃការចូលបណ្ណាល័យអានសៀវភៅដែលរកឃើញតាមរយៈការសិក្សាស្រាវជ្រាវនេះនិងការសិក្សាស្រាវជ្រាវរបស់ Hay (២០១៧)ក៏បានបង្ហាញពីភាគរយតិចតួចនៃចំនួនសិស្សចូលចិត្តការចូលបណ្ណាល័យ ប៉ុន្តែមូលហេតុដែលសិស្សមិនចូលចិត្តការចូលបណ្ណាល័យនៅក្នុងការសិក្សាមួយនេះគឺដោយសារការមើលបំណាំគ្នា។ ជាក់ស្តែងមានសិស្សម្នាក់បានបង្ហាញថាការ

ចូលបណ្ណាល័យអានសៀវភៅ មិនសូវមានសិស្សដទៃចូលទេ ដូចនេះ ពេលគេចូលម្នាក់ឯងមានអារម្មណ៍ថាខុសគេ ហើយយូរៗទៅ គេក៏ខ្ជិលចូលបណ្ណាល័យអានដែរ។ រីឯមូលហេតុនៃការស្រាវជ្រាវរបស់ Hay (2017)បានបង្ហាញថាមូលហេតុនៃការចូលអានសៀវភៅក្នុងបណ្ណាល័យនៅមានកម្រិតក៏ដោយសារការប្តេជ្ញាចិត្តទាបក្នុងការអាននិងដោយសារបញ្ហាបណ្ណាល័យបើកតែចំពេលពួកសិស្សរៀន ហើយមួយវិញទៀតបណ្ណាល័យខ្លះមិនបានបើកជាប្រចាំ ព្រមទាំងបញ្ហាកង្វះខាតសម្ភារៈអានផងដែរ។ លើសពីនេះទៀត ឥរិយាបថដែលសិស្សឧស្សាហ៍អនុវត្តប្រចាំថ្ងៃជាជាងការអាននៅក្នុងការសិក្សាស្រាវជ្រាវទាំងពីរនេះមានចំណុចប្រហាក់ប្រហែលគ្នាត្រង់ចំណុចដែលសិស្សពុំមានទម្លាប់អានសៀវភៅជាប្រចាំដូចនឹងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាដើម្បីកម្សាន្ត។ ជាការពិត តាមលទ្ធផលនៃការស្រាវជ្រាវនេះផ្ទាល់បានបង្ហាញថា សិស្សតែងចំណាយពេលច្រើនក្នុងការលេងទូរស័ព្ទ (លេងGame Facebook YouTube Tik Tok) ។ រីឯ ការសិក្សារបស់ Hay (2017)បានបង្ហាញថារវាងការអានសៀវភៅនិងការមើលទូរទស្សន៍ សិស្សបានឱ្យអាទិភាពទៅលើការមើលទូរទស្សន៍ទៅវិញ។

## ៥.៥ មូលហេតុចម្បងៗដែលសិស្សមិនមានទម្លាប់អាន

មូលហេតុចម្បងៗដែលធ្វើឱ្យសិស្សមិនមានទម្លាប់អានក្នុងការសិក្សាស្រាវជ្រាវនេះមានប្រាំចំណុច រួមមាន៖ សិស្សមិនមានទម្លាប់អានតាំងពីតូច សិស្សផ្ទាល់គ្មានពេលនិងមិនមានអារម្មណ៍ក្នុងការផ្ចង់នៅពេលអានបានល្អ គ្រួសារ សាលារៀន និងសង្គមមិនបានធ្វើជាគំរូល្អ

ចំពោះការអាន វិធីសាស្រ្តបង្រៀនរបស់គ្រូមិនជំរុញដល់ការអាន និងបញ្ហាបណ្ណាល័យនៅសាលារៀន។ រីឯការស្រាវជ្រាវរបស់លោកសុផលក្នុងឆ្នាំ២០១២ ដែលសិក្សាទៅលើទម្លាប់អានរបស់សិស្សខ្មែរនៅវិទ្យាល័យបានបង្ហាញពីមូលហេតុដែលសិស្សមិនមានទម្លាប់អានចំនួនពីរស្រដៀងគ្នាទៅនឹងការស្រាវជ្រាវនេះ។ មូលហេតុទីមួយ គឺកត្តាទម្លាប់របស់បុគ្គល ដែលអាចនិយាយបានថាមិនទម្លាប់អានតាំងពីតូច ឬមិនចេះពីរបៀបផ្ចង់អារម្មណ៍ក្នុងការអាន។ ហើយចំពោះមូលហេតុទីពីរ គឺកត្តាកង្វះខាតការជំរុញនិងលើកទឹកចិត្តក្នុងការអានពីសំណាក់ឪពុកម្តាយគ្រូបង្រៀន និងសហគមន៍ ដែលក្នុងការស្រាវជ្រាវនេះក៏បង្ហាញនូវអត្ថន័យដូចគ្នា គ្រាន់តែខុសនូវពាក្យពេចន៍នៃការបកស្រាយប៉ុណ្ណោះ។ រីឯកត្តាបួនទៀតដែលការស្រាវជ្រាវរបស់លោកសុផលឆ្នាំ២០១២ រកឃើញខុសពីការស្រាវជ្រាវនេះ គឺកត្តាចំណងប្រធានបទមិនសមស្របនឹងចំណូលចិត្តសិស្ស កត្តាអត្ថបទអំណានមានពាក្យពិបាកឬពាក្យបច្ចេកទេសច្រើននិងកត្តាអត្ថបទមានចំនួនច្រើនទំព័រ  និងកត្តាកង្វះខាតសៀវភៅសិស្ស។

# ជំពូក ៦៖ សន្និដ្ឋាន ដែនកំណត់ និងសំណូមពរ

វត្ថុបំណងនៃជំពូកទី៦នេះ គឺជាការសំយោគនិងសរុបនូវលទ្ធផលដែលសិក្សាលើសមត្ថភាពអំណានភាសាខ្មែរសិស្សថ្នាក់ទី៧ បន្ទាប់ពីបានធ្វើការបញ្ចប់និងពិភាក្សារួច។ អ្នកស្រាវជ្រាវបានបែងចែកគំនិតសំខាន់សម្រាប់បង្ហាញក្នុងជំពូកនេះជាបួនគឺ សេចក្ដីសន្និដ្ឋាន ដែនកំណត់នៃការស្រាវជ្រាវ សំណូមពរ និងសំណើសុំសម្រាប់ការសិក្សាបន្ត។

## ៦.១ សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយលទ្ធផលនៃការស្រាវជ្រាវ អ្នកសិក្សាលើប្រធាននេះ យល់ឃើញថាលទ្ធផលបានឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវក៏ដូចជាសំណួរស្រាវជ្រាវទាំងពីរបានមួយភាគធំ។ ដោយក្នុងនោះ ការសិក្សាសំណួរស្រាវជ្រាវទីមួយ ដែលចង់ដឹងពីទស្សនៈរបស់ភាគីពាក់ព័ន្ធទៅលើសមត្ថភាពអំណានភាសាខ្មែររបស់សិស្សថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំ ភាគីពាក់ព័ន្ធមិនថាគ្រូ មិនថាសិស្ស អាណាព្យាបាល ឬអ្នកជំនាញ ពួកគេមានការយល់ស្របដូចគ្នាច្រើនទៅលើផ្នែកដែលសិស្សមានកម្សោយ ទម្លាប់នៃការអាន វត្ថុបំណងនៃសមត្ថភាពអំណាន និងដំណើរការនៃការបង្រៀនអំណាន ប៉ុន្តែនៅត្រង់ចំណុចមូលហេតុនៃកម្សោយការអាន មានអ្នកជំនាញម្នាក់មិនយល់ស្របទៅលើមូលហេតុកម្សោយការអានដែលបណ្ដាលមកពីកត្តាសិស្សខ្លួនឯងនោះទេ។ ចំពោះចំណុចខ្វែងគ្នានេះ អ្នកស្រាវជ្រាវក៏មានការយល់ស្របទៅនឹងគំនិត ទស្សនៈរបស់អ្នកជំនាញម្នាក់នោះដែរ ពីព្រោះជាការពិតណាស់

សិស្សដែលស្ថិតក្នុងកម្រិតថ្នាក់ទី៧ គឺស្ថិតនៅក្រោមការមើលខុសត្រូវ ណែនាំពីគ្រូ អាណាព្យាបាល បើនិយាយឱ្យចំនោះគឺមនុស្សពេញវ័យទាំងអស់ដែលនៅជុំវិញពួកគេ។ អាស្រ័យហេតុនេះឥទ្ធិពលរបស់គ្រូ និងអាណាព្យាបាលពិតជាមានសារៈសំខាន់ណាស់ទៅលើលទ្ធផលនៃសមត្ថភាពអំណានរបស់សិស្ស។ បន្ថែមពីនេះទៀត ចំពោះសំណួរស្រាវជ្រាវទីពីរស្តីពីនីតិវិធីដើម្បីលើកកម្ពស់សមត្ថភាពអំណានរបស់គ្រូ អាណាព្យាបាល និងអ្នកជំនាញ អ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថា នីតិវិធីទាំងនោះ សុទ្ធតែជាកម្លាំងចលករជំរុញពីខាងក្រោយនៃភាសា ប៉ុន្តែចំពោះការជំរុញពីខាងក្នុងនៃភាសាពុំឃើញមានការលើកឡើងបញ្ជាក់នោះទេ។ ជាក់ស្តែងដើម្បីលើកកម្ពស់សមត្ថភាពអំណានភាសាខ្មែររបស់សិស្សទៅបាន ត្រូវមានកត្តាជំរុញពីខាងក្រៅភាសាផង និងកត្តាជំរុញពីខាងក្នុងភាសាផង។ ក្នុងនោះ យើងត្រូវទទួលស្គាល់ថា ភាសាខ្មែរមិនមែនងាយស្រួលក្នុងការសិក្សាប៉ុន្មានទេ ពីព្រោះនៅក្នុងភាសាខ្មែរ វាមានលក្ខណៈពិសេសជាច្រើនដែលទាមទារឱ្យអ្នកសិក្សា មានភាពអត់ធ្មត់ខ្ពស់ ឈ្វេងយល់ពីលក្ខណៈពិសេសទាំងនោះឱ្យគ្រប់បរិបទ តួយ៉ាងពាក្យក្នុងភាសាខ្មែរមានពាក្យជាច្រើនដែលខ្ចីពីបាលីសំស្ក្រឹត ដោយមានការសរសេរគ្រួតជើងច្រើន នាំឱ្យពិបាកប្រកប ពិបាកក្នុងការអាន ហើយពាក្យខ្លះមានសំណេរខុសពីសំណួរ ដែលវាទាមទារឱ្យមានការចងចាំបន្ថែមជាដើម។ ដូចនេះ អ្នកជំនាញអក្សរសាស្ត្រខ្មែរគ្រប់រូប ត្រូវតែមុជឱ្យដល់ជម្រៅនៃភាសាជាតិខ្លួន ហើយធ្វើការពន្យល់បង្ហាញពីគន្លឹះយ៉ាងណា ដើម្បីឱ្យអ្នកសិក្សាក្រោយៗឆាប់យល់ពីលក្ខណៈពិសេសទាំងនោះ

រួចជំរុញឈានឱ្យដល់ការអានភាសាខ្មែរកាន់តែមានភាពត្រឹមត្រូវឡើងដែលស្របនឹងកម្រិតសិក្សារបស់ពួកគេ។

សរុបសេចក្តីមក ការយល់ឃើញរបស់ភាគីពាក់ព័ន្ធទៅនឹងសមត្ថភាពនៃការអានភាសាខ្មែររបស់សិស្សថ្នាក់ទី៧ មានការយល់ឃើញស្របគ្នាច្រើន ថាសិស្សថ្នាក់ទី៧នៃវិទ្យាល័យស្វាយរលំពិតជាមានកម្សោយការភាសាខ្មែរពិតប្រាកដមែន ហើយចំពោះមូលហេតុនៃកម្សោយនោះ គឺបណ្តាលមកពីកត្តាខ្វះការយកចិត្តទុកដាក់ពីសំណាក់គ្រូបង្រៀន អាណាព្យាបាល ក៏ដូចជាមនុស្សជុំវិញខ្លួនមិនឱ្យតម្លៃទៅលើការអាន ហើយវាមិនមែនមកពីកត្តាសិស្សខ្លួនឯងនោះមួយរយភាគរយនោះទេ។ ចំណែកឯ នីតិវិធីនៃការលើកកម្ពស់នៃការអាន គឺត្រូវមានការចូលរួមពីកត្តាខាងក្រៅភាសានិងកត្តាខាងក្នុងនៃភាសា។

## ៦.២ ដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺមានដែនកំណត់របស់វា ដែលដូចអ្វីដែលបានបង្ហាញនិងពន្យល់ខាងដើមតែប៉ុណ្ណោះ។

ជាបឋម អ្នកស្រាវជ្រាវក្នុងការសិក្សានេះ គឺមានបទពិសោធថ្មីថ្មោងក្នុងការសិក្សាស្រាវជ្រាវនេះ។ សម្រាប់ហេតុផលនេះ អ្នកស្រាវជ្រាវអាចនឹងមានការវិភាគ ពិចារណានៅមិនទាន់សព្វទិដ្ឋភាពនៃបញ្ហា ហើយក៏អាចនាំអ្នកអានឬអ្នកសិក្សាផ្សេងទៀតទៅដល់ចំណេះដឹងមួយដែលមានបញ្ហាដោយអចេតនា។

បន្ទាប់មក តាមរយៈលក្ខណៈស្រាវជ្រាវមួយនេះ អ្នកស្រាវជ្រាវប្រើវិធីសាស្ត្របែបគុណវិស័យ ដែលរុករកអំពីទស្សនៈរបស់គ្រូ អាណាព្យាបាល អ្នកជំនាញ និងសិស្ស ហើយជាលទ្ធផលវាអាចធ្វើទូទៅកម្មបានត្រឹមតែកន្លែង ទំហំ និងបរិបទ ដែលវាបានសិក្សាប៉ុណ្ណោះ។ ការស្រាវជ្រាវនេះអាចខុសពីការសិក្សាដែលប្រើវិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ ដែលមានទំហំនៃការស្រាវជ្រាវធំជាងនេះ។

បន្ថែមពីនេះទៀត អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះមានតែសិស្សចំនួន៦នាក់ អាណាព្យាបាលសិស្សទាំង៦រូបនោះ គ្រូបង្រៀននៅថ្នាក់ទី៧ចំនួនពីររូប និងអ្នកជំនាញអក្សរសាស្ត្រខ្មែរចំនួន២រូបទៀតតែប៉ុណ្ណោះ។ ហើយវត្ថុបំណងនៃការស្រាវជ្រាវផ្តោតតែលើទស្សនៈនៃការយល់ឃើញពីសមត្ថភាពអំណាននៅថ្នាក់ទី៧ និងដំណោះស្រាយដើម្បីលើកកម្ពស់សមត្ថភាពអានដល់សិស្សថ្នាក់ទី៧នៃសាលាអនុវិទ្យាល័យស្វាយរលំ។

ចុងបញ្ចប់នេះ ការសិក្សាស្រាវជ្រាវមួយនេះ មានពេលវេលាកំណត់និងឯកសារនៅមានកម្រិត ហើយអ្នកស្រាវជ្រាវធ្វើការសិក្សានេះដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់របស់ខ្លួន ដែលមានការជួយពីគ្រូដឹកនាំតែម្នាក់។ អាស្រ័យហេតុនេះ លែងអីនឹងមានកំហុសនិងចំណុចខ្វះខាតកើតមាន។

## ៦.៣ សំណូមពរ

### ក. ការធ្វើបច្ចុប្បន្នភាពសៀវភៅសិក្សាគោល

សៀវភៅសិក្សាគោល គឺជាឯកសារដ៏សំខាន់មួយដែលជំរុញឱ្យការបង្រៀននិងរៀនមានប្រសិទ្ធភាព។ ជាក់ស្តែងសៀវភៅសិក្សាគោលថ្នាក់ទី៧ ត្រូវបានអនុញ្ញាតឱ្យបោះពុម្ពផ្សាយដើម្បីឱ្យសាលារៀននីមួយៗយកទៅប្រើប្រាស់តាំងពីឆ្នាំ២០០៩ ហើយបើគិតមកដល់ពេលនេះមានរយៈពេល១១ឆ្នាំហើយ។ អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡា គួរតែពិចារណាធ្វើបច្ចុប្បន្នភាពសៀវភៅសិក្សាគោលភាសាខ្មែរនេះឡើងវិញ ដោយពិនិត្យខ្លឹមសារអត្ថបទអំណានឱ្យមានលក្ខណៈប្រសើរឡើង និងបម្រើឱ្យចំណេះដឹងនាសតវត្សទី២១។ នៅក្នុងនោះដែរ អ្នកស្រាវជ្រាវស្នើឱ្យក្រសួងអប់រំ យុវជន និងកីឡាពិចារណាផងដែរ ទៅលើអំណានដែលដាក់បញ្ចូលក្នុងសៀវភៅសិក្សាគោលដោយអំណានទាំងនោះត្រូវមានខ្លឹមសារលក្ខណៈវិទ្យាសាស្ត្រនិងគតៈឱ្យបានច្រើន ហើយការរចនាលើមេរៀនអំណាននោះទៀតសោត សូមបញ្ចូលនូវលំហាត់នានាឱ្យសិស្សបានគិត វិភាគ ពិចារណា ព្រមទាំងឈានដល់ការបណ្តុះបំណិននៃការអានបានយ៉ាងរលូននិងមានបំណិននៃការគិតស៊ីជម្រៅផងដែរ។

សរុបមក ក្រសួងអប់រំ យុវជន និងកីឡា ត្រូវពិចារណាធ្វើបច្ចុប្បន្នភាពសៀវភៅសិក្សាគោលឱ្យមានភាពទាក់ទាញដល់អ្នកសិក្សា ព្រមទាំងបានបណ្តុះនូវពុទ្ធិ បំណិន និងឥរិយាបថដល់សិស្សយ៉ាងពិតប្រាកដ។

## ខ. ការផលិតគ្រូគំរូប្រចាំសាលា

កន្លងមក យើងសង្កេតឃើញថាក្រសួងអប់រំ យុវជន និងកីឡាក៏មានយន្តការនៃការផ្តល់ជារង្វាន់កិត្តិយសសម្រាប់គ្រូឆ្នើមប្រចាំប្រទេស ប្រចាំខេត្ត និងប្រចាំសាលាផងដែរ។ នៅក្នុងនោះដែរ មានការវាយតម្លៃដោយផ្តល់រង្វាន់ជាទឹកប្រាក់ និងមេដាយតំណាង(មេដាយមាស មេដាយប្រាក់ មេដាយសំរិទ្ធ)។ បន្ថែមពីនេះ ចំពោះការវាយតម្លៃគ្រូឆ្នើមប្រចាំសាលាមានគោលការណ៍ដើម្បីវិនិច្ឆ័យហើយ ប៉ុន្តែការអនុវត្តក្នុងការជ្រើសរើសមិនទាន់មានសុក្រិតភាពនៅឡើយ។ ដូចនេះ គណៈគ្រប់គ្រងសាលារៀនត្រូវគិតឡើងវិញ ដោយជ្រើសរើសឱ្យចំគ្រូឆ្នើមពិតប្រាកដ ទើបអាចធ្វើជាគំរូដល់គ្រូដទៃបាន។ ហើយគ្រូឆ្នើមពិតប្រាកដក៏មានទឹកចិត្តក្នុងការជួយគ្រូដទៃទៀតបានដែរ។ ការជ្រើសរើសគ្រូគំរូប្រចាំសាលាបានត្រឹមត្រូវ នឹងអាចមានសង្ឃឹមច្រើនក្នុងការបង្កើតឬផលិតគ្រូល្អជាបន្តបន្ទាប់ទៀតបាន។

## គ. គុណភាពបណ្ណាល័យ

បណ្ណាល័យគឺជាឃ្លាំងសម្រាប់ផ្ទុកនូវឯកសារ ក៏ដូចជាចំណេះដឹងយ៉ាងសម្បូរបែប ដែលសិស្សានុសិស្សគ្រប់រូបអាចចូលទៅអាននៅទីនោះ រួចស្រង់ចំណេះដឹង ឬដំណោះស្រាយផ្សេងៗបាន។ អាស្រ័យហេតុនេះ គុណភាពបណ្ណាល័យក្នុងសាលានីមួយៗ គួរតែបានយកចិត្តទុកដាក់ដោយគណៈគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ បណ្ណាល័យដែលគុណភាព

និងជាទីមនោរម្យដល់អ្នកអាន យើងត្រូវមើលទៅលើទីកន្លែងនិងបរិយាកាសនៃបណ្ណាល័យ សៀវភៅដែលមានក្នុងបណ្ណាល័យ ការកំណត់ម៉ោងពេលឱ្យសិស្សចូលអាន ហើយសមត្ថភាពរបស់បណ្ណារក្សក៏ជាចំណុចសំខាន់ដែលក្នុងការលើកកម្ពស់គុណភាពបណ្ណាល័យផងដែរ។ ជាក់ស្តែង បណ្ណាល័យគួរតែមានទីកន្លែងធំទូលាយ បរិស្ថានស្អាត និងមានសភាពស្ងៀមស្ងាត់ ដែលជាអំណោយផលល្អដល់អ្នកអាន។ ហើយ ចំពោះសៀវភៅវិញ គួរតែរៀបចំឱ្យមានច្រើនប្រធានបទបញ្ចូលគ្នា ដើម្បីអាចតម្រូវតាមការចូលចិត្តរបស់អ្នកអាន។ រីឯ ម៉ោងពេលនៃការឱ្យសិស្សចូលអាន គណៈគ្រប់គ្រងក៏ដូចជាបណ្ណារក្សក៏ត្រូវពិចារណារឿងហ្នឹងដែរ លៃយ៉ាងណាបើកបណ្ណាល័យចំពេលដែលសិស្សអាចចូលអានបាន។ ហើយបណ្ណារក្សក៏ត្រូវទទួលបានបណ្តុះបណ្តាលពីជំនាញនេះឱ្យបានច្បាស់លាស់ និងជាអ្នកស្រឡាញ់ការអានផងដែរ។

## ៦.៤ សំណើសុំសម្រាប់ការសិក្សាបន្ត

ការសិក្សាស្រាវជ្រាវនាពេលអនាគត គួរតែអាចកំណត់ការសិក្សាទៅលើប្រធានបទនេះទៀត ប្រសិនបើមានអ្នកស្រាវជ្រាវផ្សេងទៀតចាប់អារម្មណ៍ ដោយផ្អែកលើវិសាលភាពនៃការសិក្សាលើប្រធានបទនេះនៅខាងដើម។ ហើយអ្នកស្រាវជ្រាវបន្ទាប់ៗ គួរពិចារណាលើសំណើសុំដូចខាងក្រោម៖

ជាដំបូង ការសិក្សាបន្តបន្ទាប់ទៀត គួរតែបញ្ចូលនូវវិធីសាស្ត្រស្រាវជ្រាវតាមបែប បរិមាណវិស័យ ឬក៏វិធីសាស្ត្រចំរុះ ដើម្បីអាចធ្វើទូទៅកម្មទៅលើវិសាលភាពធំណាមួយ។ បន្ទាប់ពីនេះ ផ្នែកខ្លះនៃការរកឃើញនៅក្នុងការសិក្សានេះនៅមានចំណុចគួរឱ្យពិចារណាបន្ត និងសង្ស័យដែលគួរតែសិក្សាបន្តទៀត។

មួយវិញទៀត សំណាកគំរូគួរតែមានទំហំធំជាងនេះ និងធ្វើការស្រាវជ្រាវនៅទីកន្លែងផ្សេងទៀត។ សិស្សដែលជាអ្នកចូលរួមអាចជ្រើសរើសមកពីគ្រប់កម្រិតថ្នាក់នៃអនុវិទ្យាល័យ ខណៈនោះគ្រូបង្រៀនដែលជាអ្នកចូលរួម ក៏គួរតែរើសឱ្យមានចំនួនច្រើនជាងការស្រាវជ្រាវនេះ ហើយចំពោះអាណាព្យាបាលនិងអ្នកជំនាញក៏ត្រូវតែមានបញ្ចូលក្នុងការស្រាវជ្រាវផងដែរ។ ទន្ទឹមនឹងនេះ ចំពោះការប្រមូលទិន្នន័យទៀតសោត បើអាចគួរតែទៅជួបពួកគាត់ផ្ទាល់ ពីព្រោះការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវធ្វើការសិក្សាចំពេលប្រទេសជួបនឹងវិបត្តិកូវីដ-១៩។ ហេតុនេះ ការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវប្រើមធ្យោបាយប្រមូលតាមរយៈអនឡាញ។

បន្ទាប់មកទៀត ការសិក្សានាពេលអនាគតគួរតែធ្វើការស្រាវជ្រាវនៅទីកន្លែងផ្សេងទៀតនៃប្រទេស ហើយធ្វើឡើងទាំងនៅទីជនបទនិងទីប្រជុំជន។ ជាមួយគ្នានេះ អ្នកស្រាវជ្រាវបន្តក៏អាចមើលលើបញ្ហាទាំងនៅកម្រិតថ្នាក់បឋមសិក្សាក៏ដូចជាវិទ្យាល័យផងដែរ។

ជាពិសេសជាងនេះទៀត ការសិក្សានាពេលអនាគត គួរតែបញ្ចូលឱ្យមានកម្រង សំណួរនិងពង្រីកវិសាលភាពអ្នកចូលរួម ដើម្បីអាចមើលឃើញពីបញ្ហាបានទូលំទូលាយ។ ដូចនេះ វានាំឱ្យការសិក្សានោះកាន់តែមានភាពច្បាស់លាស់និងអាចធ្វើទូទៅកម្មបាន។ ជាមួយគ្នានេះ លទ្ធផលនៃការស្រាវជ្រាវមានភាពរឹងមាំ អាចទុកចិត្តបាន មានភាពលំអៀងតិចតួច ក្នុងការយកទៅអនុវត្តនៅក្នុងកម្មវិធី ឬគោលនយោបាយអំណាននិងទម្លាប់អានបាន។

សរុបសេចក្ដីមក ការស្រាវជ្រាវនាពេលអនាគត អាចធ្វើការសិក្សាជាបន្តបន្ទាប់ ដោយបញ្ចូលនូវវិធីសាស្ត្រស្រាវជ្រាវទីទៃពីការស្រាវជ្រាវនេះ ហើយអ្នកស្រាវជ្រាវនាពេលអនាគត ក៏អាចស្រាវជ្រាវឱ្យបានស៊ីជម្រៅជាងនេះ ដើម្បីទទួលបានលទ្ធផលដែលមានចំណុចសំខាន់ៗផ្សេងពីនេះ និងកាន់តែពិស្ដារ ច្បាស់លាស់ជាងការស្រាវជ្រាវនេះផងដែរ។

# ឯកសារយោង


ក្រសួងអប់រំ, (2018). *កម្មវិធីសិក្សាលម្អិតភាសាខ្មែរកម្រិតមធ្យមសិក្សាបឋមភូមិ*. ភ្នំពេញ:ក្រសួងអប់រំ

ក្រសួងអប់រំ, (2019). *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣*. ភ្នំពេញ:ក្រសួងអប់រំ

ក្រសួងអប់រំ, (2016). *ឯកសារជំនួយគ្រូឧទ្ទេសសម្រាប់បណ្ដុះបណ្ដាលគរុសិស្សនិងគ្រូស្ដីពីស្ដង់ដាអំណានថ្នាក់ទី១ ទី២ និងទី៣*. ភ្នំពេញ:ក្រសួងអប់រំ

ឃុត សៅ(2018, December 23).រដ្ឋមន្ត្រីក្រសួងអប់រំអះអាងថាអត្រាសិស្សមិនចេះអានអក្សរចាប់ពីថ្នាក់ទី៤ចុះក្រោមនៅមានកម្រិតខ្ពស់បើធៀបជាមួយប្រទេសនៅក្នុងតំបន់. https://www.information.gov.kh/detail/២៥១៨៦៨

ជួន ណាត, (1967). *វចនានុក្រមភាគទី1-2. ភ្នំពេញ*: ពុទ្ធសាសនបណ្ឌិត្យ

ញឹម សុផល(2015, May 12). សិស្សនៅបឋមសិក្សាត្រូវបានកត់សម្គាល់ថាកាន់តែខ្សោយការអាននិងសរសេរ. *rfi.* Retrieved from https://www.rfi.fr/km/cambodia/elementary-students-poor-reading-and-writing-12-05-2015

តុង សុប្រាជ្ញ(2017, October 17). ហេតុអ្វីបានជាកូនខ្មែរខ្លះ នៅតែប្រើភាសាខ្លួនមិនត្រូវជ្រុង ? *The Phnom penh Post*. Retrieved from https://m.postkhmer.com/វិភាគសង្គម/ហេតុអ្វីបានជាកូនខ្មែរខ្លះ-នៅតែប្រើភាសាខ្លួនមិនត្រូវជ្រុង

ឡាំ លីម, (2020). *អំណានជាអំណាច*. ភ្នំពេញ

អយក (២០១៨). ការអប់រំនៅប្រទេសកម្ពុជា៖ លទ្ធផលពីការចូលរួមរបស់ប្រទេសកម្ពុជាក្នុងកម្មវិធីអន្តរជាតិស្ដីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍. ភ្នំពេញ: អយក.

Ali, M., & Ibrahim, A. Reading Comprehension: Problems & Solutions.

Chang, Y. C., & Bangsri, A. (2020). Thai Students' Perceived Teacher Support on Their Reading Ability: Mediating Effects of Self-Efficacy and Sense of School Belonging. *International Journal of Educational Methodology*, *6*(2), 435-445.

Creswell, W. J. (2002). *Educational research: Planning, conducting, and evaluating quantitative* and *qualitative research* (4th ed.). Boston, MA: Pearson Education.

Dara, D. (2019). Investigating English Reading Comprehension Problems of Cambodian High School Students. *American International Journal of Social Science*, *8*(3), 52-56.

Dawson, C. (2007) *A Practical Guide to Research Methods a User-Friendly Manual for Mastering Research Techniques and Projects*. Oxford: How To Books. [Web.] Retrieved from the Library of Congress, https://lccn.loc.gov/2009659371.

Fraenkel, J. R., Wallen, N. E.,& Hyun, H. H. (2012). How to Design and Evaluate Research in Education. New York: McGraw-Hill.

Hoyt, L. (2009). *Revisit, reflect, retell: Time-tested strategies for teaching reading comprehension*. Heinemann.

Iqbal, M., Noor, M., Muhabat, F., & Kazemian, B. (2015). Factors responsible for poor English reading comprehension at secondary level. *Communication and Linguistics Studies*, *1*(1), 1-6.

Kirchner, E., & Mostert, M. L. (2017). Aspects of the reading motivation and reading activity of Namibian primary school readers. *Cogent Education*, *4*(1), 1411036.

Nita,H. (2017). *Factors Influencing Secondary School Students' Reading Habits*(Master's thesis). Royal University of Phnom penh.

Shea, M., & Roberts, N. (2016). Fives: an integrated strategy for comprehension and vocabulary learning. *Journal of Inquiry and Action in Education*, *8*(1), 6.

Smith, N., and Day, B. (2013, April).Keys to reading among middle school children. In *The Educational Forum* (Vol. 77, No. 2, pp. 111-121). Taylor and Francis Group.

Sophal,S. (2012). *The Challenges of Khmer Language Teaching with Student-Centered Approach of Khmer Language Teachers: Three Case Studies at High Schools in Kampong Chhnang Province* (Master's thesis). Royal University of Phnom penh.

UNDP. (2013). Retrieved, 2013, from wikipedia: https://km.m.wikipedia.org/wiki/បញ្ជី_ប្រទេស_មានចំនួនអ្នកអានសៀវភៅ

UNESCO, (2015). *Cambodia Early Reading and Writing*. United Nations Educational, Scientific and Cultural Organization 7, place de Fontenoy, 75352 Paris 07 SP, France. (http://www.unesco.org/open-access/terms-use-ccbysa-en)

Vicheika, K. (2020, February 24). Cambodia's Education Ministry Tackling Low Reading and Writing Proficiency in Secondary Students. *VOA Khmer*. Retrieved from https://www.voacambodia.com/a/cambodia-education-ministry-tackling-low-reading-and-writing-proficiency-in-secondary-students/5301115.html

# ឧបសម្ព័ន្ធ ក៖ សំណួរសម្រាប់សម្ភាស

## ពិធីសារសម្ភាស

**ប្រធានបទ៖ ទស្សនៈរបស់សិស្ស គ្រូ និងអាណាព្យាបាលចំពោះសមត្ថភាពអំណានភាសាខ្មែររបស់សិស្សថ្នាក់ទី៧នៅអនុវិទ្យាល័យស្វាយរលំ**

- ម៉ោងនៃការសម្ភាស៖……………………………………...
- កាលបរិច្ឆេទ៖………………………………………………
- ទីកន្លែង៖………………………………………………….
- អ្នកសម្ភាស៖…………………………………………………
- អ្នកផ្តល់កិច្ចសម្ភាស៖……………………………..............
- តួនាទីរបស់អ្នកផ្តល់កិច្ចសម្ភាស៖…………………………..

វត្ថុបំណងនៃការសម្ភាសនិងការសិក្សាលើប្រធានបទនេះគឺអ្នកស្រាវជ្រាវមានបំណងរកឱ្យឃើញពីមូលហេតុទាំងឡាយដែលនាំឱ្យសិស្សខ្សោយការអានភាសាខ្មែរនៅថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំ ព្រម
ទាំងចង់លើកកម្ពស់សមត្ថភាពអានភាសាខ្មែរដល់សិស្សឱ្យបានប្រសើរឡើង។ ចំពោះព័ត៌មានដែលបានមកពីអ្នកចូលរួមម្នាក់ៗត្រូវប្រមូលមកទុកជាទិន្នន័យដើម្បីវិភាគ ហើយទិន្នន័យដែលបានមកទាំងអស់ អ្នកស្រាវជ្រាវនឹងរក្សាវាជាការសម្ងាត់។ ជាមួយគ្នានេះ រយៈពេលនៃការសម្ភាសគឺមិនឱ្យលើសពី ៤០នាទីនោះទេ បន្ទាប់មកអ្នកស្រាវជ្រាវក៏សុំការអនុញ្ញាតថតសំឡេងនៅកំឡុងពេលសម្ភាសនោះផងដែរ ពីព្រោះការពារការកត់ត្រាមានចន្លោះខ្វះខាត។ ហើយជាចុងក្រោយ អ្នកស្រាវជ្រាវសុំឱ្យអ្នកផ្តល់កិច្ចសម្ភាសអាននូវកំណត់ត្រាសម្ភាសនិងចុះហត្ថលេខាយល់ព្រមផងដែរ។

- **ចាប់ផ្តើមសាកល្បងម៉ាស៊ីនថតសំឡេង រួចថត៖**

**សំណួរសម្រាប់សម្ភាសគ្រូបង្រៀន**

1. *តើគ្រូមានទស្សនៈយល់ឃើញដូចម្តេចចំពោះអំណានរបស់សិស្សថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំលើមុខវិជ្ជាភាសាខ្មែរ?*

១) តើអ្នកគ្រូបង្រៀនភាសាខ្មែរថ្នាក់ទី៧បានរយៈពេលប៉ុន្មានឆ្នាំហើយ ?

២) តើដំណើរការនៃការបង្រៀនអំណានរបស់អ្នកគ្រូអនុវត្តយ៉ាងដូចម្តេច?

៣) តើអ្នកគ្រូយល់ថាសមត្ថភាពអំណានរបស់សិស្សស្ថិតនៅកម្រិតណាខ្លះ? ហើយអ្នកគ្រូឈរលើលក្ខខណ្ឌអ្វីខ្លះដើម្បីដឹងពីកម្រិតទាំងនោះ?

៤) តើអ្នកគ្រូយល់ថាកត្តាអ្វីខ្លះដែលនាំឱ្យសិស្សរបស់អ្នកគ្រូមានកម្សោយអំណានបែបនេះ?

៥)តើអ្នកគ្រូធ្លាប់បានណែនាំសិស្សពីតម្លៃនៃអំណានទៅកាន់សិស្សដែរឬទេ? បើធ្លាប់ តើអ្នកគ្រូបានណែនាំពួកគេយ៉ាងដូចម្ដេចអំពីតម្លៃនៃអំណាន?

៦) តាមការសង្កេតរបស់អ្នកគ្រូ តើសិស្សថ្នាក់ទី៧ ចូលចិត្តការអានដែរឬទេ? ព្រោះអ្វី?

៧) តើពួកគេឧស្សាហ៍ចូលបណ្ណាល័យឬទេ? ហេតុអ្វី?

៨) តើវត្ថុបំណងនៃការបង្រៀនអំណានដែលអ្នកគ្រូចង់បានគឺអ្វីខ្លះ?

៩) តើរាល់ការបង្រៀនអំណានរបស់អ្នកគ្រូ សិស្សរបស់អ្នកគ្រូតែងតែសម្រេចដល់វត្ថុបំណង ឬយ៉ាងណា? តើអ្វីខ្លះជាឧបសគ្គដែលនាំអ្នកគ្រូពិបាកសម្រេចដល់វត្ថុបំណងនៃមេរៀន?

### *២.តើភាគីពាក់ព័ន្ធត្រូវធ្វើដូចម្ដេច ដើម្បីឱ្យសិស្សទទួលបានលទ្ធផលល្អក្នុងការអានភាសាខ្មែរ?*

១) តើអ្វីខ្លះជាដំណោះស្រាយដែលអ្នកគ្រូធ្លាប់បានប្រើប្រាស់កន្លងមក ដើម្បីដោះស្រាយបញ្ហាទាំងនោះ? (ព្យាយាមសួរសម្អិតលើបញ្ហាដែលបានលើកឡើងខាងលើ)

២) តើអ្វីខ្លះជាសំណូមពររបស់លោកគ្រូ/អ្នកគ្រូ ដើម្បីដោះស្រាយបញ្ហាទាំងនេះ?

(សូមអរគុណដល់អ្នកចូលរួមនិងការសហការ ក្នុងការសម្ភាសន៍នេះ។ សូមធានាចំពោះអ្នកចូលរួមថានឹងរក្សាការសម្ងាត់នៃការឆ្លើយតបនិងបន្តសក្ដានុពលសម្រាប់ការសម្ភាសនាពេលអនាគត។ )

# ពិធីសារសម្ភាស

## ប្រធានបទ៖ ទស្សនៈរបស់សិស្ស គ្រូ និងអាណាព្យាបាលចំពោះសមត្ថភាពអំណានភាសាខ្មែររបស់សិស្សថ្នាក់ទី៧នៅអនុវិទ្យាល័យស្វាយរលំ

- ម៉ោងនៃការសម្ភាស៖…………………………………
- កាលបរិច្ឆេទ៖…………………………………………
- ទីកន្លែង៖………………………………………………
- អ្នកសម្ភាស៖……………………………………………
- អ្នកផ្ដល់កិច្ចសម្ភាស៖……………………….............
- **តួនាទីរបស់អ្នកផ្ដល់កិច្ចសម្ភាស៖**…………………….

វត្ថុបំណងនៃការសម្ភាសនិងការសិក្សាលើប្រធានបទនេះគឺអ្នកស្រាវជ្រាវមានបំណងរកឱ្យឃើញពីមូលហេតុទាំងឡាយដែលនាំឱ្យសិស្សខ្សោយការអានភាសាខ្មែរនៅថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំ ព្រមទាំងចង់លើកកម្ពស់សមត្ថភាពអានភាសាខ្មែរដល់សិស្សឱ្យបានប្រសើរឡើង។ ចំពោះព័ត៌មានដែលបានមកពីអ្នកចូលរួមម្នាក់ៗត្រូវប្រមូលមកទុកជាទិន្នន័យដើម្បីវិភាគ ហើយទិន្នន័យដែលបានមកទាំងអស់ អ្នកស្រាវជ្រាវនឹងរក្សាវាជាការសម្ងាត់។ ជាមួយគ្នានេះ រយៈពេលនៃការសម្ភាសគឺមិនឱ្យលើសពី៤០នាទីនោះទេ បន្ទាប់មកអ្នកស្រាវជ្រាវក៏សុំការអនុញ្ញាតថតសំឡេងនៅកំឡុងពេលសម្ភាសនោះផងដែរ ពីព្រោះការពារការកត់ត្រាមានចន្លោះខ្វះខាត។ ហើយជាចុងក្រោយ អ្នកស្រាវជ្រាវសុំឱ្យអ្នកផ្ដល់កិច្ចសម្ភាសអាននូវកំណត់ត្រាសម្ភាសនិងចុះហត្ថលេខាយល់ព្រមផងដែរ។

- **ចាប់ផ្ដើមសាកល្បងម៉ាស៊ីនថតសំឡេង រួចថត៖**

### សំណួរសម្រាប់សម្ភាសសិស្ស

***១)តើប្អូនមានទស្សនៈយល់ឃើញដូចម្ដេចចំពោះអំណានរបស់ប្អូននៅកម្រិតថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំលើមុខវិជ្ជាភាសាខ្មែរ?***

១) តើប្អូនចូលចិត្តការអានដែរឬទេ?

២) តើការរៀនភាសាខ្មែរមានការលំបាកសម្រាប់ប្អូនដែរឬទេ? ហេតុអ្វី?

៣) តើមួយអាទិត្យប្អូនបានចូលបណ្ណាល័យប៉ុន្មានដង? តើនៅផ្ទះប្អូនមានសៀវភៅច្រើនដែរឬទេ? ប្រភេទសៀវភៅអ្វីខ្លះ? ប្អូនអានវាញឹកញាប់ដែរឬទេ?

៤) តើប្អូនជួបបញ្ហាឬការលំបាកអ្វីខ្លះក្នុងការអាន?(មិនចេះពាក្យ មិនយល់ពីអត្ថន័យ ពិបាកក្នុងការផ្ចង់អារម្មណ៍)

៥) តើគ្រូរបស់ប្អូនធ្លាប់ប្រាប់ពីអត្ថប្រយោជន៍នៃការអានដែរឬទេ? បើគាត់ធ្លាប់ប្រាប់ តើគាត់បានប្រាប់ដូចម្តេចខ្លះ?

៧)តើប្អូនពេញចិត្តទៅនឹងវិធីសាស្ត្របង្រៀនអំណានរបស់គ្រូប្អូនដែរឬទេ? បើពេញចិត្ត ហេតុអ្វី(សួរពីចំណុចដែលពួកគេពេញចិត្តជាក់លាក់) បើមិនពេញចិត្ត ហេតុអ្វី(សួរពីចំណុចដែលពួកគេមិនពេញចិត្តជាក់លាក់) ?

៨) តើការរៀនអំណាននៅបឋមសិក្សានិងអនុវិទ្យាល័យខុសគ្នាដូចម្តេច?

(សូមអរគុណដល់អ្នកចូលរួមនិងការសហការ ក្នុងការសម្ភាសន៍នេះ។ សូមធានាចំពោះអ្នកចូលរួមថានឹងរក្សាការសម្ងាត់នៃការឆ្លើយតបនិងបន្តសក្តានុពលសម្រាប់ការសម្ភាសនាពេលអនាគត។ )

# ពិធីសារសម្ភាស

**ប្រធានបទ៖ ទស្សនៈរបស់សិស្ស គ្រូ និងអាណាព្យាបាលចំពោះសមត្ថភាពអំណានភាសាខ្មែររបស់សិស្សថ្នាក់ទី៧នៅអនុវិទ្យាល័យស្វាយរលំ**

- ម៉ោងនៃការសម្ភាស៖……………………………………
- កាលបរិច្ឆេទ៖…………………………………………….
- ទីកន្លែង៖…………………………………………………
- អ្នកសម្ភាស៖…………………………………………….
- អ្នកផ្ដល់កិច្ចសម្ភាស៖…………………………..............
- តួនាទីរបស់អ្នកផ្ដល់កិច្ចសម្ភាស៖………………………….

វត្ថុបំណងនៃការសម្ភាសនិងការសិក្សាលើប្រធានបទនេះគឺអ្នកស្រាវជ្រាវមានបំណងរកឱ្យឃើញពីមូលហេតុទាំងឡាយដែលនាំឱ្យសិស្សខ្សោយការអានភាសាខ្មែរនៅថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំ ព្រមទាំងចង់លើកកម្ពស់សមត្ថភាពអានភាសាខ្មែរដល់សិស្សឱ្យបានប្រសើរឡើង។ ចំពោះព័ត៌មានដែលបានមកពីអ្នកចូលរួមម្នាក់ៗត្រូវប្រមូលមកទុកជាទិន្នន័យដើម្បីវិភាគ ហើយទិន្នន័យដែលបានមកទាំងអស់ អ្នកស្រាវជ្រាវនឹងរក្សាវាជាការសម្ងាត់។ ជាមួយគ្នានេះ រយៈពេលនៃការសម្ភាសគឺមិនឱ្យលើសពី៤០នាទីនោះទេ បន្ទាប់មកអ្នកស្រាវជ្រាវក៏សុំការអនុញ្ញាតថតសំឡេងនៅកំឡុងពេលសម្ភាសនោះផងដែរ ពីព្រោះការពារការកត់ត្រាមានចន្លោះខ្វះខាត។ ហើយជាចុងក្រោយអ្នកស្រាវជ្រាវសុំឱ្យអ្នកផ្ដល់កិច្ចសម្ភាសអាននូវកំណត់ត្រាសម្ភាសនិងចុះហត្ថលេខាយល់ព្រមផងដែរ។

- ចាប់ផ្ដើមសាកល្បងម៉ាស៊ីនថតសំឡេង រួចថត៖

**សំណួរសម្រាប់សម្ភាសអាណាព្យាបាលសិស្ស**

1. *តើអាណាព្យាបាលរបស់សិស្សមានទស្សនៈយល់ឃើញដូចម្ដេចចំពោះអំណានរបស់សិស្សថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំលើមុខវិជ្ជាភាសាខ្មែរ?*

➢ **សំណួរប្រជាសាស្ត្រ**

១) តើបងបានបញ្ចប់ការសិក្សានៅកម្រិតណា?

២)តើសព្វថ្ងៃនេះបងនិងគ្រួសារបងមានអាយុប៉ុន្មានហើយ

៣)តើសព្វថ្ងៃនេះបងនិងគ្រួសារបងប្រកបមុខរបរអ្វីដែរ?

៤) តើបងមានកូនប៉ុន្មាននាក់ក្នុងបន្ទុក? ហើយពួកគេសិក្សានៅកម្រិតខ្លះទីប៉ុន្មានខ្លះ?

**សំណួរទាក់ទងនឹងការអានរបស់កូនគាត់**

១)តើបងយល់ថាការអានមានតម្លៃដូចម្តេចសម្រាប់កូនរបស់បង?

២) តើបងធ្លាប់បង្រៀនកូនឱ្យមានទម្លាប់ក្នុងការអាននៅផ្ទះដែរទេ?

៣) តើកូនបងមានទម្លាប់អាននៅផ្ទះដែរឬទេ?

៤) តើបងដែលសង្កេតមើលការសិក្សារបស់កូនបងដែរឬទេ? តើការសិក្សារបស់កូនបងដូចម្តេចដែរ? បើដឹង មូលហេតុអ្វី ហើយបើមិន ដឹងមូលហេតុអ្វី?

៥)តើបងដែលសង្កេតមើលការអានរបស់កូនបងដែរឬទេ? តើការអានរបស់កូនបងដូចម្តេចដែរ? បើដឹងមូលហេតុអ្វី ហើយបើមិនដឹងមូលហេតុអ្វី?

៦) តើបងយល់ដូចម្តេចដែរចំពោះការបង្រៀននៅសាលា (ចំពោះកម្មវិធីសិក្សា ចំពោះគ្រូ)? ជាពិសេសផ្តោតលើអំណាន។

*២.តើភាគីពាក់ព័ន្ធត្រូវធ្វើដូចម្តេច ដើម្បីឱ្យសិស្សទទួលបានលទ្ធផលល្អក្នុងការអានភាសាខ្មែរ?*

១)តើបងបានធ្វើអ្វីខ្លះដើម្បីជម្រុញការសិក្សារបស់គេ ជាពិសេសការអាន?

២) តើបងគួរធ្វើបែបណាដើម្បីជួយកូនបងឱ្យទទួលបានលទ្ធផលល្អក្នុងការរៀនអំណាន?

(សូមអរគុណដល់អ្នកចូលរួមនិងការសហការ ក្នុងការសម្ភាសន៍នេះ។ សូមធានាចំពោះអ្នកចូលរួមថានឹងរក្សាការសម្ងាត់នៃការឆ្លើយតបនិងបន្តសក្តានុពលសម្រាប់ការសម្ភាសនាពេលអនាគត។ )

# ពិធីសារសម្ភាស

**ប្រធានបទ៖ ទស្សនៈរបស់សិស្ស គ្រូ និងអាណាព្យាបាលចំពោះសមត្ថភាពអំណានភាសាខ្មែររបស់សិស្សថ្នាក់ទី៧នៅអនុវិទ្យាល័យស្វាយរលំ**

- ម៉ោងនៃការសម្ភាស៖………………………………….
- កាលបរិច្ឆេទ៖………………………………………….
- ទីកន្លែង៖…………………………………………………
- អ្នកសម្ភាស៖…………………………………………..
- អ្នកផ្តល់កិច្ចសម្ភាស៖………………………..............
- តួនាទីរបស់អ្នកផ្តល់កិច្ចសម្ភាស៖………………………..

វត្ថុបំណងនៃការសម្ភាសនិងការសិក្សាលើប្រធានបទនេះគឺអ្នកស្រាវជ្រាវមានបំណងរកឱ្យឃើញពីមូលហេតុទាំងឡាយដែលនាំឱ្យសិស្សខ្សោយការអានភាសាខ្មែរនៅថ្នាក់ទី៧នៃអនុវិទ្យាល័យស្វាយរលំ ព្រមទាំងចង់លើកកម្ពស់សមត្ថភាពអានភាសាខ្មែរដល់សិស្សឱ្យបានប្រសើរឡើង។ ចំពោះព័ត៌មានដែលបានមកពីអ្នកចូលរួមម្នាក់ៗត្រូវប្រមូលមកទុកជាទិន្នន័យដើម្បីវិភាគ ហើយទិន្នន័យដែលបានមកទាំងអស់ អ្នកស្រាវជ្រាវនឹងរក្សាវាជាការសម្ងាត់។ ជាមួយគ្នានេះ រយៈពេលនៃការសម្ភាសគឺមិនឱ្យលើសពី ៤០នាទីនោះទេ បន្ទាប់មកអ្នកស្រាវជ្រាវក៏សុំការអនុញ្ញាតថតសំឡេងនៅកំឡុងពេលសម្ភាសនោះផងដែរ ពីព្រោះការពារការកត់ត្រាមានចន្លោះខ្វះខាត។ ហើយជាចុងក្រោយ អ្នកស្រាវជ្រាវសុំឱ្យអ្នកផ្តល់កិច្ចសម្ភាសអាននូវកំណត់ត្រាសម្ភាសនិងចុះហត្ថលេខាយល់ព្រមផងដែរ។

- **ចាប់ផ្តើមសាកល្បងម៉ាស៊ីនថតសំឡេង រួចថត៖**

**សំណួរសម្រាប់សម្ភាសអ្នកជំនាញ**

## *២.តើភាគីពាក់ព័ន្ធត្រូវធ្វើដូចម្តេច ដើម្បីឱ្យសិស្សទទួលបានលទ្ធផលល្អក្នុងការអានភាសាខ្មែរ?*

១) តើលោក/លោកស្រី យល់យ៉ាងណាទៅលើការអានភាសាខ្មែររបស់សិស្សនៅកម្ពុជា ជាពិសេសសិស្សនៅកម្រិតអនុវិទ្យាល័យ?

២) តាមការយល់របស់លោក/លោកស្រី តើមូលហេតុអ្វីដែលនាំឱ្យពួកគេខ្សោយការអានភាសាខ្មែរ?

៣) ក្នុងនាមជាអ្នកជំនាញអក្សរសាស្ត្រខ្មែរ តើគួរធ្វើយ៉ាងណាដើម្បីឱ្យការអានភាសាខ្មែរប្រសើរឡើង?

(សូមអរគុណដល់អ្នកចូលរួមនិងការសហការ ក្នុងការសម្ភាសន៍នេះ។ សូមធានាចំពោះអ្នកចូលរួមថានឹងរក្សាការសម្ងាត់នៃការឆ្លើយតបនិងបន្តសក្ដានុពលសម្រាប់ការសម្ភាសនាពេលអនាគត។ )

# ឧបសម្ព័ន្ធ ខ៖ លិខិតស្នើសុំការស្រាវជ្រាវ

**មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី**

**NEW GENERATION PEDAGOGICAL RESEARCH CENTER**

ថ្ងៃសុក្រ១៥រោច ខែបឋមសាធ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ ២០២១

**សូមគោរពជូន**

**លោក ពេជ្រ សារា នាយកអនុវិទ្យាល័យស្វាយរលំ**

**កម្មវត្ថុ៖** សំណើសុំអនុញ្ញាតឱ្យគរុនិស្សិតឈ្មោះ **ទៀប ច័ន្ទថត្ថី** បានចុះប្រមូលទិន្នន័យស្រាវជ្រាវនៅ អនុវិទ្យាល័យស្វាយរលំ ក្នុងចន្លោះពីថ្ងៃទី០៩ ខែកក្កដា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១។

សេចក្តីដូចបានជម្រាបក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូន លោកនាយកជ្រាបថា លោកស្រី **ទៀប ច័ន្ទថត្ថី** ជាគរុនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យជំនាន់ទី២ មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី នៃវិទ្យាស្ថានជាតិអប់រំ។ លោកស្រី មានគម្រោងចុះស្រាវជ្រាវលើប្រធានបទ "**ទស្សនៈរបស់សិស្ស គ្រូ និងអាណាព្យាបាលចំពោះសមត្ថភាពអំណានភាសាខ្មែររបស់សិស្សថ្នាក់ទី៧នៅអនុវិទ្យាល័យស្វាយរលំ**" ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ។ គោលបំណងនៃការចុះប្រមូលទិន្នន័យនេះ គឺដើម្បីប្រមូលព័ត៌មានសំខាន់ៗដែលទាក់ទងទៅនឹងប្រធានបទស្រាវជ្រាវខាងលើ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ អាចរួមចំណែកក្នុងការជំរុញឱ្យការរៀននិងបង្រៀនកាន់តែមានលក្ខណៈល្អប្រសើរឡើង។

អាស្រ័យហេតុនេះ សូមលោកនាយកមេត្តាអនុញ្ញាតនិងជួយសម្រួលដល់និស្សិតរូបនេះបានចុះប្រមូលទនិន្ន័យតាមការស្នើសុំដូចមានក្នុងកម្មវត្ថុខាងលើដោយក្តីអនុគ្រោះ។

សូមលោកនាយកទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ

**ប្រធានមជ្ឈមណ្ឌល**

**បណ្ឌិតសភាចារ្យ ច័ន្ទ រ័ត្ន**

ឯកសារ មសគថ.

អាសយដ្ឋាន៖ មហាវិថីព្រះនរោត្តម, វិទ្យាស្ថានជាតិអប់រំ, អគារ I, រាជធានីភ្នំពេញ, លេខទូរសព្ទ និងតេឡេក្រាម៖ ០១១៦៩៧០៣៨
Address: #123, Preah Norodom Blvd, NIE, Building I, Phnom Penh, Cambodia, www.ngprc.edu.kh, email: ngprc@moeys.gov.kh

# Empowering educators with ethical and evidence-based practices




Email: ngprc.faculty@gmail.com
Website: www.ngprc.edu.kh